អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 11-Dec-2012, 11:58
CMS/CFO: Uch Arun

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសង

**ថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១២**

**ម៉ោង ០៩: ០៣នាទី**

**សវនាការលើកទី១៣៦**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍ *(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ *(Judge Jean-Marc LAVERGNE)*

ចៅក្រម ធូ មណី

ចៅក្រម យូរ ឧត្តរា

ចៅក្រម ក្លូឌា ហ្វេនស៍ *(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

លោក ដាវ អានសាន

លោក រ៉ូជឺ ហ្វីលីព *(Mr.Roger PHILLIP)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វ៉េង ហ៊ាត់

លោក ថារីក អាប់ឌុលឡាក់ *(Mr. Tarik ABDULHAK)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ហ្សាស្ពើ ប៉ៅ*(Mr Jasper PAUW)*

លោក អេនឌ្រូ អ៊ីនូហ្ស៊ី
*(Mr. Andrew IANUZZI)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ
*(Ms. Anta GUISSÉ)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស
*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត
*(Ms. Elisabeth SIMONNEAU-FORT)*

លោកស្រី ទី ស្រ៊ីនណា

លោក ហុង គឹមសួន

លោក វ៉ែន ពៅ

លោក ឡោ ជុនធី

លោកស្រី ស៊ីន សុវ៉ន

លោកស្រី គ្រីស្ទីន ម៉ាទីណូ
*(Ms. Chritine MARTINAU)*

លោកស្រី អ៊ីស្សាបែល ឌៀរ៉ង់
*(Ms. Isabelle DURAND)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណា

លោកស្រី សួ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍ | អង់គ្លេស |
| លោក អាប់ឌុលឡាក់ ថារីក | អង់គ្លេស |
| លោក វ៉េង ហ៊ត់ | ខ្មែរ |
| លោក អាង ឧត្តម | ខ្មែរ |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក អេនឌ្រូ អ៊ីនូហ្វី | អង់គ្លេស |
| លោក ហ្វាស្តេ ប៉ៅ | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |
| លោក គង់ សំអុន | ខ្មែរ |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក គឹម វ៉ាន់ឌី (TCCP-59) | ខ្មែរ |
| លោក ហ៊ុន ឈុនលី (TCW-247) | ខ្មែរ |

## ឧបសម្ព័ន្ធ

**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី៖ លោក គឹម វ៉ាន់ឌី** (TCCP-59)
សួរបន្តដោយលោកស្រី ទី ស្រ៊ីនណា ផ្តើមពី៖.................... ទំព័រ ៨
សួរដោយលោក អាប់ឌុលឡាក់ ថារីក ផ្តើមពី៖.................... ទំព័រ ១៦

**ការសួរសំណួរទៅសាក្សី៖ លោក ហ៊ុន ឈុនលី** (TCW-247)
សួរដោយប្រធានអង្គជំនុំ ផ្តើមពី៖.................... ទំព័រ ២៥
សួរដោយលោក វ៉េង ហ៊ត់ ផ្តើមពី៖.................... ទំព័រ ២៨
សួរដោយលោក អាប់ឌុលឡាក់ ថារីក ផ្តើមពី៖.................... ទំព័រ ៤៨

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៣:៣៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ តាមកាលវិភាគដែលបានគ្រោងទុកនៅកិច្ចដំណើរការសវនាការថ្ងៃនេះ អង្គជំនុំជម្រះនឹងបន្តស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណី គឹម វ៉ាន់ឌី ហើយនឹងចាប់ផ្ដើមស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម TCW-247។

ក្រឡាបញ្ជីសវនាការលោក ឌុច ផារី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការថ្ងៃនេះ គ្រប់ភាគីទាំងអស់នៃរឿងក្ដីមានវត្តមាន។ លើកលែងតែជនជាប់ចោទ អៀង សារី មានវត្តមាននៅបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការដោយមូលហេតុសុខភាព។ ដើមបណ្ដឹងរដ្ឋប្បវេណីដែលត្រូវបន្តផ្ដល់សក្ខីកម្មថ្ងៃនេះ គឺលោក គឹម វ៉ាន់ឌី ដើមបណ្ដឹងរដ្ឋប្បវេណីមានវត្តមានរួចហើយ។

[០៩:០៥:១១]

ចំពោះសាក្សីបម្រុងសម្រាប់សវនាការថ្ងៃនេះ គឺសាក្សីដែលមានរហស្សនាម TCW-247 សាក្សីរូបនេះបានបញ្ជាក់ថា តាមសតម្ដភាពដែលគាត់អាចដឹង គឺគាត់មិនមានចំណងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងបីរូប ឬដើមបណ្ដឹងរដ្ឋប្បវេណីណាមួយដែលបានទទួលស្គាល់នោះទេ។ សាក្សីរូបនេះបានធ្វើសម្បថនៅចំពោះមុខរូបលោកតាដំបងដែក កាលពីព្រឹកមិញរួចហើយ។ សាក្សីរូបនេះមិនមានមេធាវីប្រឹក្សានោះទេ។

ក្រឡាបញ្ជីកត់សម្គាល់ផងដែរ អំពីវត្តមានរបស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបរទេសមួយរូបឈ្មោះ អ៊ីស្សាបែល ឌៀរ៉ង់ ដែលមេធាវីរូបនេះមិនទាន់បានទទួលស្គាល់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៅឡើយទេ។

សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក ឌុច ផារី។

អង្គជំនុំជម្រះបានស្តាប់នូវសេចក្តីរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមាន ភាគីនិងបុគ្គលទាំងឡាយដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះ។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា នៅក្នុងកិច្ចដំណើរការសវនាការនេះ មានវត្តមានមេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណីមួយរូប ដែលគាត់មិនទាន់ត្រូវបានទទួលស្គាល់នៅក្នុងអំឡុងពេលដំណើរការនីតិវិធីសវនាការលើសំណុំរឿងក្តីនេះកន្លងមក។

[០៩:០៦:៤១]

ដូច្នេះអង្គជំនុំជម្រះបំពេញកិច្ចនីតិវិធីទទួលស្គាល់មេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណីរូបនេះជាមុនសិន មុននឹងចាប់ផ្តើមបន្តដំណើរការពិភាក្សាដេញដោលស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី គឹម វ៉ាន់ឌី។

ដោយអនុលោមតាមវិធាន២២(២)(ក) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះសូមអញ្ជើញលោក ពេជ អង្គ ដែលជាសហមេធាវីជាតិនៃមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ឡើងធ្វើការស្នើសុំទទួលស្គាល់មេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលមានវត្តមាននៅក្នុងសវនាការនេះ។ ហើយមេធាវីរូបនោះ គឺដែលមិនទាន់បានទទួលស្គាល់ពីអង្គជំនុំជម្រះសាលាដំបូងពីអំឡុងពេលកន្លងមក។

សូមអញ្ជើញលោក ពេជ អង្គ!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម អង្គសវនាការទាំងមូល។ នៅពីខាងក្រោយខ្ញុំនេះគឺមានវត្តមានរបស់លោកស្រីមេធាវី អ៊ីស្សាបែល ឌៀរ៉ង់ ជាមេធាវីដែលមាន -- សមាជិកនៃគណៈមេធាវីនៃទីក្រុងឡូប្រទេសបារាំង។ លោកស្រីត្រូវបានទទួលស្គាល់ដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ឲ្យចុះបញ្ជីនៅក្នុងបញ្ជីគណៈមេធាវីរួចហើយ នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ ២០០៨ ហើយបានស្បថនៅចំពោះមុខសាលាឧទ្ធរណ៍នៃព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ រួចហើយ។

[០៩:០៨:១២]

លោកស្រីជាមេធាវីម្នាក់នៅក្នុងក្រុមមេធាវីៗគ្មានព្រំដែនប្រទេសបារាំង។ សូមលោកប្រធានអនុញ្ញាតទទួលស្គាល់ ដើម្បីលោកស្រីមានសិទ្ធិនៅក្នុងការបំពេញកិច្ចនៃនីតិវិធីជាប្រយោជន៍ទៅដល់ដើមបណ្ដឹងរដ្ឋប្បវេណីរបស់គាត់។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកស្រីមេធាវី អ៊ីស្សាបែល ឌៀរ៉ង់ អញ្ជើញក្រោកឈរ!

លោកស្រី អ៊ីស្សាបែល ឌៀរ៉ង់ អង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់លោកស្រីជាមេធាវីអន្តរជាតិតំណាងដើមបណ្ដឹងរដ្ឋប្បវេណី សម្រាប់គោលបំណងនៃកិច្ចដំណើរការនីតិវិធីចំពោះមុខអង្គជំនុំជម្រះសាលាដំបូង សម្រាប់ក្នុងសំណុំរឿង០០២នេះ។ អនុលោមតាមការទទួលស្គាល់នេះ លោកស្រីមេធាវីមានសិទ្ធិ និងបុព្វសិទ្ធិដូចគ្នានឹងមេធាវីជាតិតំណាងដើមបណ្ដឹងរដ្ឋប្បវេណីដែរ។ សូមអង្គុយចុះ!

សូមអញ្ជើញលោក អាង ឧត្ដម!

[០៩:០៩:១៤]

**លោក អាង ឧត្ដម៖**

សូមគោរពលោកប្រធាន! សូមគោរពលោក លោកស្រីចៅក្រម! សួស្ដីសហព្រះរាជអាជ្ញា សួស្ដីសហភាគា ហើយលោកអ្នកទាំងឡាយដែលចូលរួមសវនាការនេះនៅក្នុងបន្ទប់ និងក្រៅបន្ទប់ផង។ នៅថ្ងៃទី០៦ ខែធ្នូ នេះ ខ្ញុំ -- យើងខ្ញុំបានទទួល ប្រហែលជាអង្គជំនុំជម្រះបានទទួលដែររបាយការណ៍ពេទ្យរបស់លោក អៀង សារី ដែលបញ្ជាក់ថា ស្ថានភាពទូទៅនៅពេលសម្រាកអង្គុយស្ងៀមមានលំនឹង។ ក៏ប៉ុន្តែពេល -- ប៉ុន្តែការធ្វើចលនាបន្តិចបន្តួចបណ្ដាលឲ្យហត់ វិលមុខ និងអស់កម្លាំង។ គាត់ត្អូញត្អែរថា ដេកមិនលក់ទេយប់មិញនេះ អង្គុយមិនបានទេ។ សំណូមពរលោកប្រធានអនុញ្ញាតឲ្យគាត់ចូលរួមបន្ទប់សវនាការនៅខាងក្រោម។

ទាក់ទងចំណុចនេះ ខ្ញុំសូមទាញការកត់សម្គាល់ពីរចំណុចជូនលោក -- ជូនអង្គសវនាការ។

យើងឃើញថាមានតែពេទ្យផ្នែក -- ខាងផ្នែកផ្លូវកាយទេ ដែលបញ្ជាក់ថាគាត់មិនអាចអង្គុយបានទេ ក៏ប៉ុន្តែអត់មានពេទ្យ ឬក៏ឯកទេសណាបញ្ជាក់ថា គាត់អាចតាមដានសវនាការបាននោះទេ។ ក្នុងករណីនេះ ដោយហេតុថា ពេទ្យខាងផ្លូវកាយបញ្ជាក់តែត្រឹមស្ថានភាពផ្លូវកាយរបស់គាត់បែបនេះ តែអត់ទាន់មានអ្នកជំនាញឯកទេសណាមកបញ្ជាក់បង្ហាញពីលទ្ធភាព នៃការចូលរួមតាមសតិស្មារតីរបស់លោក អៀង សារី នៅឡើយ។ ខ្ញុំ (សូមទោស) យើងខ្ញុំជាសហមេធាវីការពារលោក អៀង សារី ស្នើសុំ

ឲ្យតុលាការចាត់តាំងអ្នកជំនាញអ្នកឯកទេស ដែលអាចបញ្ជាក់ពីភាពអាចចូលរួមបានរបស់លោក អៀង សារី នៅក្នុងសវនាការ តាមរយៈស្មារតី និងសតិរបស់គាត់ផង ដើម្បីឲ្យស្របទៅតាមការទទួលស្គាល់ថា លោក អៀង សារី អាចចូលរួមសវនាការបាន។ នេះចំណុចទី១។

[០៩:១១:១២]

ទី២. លោក -- ខ្ញុំបានកំណត់កត់សម្គាល់បញ្ជាក់ប៉ុណ្ណឹងថា ក្នុងករណីដែលលោក អៀង សារី សម្រាន្តលក់ គឺ*ខេសមេណេជ្ជឺ* ត្រូវដាស់។ ខ្ញុំសូមគូសបញ្ជាក់ចំណុចនេះបន្តិចថា *ខេសមេណេជ្ជឺ* របស់ខ្ញុំក្នុងកិច្ចសន្យារបស់គាត់ អត់មានមុខនាទីអីទៅអង្គុយដាស់អ្នកជំងឺនៅក្នុងបន្ទប់សវនាការ មុខងាររបស់គាត់គឺជួយកិច្ចការរបស់យើងខ្ញុំនៅទីនេះ និងនៅបន្ទប់ការិយាល័យរបស់យើង។ យើងធ្វើបែបនេះបានតែរយៈពេលបណ្ដោះអាសន្នខ្លីៗតែប៉ុណ្ណោះទេ។ យើងមិនអាចធ្វើទូទៅទេ។ ទី១។ ទី២ ការដែលដាស់លោកអៀង សារី គឺគាត់ភ្ញាក់បានតែមួយភ្លែត យ៉ាងយូរណាស់១នាទី គាត់នឹងលក់ទៅវិញហើយ។ ហើយពេលដែលគាត់ក្រោកម្ដងៗហ្នឹង គឺគាត់អត់ដឹងថាអ្នកណានិយាយអីទេ អត់ដឹងទេ។ ទី៣. ថាតើការដាស់អ្នកជំងឺបែបនេះ វាប៉ះពាល់ដល់កិច្ចការរបស់គ្រូពេទ្យឬអត់? ពីព្រោះជាទូទៅ ឧទាហរណ៍ដូចនៅពេទ្យ បើយើងទៅពេទ្យ ពេទ្យសុទ្ធកម្រិតព្រំដែនឲ្យយើងជួបក្នុងខណៈដែលពេទ្យព្យាបាលមិនឲ្យយើងជួប ក្នុងខណៈដែលអ្នកជំងឺកំពុងត្រូវឲ្យសម្រាកក៏យើងមិនអាចជួប។ តែករណីនេះ ឧទាហរណ៍ថា ដាស់ទៅវាប៉ះពាល់ដល់សុខភាព ឬបណ្ដាលឲ្យមានភាព ព្រឹត្តិការណ៍អីមួយកើតឡើង ឧទាហរណ៍មកដាស់ទៅ ទៅជាគាត់គាំងបេះដូង ឧទាហរណ៍អីអ៊ីចឹង។ តើ*ខេសមេណេជ្ជឺ* ខ្ញុំអ្នកដាស់ហ្នឹងនឹងទទួលបន្ទុកទទួលខុសត្រូវលើបញ្ហានេះដែរឬអត់?

នេះជាបញ្ហា។ ខ្ញុំសូមទាញការយកចិត្តទុកដាក់ពីតុលាការតាមចំណុចទាំងអស់នេះ ហើយសូមតុលាការមេត្តាពិចារណាទៅតាមសំណូមពរ និងសំណើរបស់យើងខ្ញុំផង។ សូមអរគុណ។

[០៩:១៣:០៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ចារីក៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមបញ្ជាក់ដោយខ្លី។

គឺថាយើងមិនទាន់ធ្វើរបាយការណ៍ឲ្យបានច្បាស់ ដូច្នេះយើងផ្អែកទៅតាមអ្វីដែលសហភាតាខ្ញុំ

បានលើកឡើង។ ខ្ញុំសូមឆ្លើយតបដោយសង្ខេប ដែលថា នៅព្រឹកនេះ ខ្ញុំមិនបានឮអ្វីដែលតម្រូវឲ្យអង្គជំនុំជម្រះសាលាដំបូងត្រូវមានកាតព្វកិច្ច ឬមានឆន្ទានុសិទ្ធិក្នុងការចាត់តាំងអ្នកជំនាញថ្មី ឬក៏ចាត់តាំងអ្នកជំនាញដើម្បីបញ្ចេញមតិនោះឡើយ។

សហភាតាបាននិយាយអំពីបញ្ហាដែលថាអាច និយាយដែលថានិយាយអំពីសុខភាព ឬក៏សុខមាលភាពរបស់លោក អៀង សារី នៅបន្ទប់ខាងក្រោម ដោយសារតែមិនមានវេជ្ជបណ្ឌិត ដែលអាចមានសមត្ថភាពវាយតម្លៃអំពីស្ថានភាពសតិបញ្ញារបស់គាត់។ ដូច្នេះហើយ ទើបខាងសហភាតាគាត់លើកឡើងថា មិនទាន់មានរបាយការណ៍ទាក់ទងទៅនឹងសតិបញ្ញា។ ប៉ុន្តែតាមរបាយការណ៍របស់អ្នកជំនាញកាលពីពេលមុនគឺថា លោក អៀង សារី មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួម ហើយលោកលោកស្រីចៅក្រមបានដឹងច្បាស់ផងដែរថា គោលការណ៍អន្តរជាតិ ដែលយើងយកមកអនុវត្ត គឺមិនតម្រូវឲ្យមានការត្រួតពិនិត្យទៅលើជនជាប់ចោទជារៀងរាល់ម៉ោង ឬក៏ជារៀងរាល់នាទីនោះឡើយ។

ដូច្នេះហើយ ប្រសិនបើគ្មានការចង្អុលបង្ហាញ ឬក៏គ្មានសញ្ញាណាមួយដែលថា គាត់មានបញ្ហាសុខភាព ឬក៏មានបញ្ហាសម្បទាណាមួយ គឺយើងមិនចាំបាច់ត្រូវធ្វើការចាត់តាំងអ្នកជំនាញ ដើម្បីធ្វើការវាយតម្លៃនោះឡើយ។

[០៩:១៥:៥៩]

ដូច្នេះ ខ្ញុំចង់ចង្អុលបញ្ជាក់ ឬក៏ចង់អះអាងថា ខាងព្រះរាជអាជ្ញាក៏មានការព្រួយបារម្ភផងដែរ ដែលថា ជនជាប់ចោទត្រូវតែទទួលបាននូវការព្យាបាល ឬក៏បានយកចិត្តទុកដាក់ផ្នែកសុខភាពឲ្យបានល្អ។ ប៉ុន្តែយ៉ាងណាក៏ដោយ វាជាឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះក្នុងការពិនិត្យ និងការសម្រេចទៅលើរបាយការណ៍វេជ្ជបណ្ឌិត។ ខ្ញុំគិតថាអ្វីដែលខាងមេធាវីការពារក្តីបានលើកឡើងគឺជាព័ត៌មានល្អ ប៉ុន្តែវាមិនមែនជាការចាំបាច់ ឬក៏ជាអ្វីដែលយើងត្រូវតែទាមទារ ឬក៏តម្រូវឲ្យមានការអនុវត្តអ្វីនោះឡើយ។ ប្រសិនបើព័ត៌មានរបស់វេជ្ជបណ្ឌិតគ្រប់គ្រាន់ គឺថាយើងមិនចាំបាច់ត្រូវមានអ្វីបន្ថែមនោះឡើយ។

ជាចុងក្រោយ ខាងសហភាតារបស់ខ្ញុំ គឺខាងមេធាវីការពារក្តីបានបញ្ជាក់អំពី *ខេសមេណេជ្ជឺ* គឺថាអ្នកគ្រប់គ្រងសំណុំរឿង ដែលថា *ខេសមេណេជ្ជឺ* មិនមានតួនាទីក្នុងការដាស់ ឬក៏មិនមានតួនាទីក្នុងការធ្វើឲ្យលោក អៀង សារី ងើបនោះឡើយ។ ប៉ុន្តែគាត់ក៏មិនមានតួនាទីក្នុងការកត់ត្រាទៅលើស្ថានភាពរបស់ អៀង សារី ជារៀងរាល់នាទី ឬក៏ជារៀងរាល់ម៉ោងនោះឡើយ។ នេះគឺមិនមែនជាអ្វីដែល -- នេះក៏មិនមែនជាអ្វីដែលជាការតម្រូវរបស់គាត់ផងដែរនោះទេ។ ដូច្នេះ ចំណុចទាំងអស់នេះមិនមានអ្វីដែល

ថាបញ្ជាក់ថាជាការត្រឹមត្រូវនោះឡើយ។ សូមអរគុណលោកប្រធាន។

[០៩:១៦:២២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ជម្រាបសួរលោកប្រធាន ជម្រាបសួរលោក លោកស្រីចៅក្រម។ ខ្ញុំចង់បន្ថែមពាក្យពេចន៍មួយចំនួនទៅលើមតិរបស់សហព្រះរាជអាជ្ញា។ យើង -- ទោះបីជាយើងគិតថាវាជារឿងធម្មតាក្នុងការពិភាក្សាអំពីសម្បទារបស់លោក អៀង សារី ក៏ដោយនោះ ក៏យើងគិតថាមានព័ត៌មានគ្រប់គ្រាន់ដែលបានផ្តល់ជូននៅថ្ងៃនោះ -- នៅថ្ងៃនេះ។ យើងមិនដឹងថាតើគាត់គេងនៅក្នុងរយៈពេល៥នាទី ឬក៏១ម៉ោង ឬក៏អ្នកណាជាអ្នកដាស់គាត់អីនោះទេ។ យើងៗមិនគួរធ្វើការពិភាក្សាបែបនេះរៀងរាល់ព្រឹកបែបនេះនោះទេ។ ដូច្នេះ វាមិនសមស្របទេ បើយើងធ្វើការពិភាក្សាបែបនេះនោះ វាជាការគោរពសាធារណជន និងដើមបណ្តឹងរដ្ឋប្បវេណីនោះ ខ្ញុំគិតថាអង្គជំនុំជម្រះគួរតែបញ្ចប់នូវការពិភាក្សារឿងបែបនេះជារៀងរាល់ព្រឹកបែបនេះដែលជាការមួយមិនគោរពនោះទេ។ សូមអរគុណលោកប្រធាន។

[០៩:១៧:៣០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី អាង ឧត្តម!

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន! យើងខ្ញុំក៏មិនចង់ចំណាយពេលរៀងរាល់ព្រឹកដូចសហព្រះរាជអាជ្ញាអះអាងកាលពីម្សិលមិញដែរ គឺរៀងរាល់ព្រឹកបែបនេះទេ។ យើងអត់ចង់ទេ។ ហើយយើងក៏មិនប្រាថ្នាដែរ។ យើងប្រាថ្នាចង់ឲ្យបានលោក អៀង សារី ចូលរួមពេញលេញដូចអ្នកដទៃដែរ។ ហើយដើម្បីជៀសវាងចំណុចនេះ មានដំណោះស្រាយមានតែមួយទេ គឺតែងតាំងអ្នកជំនាញ អ្នកឯកទេសខាងសរសៃប្រសាទ ខាងសតិស្មារតីមក ឲ្យគាត់រាយការណ៍គួបជាមួយនឹងគ្រូពេទ្យខាងផ្លូវកាយជាមួយគ្នាមក យើងមានរបាយការណ៍ យើងអត់បាច់អះអាងជារាល់ព្រឹកទេ។ ផ្អែកលើរបាយការណ៍ ខ្ញុំអាចធ្វើសំណូមពរតែម្តង ផ្ទាល់មាត់ ជាលាយលក្ខណ៍អក្សរតែម្តង។ ដោយសារតែអត់ហ្នឹងហើយបានយើងរាយករណ៍ ត្រូវតែរាយការណ៍ជាៗប្រចាំអីចឹង ហ្នឹងហើយ។ ហើយយើងចង់បានរបាយការណ៍អ្នក

ជំនាញហ្នឹងជាប្រចាំថ្ងៃតែម្តង អ្នកជំនាញធ្វើដូចគ្រូពេទ្យខាងផ្លូវកាយអ៊ីចឹងដែរ។ ចង់ឲ្យបានការពិនិត្យជាប្រចាំថ្ងៃដែរ ពីព្រោះដើម្បីឲ្យស្រប ពីព្រោះថារបាយការណ៍លោក ចន ខាំប៊ែល ក៏ផ្អែកលើការពិនិត្យរបស់គាត់តែ២ថ្ងៃ ហើយមិន២ថ្ងៃ ពេញថ្ងៃណា តែប៉ុន្មានម៉ោងសោះហ្នឹង គាត់ចេញរបាយការណ៍មួយសម្រាប់អនុវត្តទូទៅក្រោយមករហូតទៀត។

យើងមិនប្រាកដថារបាយការណ៍២ថ្ងៃនុ៎ងមកវាសុក្រឹត្យ ហើយវាអាចអនុវត្តត្រឹមត្រូវរហូតមកដល់ពេលនេះ ហើយតទៅអនាគតទេ។ វាមិនអាចថាអ៊ីចឹងបានទេ ពីព្រោះសុខភាពគាត់ប្រែប្រួលជាប្រចាំ ជាញឹកញាប់ ជាប្រក្រតី។ ពួកយើងមិនចង់បង្កឲ្យមានបញ្ហាយឺតយ៉ាវ ឬក៏អាក់ខានដល់ពេលវេលានេះទេ។ ដើម្បីដោះស្រាយអ៊ីចឹងមានតែទទួលយកសំណូមពររបស់យើងខ្ញុំទៅ ដើម្បីវាឲ្យសមស្រប និងឆាប់ចប់កិច្ចការ។ សូមអរគុណ។

[០៩:១៩:៣០]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:២១:៣៤]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រគល់ភារៈជូនទៅលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយច៏ ដើម្បីឆ្លើយតបទៅនឹងសំណើសុំរបស់លោកមេធាវី អាង ឧត្តម មេធាវីការពារក្តីលោក អៀង សារី ដែលបានលើកឡើងនូវបញ្ហាមួយចំនួនអម្បាញ់មិញនេះ។

សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយច៏៖**

សូមអរគុណលោកប្រធាន។ អង្គជំនុំជម្រះបានបញ្ជាក់ ហើយបានសម្រេចដូចខាងក្រោម៖ ការសម្រេចកាលពីម្សិលមិញនៅមានប្រសិទ្ធភាព ព្រោះគ្មានព័ត៌មានវេជ្ជសាស្ត្រថ្មីដែលអាចធ្វើឲ្យមានយុត្តិកម្មដែលតម្រូវឲ្យមានការកែប្រែរបស់អង្គជំនុំជម្រះសាលាដំបូងឡើយ។ អង្គជំនុំជម្រះសាលាដំបូងបាកកត់សម្គាល់ថានេះជាលើកទី១ ហើយដែលខាង អៀង សារី បានធ្វើការបញ្ជាក់អំពីបញ្ហាសតិបញ្ញា ហើយយើងនឹងពិចារណាទៅលើសំណើនេះ។ ដូច្នេះសំណើនេះគួរតែធ្វើឡើងជាលាយលក្ខណ៍អក្សរ។ អង្គជំនុំជម្រះមិនស្តាប់នូវពាក្យសុំជាផ្ទាល់មាត់ជារៀងរាល់ព្រឹកបែបនេះឡើយ គឺនៅពេលដែលអង្គជំនុំជម្រះចាប់ផ្តើមនោះឡើយ។ លើកលែងតែក្នុងករណីដែលមានអ្វីដែលវាថ្មី ឬក៏ដែលមានអ្វីវាប្រែប្រួល

ប្លែក។ គឺយើងពិនិត្យតែទៅលើរបាយការណ៍របស់វេជ្ជបណ្ឌិត ហើយប្រសិនបើរបាយការណ៍វេជ្ជ-បណ្ឌិតមិនមានអ្វីប្រែប្រួលនោះទេ។ នេះគឺជាការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង។ សូមអរគុណ។

**លោក អាង ឧត្តម៖**

ខ្ញុំសូមអរគុណចំពោះលោកស្រីចៅក្រម ដែលបានបញ្ជាក់ចំណុចនេះ។ តែខ្ញុំមាន -- មិនៗ -- យើងខ្ញុំគោរពសេចក្ដីសម្រេច ក៏ប៉ុន្តែខ្ញុំ -- យើងខ្ញុំមិនៗស្របនឹងការសម្រេចនេះ។ ទី១ ដែលលោកស្រីអះអាងថា--

**ប្រធានអង្គជំនុំ៖**

ចប់ហើយលោក អង្គជំនុំជម្រះបានសម្រេចរួចហើយណ៎ះ!

បាទ ជាបន្តអង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដី -- ក្រុមមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។ ហើយអង្គជំនុំជម្រះសូមជម្រាបថា ក្នុងការសួរនេះគឺរួមទាំងតំណាងសហព្រះរាជអាជ្ញាផង គឺនៅមានពេលវេលា ៤០នាទីតែប៉ុណ្ណោះ។ សូមជ្រាប ហើយនិងសូមរៀបចំនូវសំណួរសក្ដានុពលដើម្បីឲ្យការប្រើប្រាស់ពេលវេលាដែលកំណត់ជូននេះមានប្រសិទ្ធភាព។

[០៩:២៤:១៥]

**លោកស្រី ទី ស្រ៊ុនណា៖**

សូមអរគុណលោកប្រធាន និងសូមគោរពលោកប្រធានសាជា -- លោកប្រធាន និងលោកលោកស្រីចៅក្រម ក៏ដូចជាអង្គសវនាការទាំងមូលសាជាថ្មីម្ដងទៀត។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរបន្តដោយលោកស្រី ទី ស្រ៊ុនណា៖**

**ស៖** សួស្ដីលោក គឹម វ៉ាន់ឌី! កាលពីម្សិលមិញលោកបានរៀបរាប់ថា "ឪពុករបស់លោកហ្នឹងត្រូវបានគេចាប់ចង -- ចងស្ពាយសេកយកទៅ -- បណ្ដើរយកទៅសម្លាប់"។ អ៊ីចឹងខ្ញុំចង់សួរលោកថាតើអ្នកដែលទៅចាប់ឪពុករបស់លោកហ្នឹងមានគ្នាប៉ុន្មាននាក់ដែរ នៅពេលនោះ? ហើយពួកគាត់ហ្នឹងមានតួនាទី ឬក៏ឈ្មោះអ្វីដែរលោកស្គាល់ ឬក៏ៗ នៅចាំបានដែរឬទេ នៅពេលនោះ?

**លោក គឹម វ៉ាន់ឌី៖**

**ឆ៖** បាទ ខ្ញុំ ពេលដែលគេចាប់ឪពុកខ្ញុំនឹងទៅ យកទៅហ្នឹងគឺមានគ្នាពីរនាក់ ៗ តែខ្ញុំមិនបាន

ស្គាល់ឋាន: មិនបានស្គាល់ឈ្មោះគេទេ។ គេហ្នឹងជាឯកសណ្ឋានពណ៌ខ្មៅ ហើយមានកាន់កាំភ្លើងពីរដើម យកក្រមាយើងហ្នឹងចងចង្កេះៗ បណ្តើរឪពុកខ្ញុំហ្នឹងចេញទៅផុតពីភ្នែកខ្ញុំហ្នឹងឆ្ងាយណាស់ រហូតខ្ញុំតាមមើល ដល់តែផុតឆ្ងាយមើលលែងឃើញបានខ្ញុំបែរអារម្មណ៍មកមើលគោមើលសត្វខ្ញុំវិញ។ បាទ ខ្ញុំចាំបានប៉ុណ្ណឹង។

[០៩:២៦:០៩]

**ស៖** ខ្ញុំសូមបន្តសំណួរទៀត។ នៅក្រោយពេលដែលគេយកឪពុករបស់លោក យកទៅសម្លាប់ តើមានអ្វីកើតឡើងចំពោះម្តាយ រូបលោកផ្ទាល់ក៏ដូចជា ប្អូនៗរបស់លោកដែរឬទេ?

**ឆ៖** ពេលដែលគេយកឪពុកខ្ញុំទៅសម្លាប់ហ្នឹង ពេលនោះដឹងរឿង ជុំគ្នាទៅដឹងរឿងៗទាំងអស់ ម្តាយខ្ញុំស្រក់ទឹកភ្នែកសោកស្តាយដែលបាត់សមាជិកដែលធ្លាប់ជុំគ្នា នៅជុំគ្នា ក្រោយមកហ្នឹងក៏ដូចជា យើងនឹងធ្វើជាអង្គប្រជុំមួយដ៏តូចនៅក្នុងជាលក្ខណៈគ្រួសារ ដើម្បីសួររកមូលហេតុពេលហ្នឹង ខ្ញុំមិនបានដឹងថា តើកងឈ្លបហ្នឹងគេត្រួតពិនិត្យ ឬក៏គេលបស្តាប់ពីអង្កាល់មកទេ។ ពេលហ្នឹងផ្ទះខ្ញុំហ្នឹងនៅក្រោមដើមដូង ៗហ្នឹង បងស្រីខ្ញុំថា ក្តិបដូងធ្លាក់។ ហើយខ្ញុំក៏លាន់មាត់ថា វាមិនដែលក្តិបដូងអាណាធ្លាក់ចំចំហៀងផ្ទះតែធ្លាក់ ធ្លាក់ចំដំបូលហើយ។ ព្រោះផ្ទះវានៅក្រោមដំបូល អ៊ីចឹងបែបប្រហែលជាមានសភាពការណ៍មិនសូវស្រួលហើយ។ អ៊ីចឹងឈប់និយាយ ឈប់ស្តីនាំគ្នារកន្លែងដេក។ ពេលហ្នឹងក៏ខ្ញុំដាក់ទិសដៅអ៊ីចឹងទៅក៏វាថា បែកគ្នាកុំឲ្យគេសង្ស័យថា យើងវាពាក់ព័ន្ធជាកូនទាហាន លន់ នល់ លន់អី ដែលពីកន្លងទៅនេះ គេឆែករូបថតរូបអីឃើញនោះ។

[០៩:២៧:៥១]

បាទ ខ្ញុំក៏បានឲ្យជាមតិប៉ុណ្ណឹងហើយ ខ្ញុំក៏ប្រាសខ្លួន រកកន្លែងប្រាសខ្លួនរៀងៗខ្លួនសំងំទៅ។ បាទ ខ្ញុំនៅចាំបានប៉ុណ្ណឹង។

**ស៖** លោកបានលើកឡើងថា ក្រោយពីឪពុករបស់លោកត្រូវគេយកទៅសម្លាប់ ក្រុមគ្រួសាររបស់លោកហ្នឹងមានគេតាមឃ្លាំស្តាប់ ដោយសារតែជាប់ពាក់ព័ន្ធជាមួយនឹងក្រុមគ្រួសារ លន់ នល់។ អ៊ីចឹងក្រៅពីការតាមឃ្លាំមើលហ្នឹង តើគេមានធ្វើសកម្មភាពអ្វីផ្សេងទៀតចំពោះក្រុមគ្រួសាររបស់លោកដែរឬទេ?

**ឆ៖** បាទ មាន។ ពេលហ្នឹងក៏គេក៏ចាប់ផ្តើមប្រជុំៗ ជន១៧មេសា។ ប្រជុំ១៧មេសា ហ្នឹងឲ្យម្តាយខ្ញុំហ្នឹងទៅរៀបចំជាអីវ៉ាន់ចេញទៅលើក -- ទៅគេហៅថា ការដ្ឋាននោះ។ ប៉ុន្តែពីមុនមកមិនដឹងជា

គេហៅអី ប៉ុន្តែឥឡូវយើងហៅថា ការដ្ឋានអ៊ីចឹងទៅចុះ! ព្រោះខ្ញុំវាអត់ដែលស្គាល់ដែរ។ បាទ ទៅគេហៅទំនប់ព្រែកផ្តៅ ប៉ុន្តែឥឡូវហ្នឹងមិនដឹងជាដាក់ឈ្មោះថា បែបណាទេ។ ប៉ុន្តែទំបន់ហ្នឹងធំណាស់។ បាទ គេយកទៅដាក់នៅហ្នឹង។ ហើយប្រើឲ្យម្តាយខ្ញុំជាសរសៃខ្ចីនោះរែកដី រែកអីដូចជាមនុស្សធម្មតា មិនផ្តល់សិទ្ធិថាគាត់ជាសរសៃខ្ចី ឬមិនសរសៃខ្ចីទេ។ ពេលគាត់តវ៉ាអ៊ីចឹងទៅខាងជន១៨ ឬក៏ជាកងឈ្លបហ្នឹងគេថា អ្នកនៅកម្មសិទ្ធិក្រាស់ឃ្លីកណ៎ះ គ្មានប៉ានលះបង់អ្វីជូនអង្គការទេ ហ្នឹង។ តែខ្ញុំដូចពេលហ្នឹងប្លែកដែរ ឮអង្គការ ដឹងមួយណាដឹងមុខអាម៉េចទៅអង្គការ ហើយខ្ញុំចេះតែចាំរកមើលដែរ តែរកមិនឃើញរហូតដល់សព្វថ្ងៃ។ បាទ ខ្ញុំចាំបានប៉ុណ្ណឹង។

[០៩:៣០:០៨]

**ស៖** លោកថា ម្តាយលោកសរសៃរខ្ចី តើពេលនោះគាត់ទើបតែសម្រាលកូនឬក៏យ៉ាងម៉េច? ហើយបើសម្រាលកូន តើបានរយៈពេលប៉ុន្មានដែរបានគេតម្រូវឲ្យគាត់ចេញធ្វើការ? ហើយការដែលគេឲ្យគាត់ធ្វើការនុ៎ង តើការងារដែលគាត់ធ្វើហ្នឹង វាស្មើដូចគ្នាជាមួយនឹងមនុស្សសាមញ្ញធម្មតា ឬក៏ការងារហ្នឹងគេអាចធ្វើការសម្រាលដល់គាត់ដែរ?

**ឆ៖** បាទ ម្តាយខ្ញុំហ្នឹងសម្រាលកូនបាន៣ខែ ៗគេប្រើគាត់ហ្នឹងឲ្យកាប់ដីរែកទំនប់ហ្នឹង បើតាមខ្ញុំប៉ាន់ស្មានមើលឥឡូវទៅប្រហែលជាខ្ពង់ជាង១០ម៉ែត្រ ដែលមានជើងទេរ គិតពីជើងទេរទៅជាង១០ម៉ែត្រ ហើយប្រើដូចមនុស្សសាមញ្ញ ដូចជាមនុស្សធម្មតា ព្រោះជំនាន់ហ្នឹង គេមិនគិតថា អ្នកសរសៃខ្ចី សរសៃចាស់ សរសៃរបៀបណាទេ។ ព្រោះគេផ្តោតសំខាន់លើមនុស្សទូទៅ។ ខ្ញុំផ្តោតសំខាន់លើប៉ុណ្ណឹង ហើយម្តាយខ្ញុំហ្នឹង ខ្ញុំបញ្ជាក់អះអាងថា ម្តាយខ្ញុំសរសៃខ្ចីក៏ក្រោយហ្នឹង គាត់បានឆ្លងទន្លេបាន៣ខែហ្នឹង ប្អូនខ្ញុំមួយត្រូវស្លាប់ៗ។

[០៩:៣១:៣៣]

ហើយដល់ពេលប្អូនខ្ញុំដែលត្រូវស្លាប់ហ្នឹង បើតាមយើងគិតពីជំនាន់មុន ហើយមកជំនាន់ហ្នឹង គឺវាខុសគ្នាសឹងតែថា ដូចមេឃ និងដី។ ស្លាប់ជំនាន់មុន យើងមានលោកមានអី បង្សុកូល សូត្រ ត្រឹមត្រូវ។ ដល់ពេលជំនាន់ហ្នឹង គឺស្លាប់ដូចសត្វ ដូចធាតុអ៊ីចឹង។ តែស្បូវតែក្រណាត់ កន្ទប ឬក៏អ្វីដែលត្រូវវេចត្រូវខ្ចប់យកទៅដាក់នៅក្នុងដី គឺអត់មានទេ។ បាទ មានតែស្លឹកដូង ឬក៏ស្រទបស្លាអីតែប៉ុណ្ណឹង ដែលជំនួសឲ្យនៃការគេហៅថា មឈូសអ៊ីចឹង។ តែខ្ញុំនឹកឃើញ សោកស្តាយណាស់។ ខ្ញុំបានធ្វើរៀបរាប់បានប៉ុណ្ណឹង។

**ស៖** សូមអរគុណ។ ខ្ញុំសូមបន្តសំណួរទៀត ក្រោយពី ក្រៅអំពីការសម្លាប់ឪពុករបស់លោក តើលោកមានបានសង្កេតដែរឬទេ មាននៅក្នុងតំបន់ដែលលោករស់នៅហ្នឹងមានការធ្វើការតាមដាន និង រុករកទៅលើទាហាន លន់ នល់ ដូចជាករណីឪពុកលោកដែរឬទេ?

[០៩:៣២:៤៥]

**ឆ៖** បាទ មាន១ នៅពេលគេហៅថា អង្គប្រជុំនោះ។ បាទ មាន១ ហើយអំពាវនាវតាមរយៈប្រធានភូមិ។ ប្រធានភូមិហ្នឹង ឈ្មោះប្រធានភូមិ នៅ។ គាត់បានអំពាវនាវ គាត់ថាបងប្អូន ជន១៧មេសាហ្នឹង ពីជំនាន់មុនធ្វើអីណា? អ៊ីចឹងទេ អាចមកចុះឈ្មោះបាន តាមមកដល់ផ្ទះខ្ញុំមក ខ្ញុំនឹងចុះឈ្មោះ ហើយខ្ញុំនឹងបញ្ជូនទៅអង្គការ។ ឲ្យអង្គការគេយកទៅធ្វើការនៅថ្នាក់លើ១។ ឮអំពាវនាវ អ៊ីចឹង។ ចុងក្រោយមក ឃើញមានមនុស្សទៅចុះឈ្មោះដែរ ក៏ប៉ុន្តែខ្ញុំមិនបានរាប់ចំនួនថា បានប៉ុន្មាននាក់ប្រុសប៉ុន្មាន ស្រីប៉ុន្មានទេ ខ្ញុំអត់បានដឹងទេ។ ក៏ប៉ុន្តែឮជួបគ្នាទៅ ពិភាក្សាពេលដែលដើរទៅធ្វើការងារហ្នឹងទៅ "អ៊ី បានទៅចុះឈ្មោះនៅ? អ្អឺ! ឯងទៅចុះមុនទៅ។ បើថាចាំម៉េច១ ចាំអញចុះទៅតាមក្រោយ។ ឲ្យអ្អែងទៅមុនសិនទៅ"។ អាហ្នឹងដូចថារបៀបការសង្ស័យគ្នា ខ្លាចទៅមិនដល់គោលដៅអ៊ីចឹង។ ហើយខ្ញុំនៅបាន ឮចាំតែប៉ុណ្ណឹងទេ។

**ស៖** តើនៅក្នុងតំបន់ដែលលោកបានរស់នៅហ្នឹង លោកមានបានសង្កេតដែរឬទេ តើពេលហ្នឹង មានប្រជាជនស្លាប់ដែរឬទេ? ហើយបើមានតើគាត់ស្លាប់ដោយសារមូលហេតុអ្វី?

[០៩:៣៤:៤៨]

**ឆ៖** នៅក្នុងភូមិរបស់ខ្ញុំហ្នឹង តាមបើខ្ញុំដឹងគឺមានអ្នកស្លាប់ ស្លាប់ដោយសារ ទី១ ហូបមិនឆ្អែត។ ទី២ ធ្វើការហួសកម្លាំង ធ្លាក់ខ្លួនឈឺ គ្មានថ្នាំព្យាបាល។ ទី៣ហ្នឹង ឃើញថាវា ដូចគេហៅថា ពីសម័យហ្នឹងដូចគេថាហៅ ក្បត់អង្គការ។ ក្បត់អង្គការ ដូចជាដើរលួច លួចស្រូវលួចអី យកមកលីងបុក ដើម្បីចម្អែតក្រពះ។ ដល់គេតាមទាន់ គេចាប់វ៉ៃសម្លាប់ចោលអីអ៊ីចឹង។ បានខ្ញុំបានឃើញ ហើយខ្ញុំក៏បានភ្លាត់ស្នៀតទៅលួចដែរ លួចស្រូវគេដែរ។ បាទ ដេក១ ពេលហ្នឹងរកអីមិនឃើញ ដេកលើភ្លឺស្រែ បូតទំពាស្រូវហ្នឹងតែម្ដង បាទ ដល់ដេកទំពាស្រូវ។ ដល់ថ្ងៃមួយហ្នឹង ខាងជន១៨ ហ្នឹង គេឃើញ "អីយ៉ាស់! ដានជើងមនុស្ស! តែអាចម៍ជ្រូក"។ គេចាប់អារម្មណ៍ត្រង់ហ្នឹងទៀត ថ្ងៃក្រោយរត់ចូលព្រៃ មិនឲ្យគេឃើញទេ លែងដុះនឹងវាល ព្រោះខ្លាចអ៊ីចឹង។ គេថាចាំឃ្លាំមើល បើសេកស៊ីដាច់ទាំងក្ដួរហើយ គេថាបើសិនជាសត្វសេក សត្វកណ្ដុរស៊ីដាច់ទាំងក្ដួរហើយ ចុះអានេះស្នាមបូត។ ហ្នឹងគេតាមដានរហូត

ដល់ពីពេលហ្នឹងមក។ ហើយខ្ញុំក៏ចេះតែ មុននឹងចេញទៅណាមកណា មុននឹងដើរលួចដើរអីគេហ្នឹង មើលឆ្វេងមើលស្តាំដែរ ព្រោះខ្លាចដែរសេចក្តីស្លាប់។ ព្រោះស្លាប់ហ្នឹងមិនមែនជាស្លាប់ដោយដូចសម័យបច្ចុប្បន្នទេ ស្លាប់នោះស្លាប់ដោយវេទនាជាទីបំផុត។ បាទ ព្រោះត្រូវការហ្នឹង គេដាក់ទោសទណ្ឌអារនឹងធាងត្នោតក៏មានដែរ។ គេអារម្តងបន្តិចៗ ទម្រាំនឹងដាច់ខ្យល់ ឈឺណាស់ ខ្ញុំជឿថាឈឺណាស់។ ទុកជាខ្លួនស្គមស្គាំងប៉ុណ្ណឹងក៏នៅតែដឹងថាខ្លួនឈឺដែរ។ បាទ ខ្ញុំនៅចាំបានប៉ុណ្ណឹង។

[០៩:៣៦:៤១]

**ស៖** សូមអរគុណ។ អម្បាញ់មិញលោកតែងតែលើកអំពីការតាមដាន និងការអង្កេតសកម្មភាពរបស់ប្រជាជន។ តើពេលដែលគេធ្វើការតាមដាន និងអង្កេតសកម្មភាពប្រជាជននុំង តើមានបានសង្កេតដែរឬទេ ថាតើអ្នកដែលត្រូវគេតាមដាន និងអង្កេតនោះ គឺជាពួក១៧មេសា ឬក៏ជាពួកមូលដ្ឋានចាស់?

**ឆ៖** បាទ ពេលហ្នឹងខ្ញុំឃើញមានជាកងឈ្លបដាក់បណ្តាញ អាហ្នឹងគេហៅថា ដាក់បណ្តាញ។ ដាក់បណ្តាញតាម គឺថាតាមរុករកៗ ជាមួយជន១៨ ឧបមាថាឃើញថា ខ្ញុំអីចំណាំទៅចេញចូលផ្ទះ១៨ យករបស់យកអីទៅដូរ ហើយយកមកសម្រាប់បានអាទទួលទានហ្នឹង គឺហ្នឹងគេដាក់បណ្តាញគេស៊ើបអង្កេតហើយ។ ស៊ើបអង្កេត គេថាមិនអីទេ កាលពីមុនធ្វើស្អីធ្វើអីហ្នឹង អ្នកឯងឆ្លើយប្រាប់មក ខ្ញុំនឹងឲ្យបាយមួយឆ្អែត ខ្ញុំនឹងឲ្យដំឡូង ឲ្យជាសាច់ ជាអីទៅណ៎ះ កុំបាច់ខ្លាចចិត្ត ខ្លាចក្រែងអី យើងដូចជាគ្រួសារតែមួយ។ ពេលហ្នឹងខ្ញុំដូចឃើញថា ម្តាយខ្ញុំហ្នឹងបានទៅដូរជារបស់យកមកទុកហូប ដល់ពេលហើយក្រោយមកខ្ញុំថា ខ្ញុំក៏មិនជាអ្នកដឹងក្តីទេ ខ្ញុំថាម៉ែ ម៉ែទៅត្រង់ណា ម៉ែកុំមាត់ ឲ្យស្ងៀមណ៎ា ព្រោះកន្លងទៅយើងបាត់ឪពុកមួយហើយ ហើយចុះបើសិនជាថ្ងៃក្រោយទៅទៀតខ្ញុំបាត់បង់ម្តាយទៀត តើឲ្យខ្ញុំហ្នឹងរស់ទីពឹងអ្នកណា បើសព្វថ្ងៃ។ ហើយខ្ញុំបានដឹងតែប៉ុណ្ណឹងទេ។

[០៩:៣៨:៣០]

**ស៖** សូមអរគុណ។ នៅក្នុងអំឡុងពេលដែលលោករស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទាំងមូល តើលោកមានដែលធ្លាប់ឮឈ្មោះលោក ប៉ុល ពត, លោក នួន ជា, លោក អៀង សារី, លោក ខៀវ សំផន ដែរឬទេ? ហើយបើសិនជាធ្លាប់ឮ តើធ្លាប់ឮនៅកន្លែងណា? លោកចាំបានដែរឬទេ?

**ឆ៖** ពេលហ្នឹងប្រហែលជាបាយថ្ងៃល្ងាចហើយ ដែលខ្ញុំមិនចាំពេលវេលាទេ ហើយឃើញ មិនមែនជាប្រធានភូមិទេ ឮនិយាយតមាត់ពីមួយទៅមួយ ដែលនៅក្នុងរោងបាយហ្នឹង។ គេថា យប់ហ្នឹងគេបញ្ចាំងកុន នៅភូមិស្រះចក ស្រុកឈ្មូក ខេត្តកំពត អីចឹងធ្វើដំណើរហ្នឹងប្រហែលជាជិត១២គីឡូ បើតាម

ខ្ញុំស្មានមើល។ បាទ ដើរ អ្នកខ្លះដើរ អ្នកខ្លះជិះរទេះគោ គេមានរទេះគោគេជិះទៅ អ្នកអត់ទៅ ដើរទៅ។ ខ្ញុំឃើញបានគេបញ្ចាំងកុនមែន ក៏ប៉ុន្តែបញ្ចាំងកុនហ្នឹងខ្ញុំអង្គុយពីទ្រង់ឆ្ងាយដែរ មើលវាអត់សូវច្បាស់ទេ ឃើញមិនសូវច្បាស់ តែឮអ្នកបកប្រែ គេហៅថាអ្នកបញ្ចូលសំឡេងកុននោះបាទ។ គេថានេះហើយជាឈ្មោះអីអីចេះៗអីចឹង ហើយណាមួយវា ដូចថា ប្រើអារម្មណ៍ឲ្យស្ដាប់វាមិនសូវបានច្បាស់ មូលហេតុដោយសារកន្លែងហ្នឹង ឮមាត់ៗច្រើនពេក។ ឮមាត់ឲ្យជៀវដូចផ្សារលក់ត្រីអីចឹង។ អីចឹងហើយស្ដាប់វាអត់សូវបានច្បាស់ពិតប្រាកដ អីចឹងបានខ្ញុំមិនប៊ានអះអាងថា។

**ស៖** អីចឹងនៅក្នុងខ្សែភាពយន្តកុនហ្នឹង លោកមានបានចាំទេ តើគេបញ្ចាំងពីអីគេដែរពេលនុ៎ង?

**ឆ៖** ខ្ញុំអត់បានចាំថាគេបញ្ចាំងហ្នឹងបញ្ចាំងអំពីអ្វីមួយ ដើម្បីធ្វើអីមួយទេ ខ្ញុំអត់បានដឹងទេ គ្រាន់តែដឹងថា គេបញ្ចាំងហ្នឹងគឺនិយាយអីចឹង ទាន់ត្រង់មួយឃ្លាថា "អីចឹងប្រទេសជាតិយើងបានរំដោះរួចផុតទុក្ខទោស ពីនឹមចក្រពត្តិ –ហើយខ្ញុំហ្នឹងអត់ដែលឮទេ សូម្បីតែរៀនក៏ខ្ញុំអត់ដែលឮថានឹមចក្រពត្តិរបៀបម៉េចទេ– អីចឹងទេ យើងនឹងខំកសាងប្រទេស"។ ហើយខ្ញុំស្ដាប់បានតែប៉ុណ្ណឹងទៅ ដូចវាគ្មានសាច់រឿងអីឲ្យគួរមើលទៅ ខ្ញុំក៏ដូចថា វាអស់កម្លាំងពីធ្វើការធ្វើអីផង ខ្ញុំក៏ដេកលក់កន្លែងកុនហ្នឹងទៅ។ ដេកលក់នៅកន្លែងទីលានបញ្ចាំងកុនហ្នឹងទៅ។

[០៩:៤១:៤៥]

**ស៖** តើនៅក្នុងកុនហ្នឹងគេមានបញ្ចាំងអំពីអ្នកដែលខ្ញុំរៀបរាប់ឈ្មោះអម្បាញ់មិញដែរឬទេ? លោកមានបានដឹង ឬក៏ឮអីទេពេលហ្នឹង?

**ឆ៖** គ្រាន់តែបាន ខ្ញុំបានដឹង បានឮ ក៏ប៉ុន្តែវាគ្រាន់តែថា ខ្ញុំវាអត់ដែលស្គាល់ ព្រោះខ្ញុំវានៅតូចៗពេក។ បាទ មិនដែលបានស្គាល់ឲ្យច្បាស់ទេ ក៏ប៉ុន្តែគ្រាន់តែថាឮអ្នកបញ្ចូលជាភាសាកុននោះគេនិយាយទេ។ ហើយអ្នកបញ្ចូលភាសាកុនហ្នឹង ខ្ញុំមិនបានទៅឃើញមុខគេច្បាស់ផង មិនដឹងជាមានសម្បុរបែបណា អីបែបណាអត់បានទេ ព្រោះគេមិនឲ្យទៅជិតទេ។ ព្រោះបរិវេណហ្នឹងគេមិនឲ្យទៅជិតអីចឹងតែម្ដង។ ខ្ញុំបានឃើញថា គេនិយាយចូលភាសាកុនហើយ មិនដឹងជាគេហ្នឹងនៅអង្គុយកន្លែងណា អីកន្លែងណាទេ ប៉ុន្តែឃើញថាមើលទៅឃើញតែ នៅឮក្បាលមីក្រូគេនៅឯលើចងលើចុងឫស្សី។ ចុងឫស្សីឈើបង្គោលកុន។ ឃើញនៅនុ៎ង។

**ស៖** សូមអរគុណ។

**លោកស្រី ទី ស្រ៊ីនណា៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតប្រើឯកសារដែលខ្ញុំបានលើកស្នើសុំលោកប្រធានកាលពីម្សិលមិញ ដែលមានលេខ D22/1352។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត ប៉ុន្តែលោកស្រីមេធាវីបញ្ជាក់អំពីពេលវេលាបែងចែកជាមួយនឹងតំណាងសហព្រះរាជអាជ្ញា ព្រោះពេលវេលាជិតអស់ហើយ។ សូមបញ្ជាក់ឲ្យច្បាស់លាស់ពីបញ្ហានេះជាមុនសិនមុននឹងបន្តសំណួរ។

[០៩:៤៣:៤៤]

**លោកស្រី ទី ស្រ៊ីនណា៖**

សូមអរគុណលោកប្រធាន ហើយនេះជាសំណួរចុងក្រោយរបស់ខ្ញុំ ហើយខ្ញុំនឹងផ្ទេរវេទិកានេះជូនដល់ខាងលោកសហព្រះរាជអាជ្ញាបន្តសំណួរទៀត។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ!

**សួរដោយលោកស្រី ទី ស្រ៊ីនណា៖**

**ស៖** ឯកសារដែលខ្ញុំបម្រុងនឹងប្រើគឺមានលេខERN ជាភាសាខ្មែរ 00526168, ហើយភាសាអង់គ្លេសមានលេខ 00866008, ចំណែកភាសាបារាំងខ្ញុំពុំមានជាភាសា -- ឯកសារនេះពុំមានបកប្រែជាភាសាបារាំងនោះទេ។ “នៅអំឡុងពាក់កណ្តាលឆ្នាំ១៩៧៨ គ្រួសាររបស់ខ្ញុំដែលមានសមាជិកប្រាំនាក់ គឺម្តាយខ្ញុំម្នាក់ បងប្អូនបង្កើតរបស់ខ្ញុំបីនាក់ និងបងស្រីជីដូនមួយខ្ញុំ អ៊ំម៉ុមម្នាក់ រួមជាមួយប្រជាពលរដ្ឋដទៃជាច្រើនគ្រួសារទៀត គឺភាគច្រើនសុទ្ធតែគ្រួសារ ដែលមានសមាជិកប្តី ឬឪពុកត្រូវគេយកទៅសម្លាប់។ ត្រូវអង្គការខ្មែរក្រហមបញ្ជូនឲ្យទៅនៅឯខេត្តពោធិ៍សាត់វិញ គឺនៅក្នុងសហករណ៍ឃុំតាឡូហាទិល ក្នុងស្រុកបាកាន។ នៅទីនោះស្ថានភាពរស់នៅកាន់តែលំបាកទ្វេឡើង ជាពិសេសអាហារហូបចុក គឺបានហូបតែបបររាវៗបន្តិចបន្តួចប៉ុណ្ណោះក្នុងមួយពេលៗ”។ អ៊ីចឹងចំណុចដែលខ្ញុំចង់បញ្ជាក់ជាមួយលោកនោះ គឺលោកបានលើកឡើងថាក្រុមគ្រួសារភាគច្រើនសុទ្ធតែគ្រួសារដែលមានសមាជិកប្តីឬឪពុកត្រូវគេយកទៅសម្លាប់។ អ៊ីចឹងចំណុចនេះ ខ្ញុំចង់បញ្ជាក់ជាមួយលោកថា តើក្រុមគ្រួសារដែលភាគច្រើនត្រូវជាប្តី ឬក៏ឪពុកត្រូវគេយកទៅសម្លាប់នោះ ជាក្រុមគ្រួសាររបស់ខាងក្រុម១៧មេសា ឬក៏

ជាក្រុមគ្រួសាររបស់ខាងមូលដ្ឋានលាយឡំគ្នា ឬក៏យ៉ាងម៉េចដែរ? សូមលោកជួយបំភ្លឺត្រង់ចំណុចនេះ។

[០៩:៤៦:០៧]

**ឆ៖** បាទ ក្រោយពីក្រុមគ្រួសារដែលសល់ពីគេសម្លាប់ពីអីហ្នឹង ឃើញថាខ្ញុំចាកចេញពីស្រុកកំណើត ខេត្តកំពតហ្នឹង ទៅនៅកាន់ពោធិ៍សាត់ហ្នឹង ភាគច្រើនជន១៨ ហ្នឹង គេបានមានជាមធ្យោបាយធ្វើដំណើរដោយឡាន បាទដោយឡាន ដោយជន១៧មេសាហ្នឹង មានជាអម្រែក។ ដូចជារូបខ្ញុំ ដូចជាបងស្រីខ្ញុំហ្នឹង គាត់ជាអ្នករែក។ បាទ គាត់ជាអ្នករែក រែកតាមកាត់យើង នេះចុះមកតាមយើង ផ្លូវជាតិលេខ ៣ ដោះកញ្ចរនេះ ត្រែងត្រយឹង ឡើងទៅជ្រិះស្រងាំជ្រុំជួរភ្នំក្រវាញកណ្ដាល តាមផ្លូវឡានពីសង្គមចាស់ ឡានដែលគេទៅកាប់ឈើ ដែលខ្ញុំចាំមិនភ្លេចទេ ដែលខ្ញុំនៅចាំផ្លូវហ្នឹង ឡើងទៅស្នាក់នៅ ម្តុំហ្នឹង។ ពេលហ្នឹងឃើញថា ម្តាយ ហើយនិងប្អូនខ្ញុំដែលនៅតូចៗហ្នឹងអស់ជើងហើយ គេឲ្យបានឈប់ឡាន ហ្នឹង គេហៅថាកូនចៅ តាម៉ុកៗ ឮតែឈ្មោះទេ ប៉ុន្តែមិនដែលឃើញរូបរាងរបៀបម៉េចទេ។ ឃើញថាឈប់ឡានឲ្យជិះ ឡានហ្នឹងខ្ញុំនៅចាំម៉ាកទៀត។ ឡានហ្នឹង ឡានរបស់ចិន ខ្ញុំអត់ចេះអានអក្សរចិនទេ ក៏ប៉ុន្តែអង្គាល់ម៉ារីកខ្ញុំចូលធ្វើទាហានហ្នឹង គេបានឲ្យឈ្មោះថាឡានហ្នឹង ឈ្មោះ ទង់រឹង បាទ កង់ប្រាំមួយ--

[០៩:៤៧:៤២]

**ស៖** អត់ទោសលោក ខ្ញុំសូមបញ្ជាក់សំណួរខ្ញុំឡើងវិញ ក្រែងលោកាលដែលខ្ញុំសួរទៅមានការមិនច្បាស់លាស់។ ខ្ញុំសូមធ្វើការបញ្ជាក់ ព្រោះនៅក្នុងកន្លែងនេះលោកបានលើកឡើងថា គ្រួសាររបស់លោករួមជាមួយប្រជាពលរដ្ឋដទៃជាច្រើនគ្រួសារទៀត គឺភាគច្រើនសុទ្ធតែគ្រួសារដែលមានសមាជិកប្ដី ឬឪពុកត្រូវគេយកទៅសម្លាប់។ អ៊ីចឹងខ្ញុំគ្រាន់ចង់បញ្ជាក់ជាមួយលោកថាតើក្រុមគ្រួសារដែលភាគច្រើននោះ ដែលត្រូវ -- ដែលមានសមាជិកប្ដី ឬក៏ឪពុកត្រូវគេយកទៅសម្លាប់ហ្នឹង គឺជាក្រុមគ្រួសារមករបស់ខាង១៧មេសា ឬជាក្រុមគ្រួសាររបស់ខាងមូលដ្ឋាន? លោកៗមានចាំដែរឬទេ ថាជាប្រភេទក្រុមគ្រួសារមកពីខាងពួកខាងណាដែរ? លោកដឹងដែរឬទេ? បើសិនជាលោកដឹង សូមឆ្លើយថាដឹង ហើយនិងរៀបរាប់ តែបើសិនជាអត់ដឹង សូមលោកអាច -- បើសិនជាអត់ដឹង លោកអាចឆ្លើយតាមអ្វីដែលលោកបានដឹង ឬក៏មិនដឹង។ សូមអរគុណ។

[០៩:៤៨:៤៩]

**ឆ៖** បាទ ពេលហ្នឹងខ្ញុំនៅបានចាំដឹងតិចៗទេ ក៏ប៉ុន្តែរៀបរាប់ហ្នឹងវាមិនបានឲ្យបានក្បោះក្បាយទេ ជនហ្នឹង ជន១៧មេសា ក្រោយពីសល់គេសម្លាប់ទេ ដែលធ្វើដំណើរលាយលំគ្នាជាមួយក្រុមគ្រួសារខ្ញុំ

ហ្នឹង។ លាយលំជាក្រុមគ្រួសារខ្ញុំហ្នឹង មានអ្នកខ្លះរ៉ែក មានអ្នកខ្លះទូលណ៌ា ទូលធ្វើដំណើរ --

**ស៖** អ៊ីចឹងមានន័យថាគាត់ជាក្រុម១៧មេសា អ៊ីចឹងមែនឬ?

**ឆ៖** បាទ ព្រោះពេលហ្នឹង ១៨មេសា គេមានរថយន្តជិះ។

**លោកស្រី ទី ស្រ៊ីនណា៖**

អ៊ីចឹងខ្ញុំសូមអរគុណចំពោះការឆ្លើយដោយក្បោះក្បាយរបស់លោក ហើយនិងសូមអរគុណលោកប្រធាន ហើយនិងសូមផ្ទេរវេទិកានេះជូនទៅខាងលោកសហព្រះរាជអាជ្ញា ដើម្បីតាំងសំណួរបន្ត។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសក្នុងការសួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

[០៩:៤៩:៥៤]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ អរុណសួស្តីលោក លោកស្រីចៅក្រម ភាគី។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** សូមអរគុណលោក គឹម វ៉ាន់ឌី ដែលលោកអញ្ជើញមកទីនេះដើម្បីជម្រាបអំពីការឈឺចាប់របស់ៗគ្រួសាររបស់លោក។ ខ្ញុំឈ្មោះ ថារីក អាប់ឌុលឡាក់ ខ្ញុំមានសំណួរសួរបន្តមួយចំនួនតែប៉ុណ្ណោះក្នុងនាមស្ថាប័នសហព្រះរាជ -- ការិយាល័យសហព្រះរាជអាជ្ញា។ ខ្ញុំគ្រាន់តែចង់បញ្ជាក់ឲ្យបានច្បាស់ថាតើយើងបានយល់ពីលោកត្រឹមត្រូវដែរឬទេ? តើលោកនៅទីណាដែរនៅថ្ងៃទី១៦, ១៧ ខែមេសា ឆ្នាំ៧៥? ដោយសារតែពេលវេលា ខ្ញុំនឹងអានសង្ខេបតាមចម្លើយរបស់លោកដែលខ្ញុំស្តាប់យល់កាលពីម្សិលមិញ ហើយលោកធ្វើការកែតម្រូវខ្ញុំ ប្រសិនបើខ្ញុំសង្ខេបចម្លើយរបស់លោកខុស។

[០៩:៥០:៥០]

លោកនិយាយថា "លោករស់នៅជ្រោយចង្វា ជិតជ្រោយចង្វានៅក្នុងស្រុកមុខកំពូល។ គឺស្រុកមុខកំពូលនេះ គឺនៅជិតទីក្រុងភ្នំពេញ បានន័យថាវានៅក្បែរម្តុំៗជ្រោយចង្វា តាមដែលខ្ញុំយល់នោះ។ នៅថ្ងៃទី១៦ ខែមេសា លោក និងគ្រួសាររបស់លោកបានឆ្លងស្ពានមកទីក្រុងភ្នំពេញទៅផ្ទះអ៊ំរបស់លោក

នៅសន្ធរម៉ុក។ ហើយនៅថ្ងៃទី១៧ ពេលព្រឹកលោកក៏បានឃើញខ្មែរក្រហម -- ទាហានខ្មែរក្រហមដើរចូលសំដៅមកទីក្រុងភ្នំពេញ”។ តើអ្វីដែលខ្ញុំសង្ខេបនេះត្រឹមត្រូវតាមអ្វីដែលលោកឆ្លើយដែរឬទេ? ហើយសូមឲ្យលោកជួយបញ្ជាក់ជូនខ្ញុំ។ សូមអរគុណ។

**លោក គីម វ៉ាន់ឌី៖**

**ឆ៖** បាទ គ្រាន់តែដែលលោកបានបញ្ជាក់ថាហ្នឹងគឺត្រឹមត្រូវហើយ ក៏ប៉ុន្តែបើគ្រាន់តែថា ខ្ញុំថាខ្ញុំចង់ជួយកែថា ផ្ទះខ្ញុំហ្នឹងនៅត្រើយខាងនៃទន្លេទេ។ បាទ ម្ខាងនៃទន្លេ។ បាទ ប៉ុណ្ណឹងទេបាទ។

**ស៖** សូមអរគុណច្រើន។ វាជាគុណប្រយោជន៍សម្រាប់ខ្ញុំណាស់ ចំពោះអ្នកដែលមិនស្គាល់ទីតាំងភូមិសាស្ត្រទីក្រុងភ្នំពេញ។ ប្រសិនបើយើងនិយាយអំពីសន្ធរម៉ុក តំបន់សន្ធរម៉ុកនេះឲ្យបានច្បាស់ តើសន្ធរម៉ុកនេះគឺជាតំបន់មួយនៅក្នុងទីក្រុងភ្នំពេញជិតផ្លូវសហព័ន្ធរុស្ស៊ី ហើយនិងជិតទួលគោកហ្នឹង តើមែនដែរឬទេ?

[០៩:៥២:៤៦]

**ឆ៖** បាទ តាមពិតដូចជាអត់ទេ សន្ធរម៉ុកហ្នឹងដូចជានៅជួរផ្លូវកម្ពុជាក្រោម បើតាមខ្ញុំដឹងពីឥឡូវទេ។

**ស៖** សូមអរគុណច្រើន។ នៅពេលនេះ ខ្ញុំសូមលើកឡើងអំពីហេតុការណ៍ដែលលោកបានលើកឡើងកាលពីម្សិលមិញ ដោយខ្លីៗវិញម្តង គឺការសម្លាប់អ៊ំរបស់លោក។ តាមការកត់ត្រានៅក្នុងកំណត់ហេតុរបស់ខ្ញុំនោះគឺថា លោកនិយាយថា “អ៊ំរបស់លោកស្លៀកពាក់ខោអាវទាហានក្នុងពេលដែលគេបាញ់សម្លាប់គាត់នោះ”។ ហើយលោកបាននិយាយថា “លោកបើកទ្វារចេញមក ហើយលោកឮសំឡេងគេបាញ់អ៊ំរបស់លោក”។ តាមលោកដឹង តាមការសង្កេតរបស់លោក តើអ៊ំរបស់លោកនៅក្នុងពេលនោះៗមានចូលរួមវាយប្រយុទ្ធជាមួយនឹងខ្មែរក្រហមដែរឬទេ? និយាយឲ្យជាក់លាក់ ខ្ញុំចង់សួរថាតើគាត់នោះមានកាំភ្លើង មានកាន់កាប់កាំភ្លើង ហើយមានធ្វើការប្រយុទ្ធបាញ់តទល់ជាមួយនឹងខ្មែរក្រហមដែរឬទេ?

**ឆ៖** បាទ ដែលខ្ញុំបានដឹង បានឃើញហ្នឹងគឺ ខ្ញុំ -- ពេលដែលគាត់ចេញទៅបន្ទាយរបស់គាត់ហ្នឹង ខ្ញុំមិនដឹងថាគាត់ទៅប្រយុទ្ធទៅអីណាទេ។ បើតាមទៅកន្លងទៅ មិនទាន់ខ្មែរក្រហមវៃចូលដល់ទីក្រុងភ្នំពេញហ្នឹងគឺគាត់បាននិយាយប្រាប់ជាគ្រួសារកូនចៅគាត់ ហើយលេចឮដល់រឿងខ្ញុំហ្នឹងថា “គាត់មានឋានៈប៉ុណ្ណឹងមិនចេញប្រយុទ្ធទេ គ្រាន់តែដាក់បញ្ជាឲ្យទៅគេទេ។ បាទ ដាក់បញ្ជាឲ្យទៅគេក្រោមៗ

ឱវាទនៃរបស់គាត់"។ បាទ ពេលហ្នឹងឃើញថា គាត់មិនបានទៅប្រយុទ្ធទៅអីទេពេលមុនគាត់ស្លាប់ហ្នឹង គឺគាត់បានបើកឡាន អាហ្ស៊ីបអាជី របស់អាមេរិកាំង ហើយឯកសណ្ឋានជាប៉ាវ៉ាហ្នឹង។ បាទ ហើយក្រោយមកឃើញថា ទាហានខ្មែរក្រហមហ្នឹងបានបាញ់គាត់តែម្តង បាញ់គាត់ស្លាប់។ ប៉ុណ្ណឹងបាទ។

**ស៖** សូមអរគុណលោកច្រើន។ ខ្ញុំមានសំណួរមួយ ឬក៏ពីរទៀតលើបញ្ហាហ្នឹងចង់សួរទៅកាន់លោក។ តាមអ្វីដែលខ្ញុំយល់ច្បាស់លាស់ និងអ្វីដែលកើតឡើងនៅថ្ងៃ១៧ ខែមេសា នោះ គឺថាក្រៅពីការសម្លាប់អ៊ំរបស់លោក តើលោកមានបានឃើញការវាយប្រយុទ្ធគ្នាបានកើតឡើងនៅកន្លែងណាផ្សេងដែរឬទេ? ឬក៏ទាហានខាងរបស់ លន់ នល់ នោះគឺឈប់មានការបាញ់ប្រយុទ្ធតតាំងជាមួយខ្មែរក្រហមរួចទៅហើយនៅក្នុងថ្ងៃ១៧មេសានោះ?

[០៩:៥៦:១៤]

**ឆ៖** បាទ មុនចូលដល់ថ្ងៃ១៧មេសា នុ៎ង គឺថ្ងៃ១៦មេសា ខ្ញុំឃើញទាហាន លន់ នល់ បានវ៉ៃជាមួយទាហានខ្មែរក្រហម សន្ធឹកណាស់ថ្ងៃចុងក្រោយហ្នឹង វ៉ៃសន្ធឹកគ្រប់មុខព្រួញទាំងអស់។ តាំងពីកន្លែងព្រលានយន្តហោះ តាំងពីជ្រោយចង្វាដែលក្បែរៗផ្ទះខ្ញុំហ្នឹងឃើញវ៉ៃសន្ធឹកមែនទែន វ៉ៃគ្រប់មុខព្រួញធ្វើឲ្យ -- ដល់ពេលស្ងប់គ្រាប់ផ្លោង ខ្ញុំក៏បានចាកចេញពីផ្ទះខ្ញុំហ្នឹងទៅសន្ធរម៉ុកហ្នឹង។ ស្អែកឡើងថ្ងៃ១៧មេសា ហ្នឹងគ្មានឃើញប្រយុទ្ធអីទេ ក៏ប៉ុន្តែវាគ្រាន់តែឃើញជាលក្ខណៈកាំភ្លើងហ្នឹងឮសូរប៉េះប៉ោះបន្តិចបន្តួចតែប៉ុណ្ណឹង ប៉ុន្តែមិនដឹងជានៅចំណុចណាៗ ខ្ញុំអត់ប៉ានដឹង ហើយអត់ប៉ានចេញ ខ្លាចត្រូវ។

**ស៖** សូមអរគុណ។ ដោយសារតែពេលវេលាខ្លី ខ្ញុំសូមបន្តសួរលោកសំណួរបីបួនទៀត លើប្រធានបទផ្សេងវិញម្តង។ នៅពេលដែលលោករៀបរាប់អំពីការផ្លាស់ប្តូរទីកន្លែងរបស់ -- គ្រួសាររបស់លោកដំបូងគឺ ចាកចេញពីខាងជើងជ្រោយចង្វា ហើយក្រោយមកលោកបានរៀបរាប់ថា គ្រួសាររបស់លោកបានត្រឡប់ទៅទិសខាងត្បូងទៅកំពត។ ហើយនៅតំបន់ឧដុង្គនោះ គឺថាលោកបានស្នាក់នៅកន្លែងផ្សារឧដុង្គនោះក៏២ ឬក៏៣ថ្ងៃផងដែរ។ តើលោកអាចពន្យល់ និងជម្រាបដោយសង្ខេបបានដែរឬទេថា តើនៅឧដុង្គនោះនៅមានប្រជាជនរស់នៅដែរឬទេតាមអ្វីដែលលោកបានឃើញ ឬក៏ពេលដែលលោកចាកចេញពីឧដុង្គនោះ លោកឃើញថាអស់មនុស្សរស់នៅទៅហើយ?

[០៩:៥៨:៣២]

**ឆ៖** បាទ ពេលហ្នឹង ខ្ញុំបន្តដំណើរចេញពីភ្នំពេញទៅកំពង់ចម្លង ឆ្ពោះទៅដល់ភូមិទួលព្រៃកក្អាមហ្នឹង ហើយក៏ត្រឡប់មកតាមហ្នឹងវិញមក ឆ្លងមកកំពង់ចម្លងឡើងទៅផ្សារឧដុង្គហ្នឹង ខ្ញុំសម្រាក

២ទៅ៣ថ្ងៃ ដើម្បីឲ្យការ គេហៅថា អស់ជើងណ៎ា អស់ជើងហ្នឹងទម្រាំបានមានកម្លាំងគ្រប់គ្រាន់នឹងបន្ត ដំណើរទៅទៀតហ្នឹង ពេលហ្នឹងឃើញខ្ញុំ -- ឃើញៗមានមនុស្ស ប៉ុន្តែខ្ញុំអត់ស្គាល់ថា មនុស្សហ្នឹងជា ជន១៨ ឬក៏ជាជន១៧ ទេ។ បាទ ឃើញមាននៅ។

**ស៖** តើលោកមានឃើញទេ? មានឃើញប្រជាជនរស់នៅក្នុងផ្ទះដូចដែលគ្រួសាររបស់លោក ធ្លាប់រស់នៅក្នុងផ្ទះនៅក្នុងទីក្រុងភ្នំពេញនៅមុនថ្ងៃ -- ១៩៧៥ តើលោកមានឃើញមនុស្សរស់នៅក្នុងផ្ទះ ដែរឬទេនៅឧដុង្គនោះ?

[០៩:៥៩:៤១]

**ឆ៖** នៅឧដុង្គហ្នឹងខ្ញុំបានឃើញមនុស្សរស់នៅ ក៏ប៉ុន្តែមនុស្សហ្នឹងជាប្រភេទលក្ខណៈដូចជា ខ្ញុំ ពិបាកសន្និដ្ឋានថាមនុស្សហ្នឹងជាអ្នកធ្វើការធ្វើអីទេ។ ក៏ប៉ុន្តែមានឃើញឯកសណ្ឋានជាពណ៌ខ្មៅ ស្លៀក ពាក់ពណ៌ខ្មៅ ស្ត្រីហ្នឹងក៏ស្លៀកពាក់ខោដែរ។ ខោអាវ មានពាក់មួកពាក់អីអីចឹងដែរ ប៉ុន្តែមិនដឹងជា សន្និដ្ឋានថា ប្រជាជន ឬក៏ជាទាហាន ព្រោះខ្ញុំអត់បានដែលដឹង។

**ស៖** សូមអរគុណ។ ខ្ញុំសូមបន្តចូលប្រធានបទមួយទៀត ដោយពិនិត្យមើលទៅលើពេលវេលា ដែលនៅសល់ខ្លី។ លោកបានពិពណ៌នាលម្អិតអំពីការចាប់ខ្លួនឪពុករបស់លោក ហើយនិងការបាត់ខ្លួន គាត់។ តើខ្ញុំអាចអនុញ្ញាតសួរលោកបានដែរឬទេ? លោកបាន ខ្ញុំគិតថា លោកបានគិតថា លោកបាន ឆ្លើយថា គាត់ជាទាហានជើងទឹកនៅក្នុងសម័យ លន់ នល់ តាមអ្វីដែលខ្ញុំយល់មិនខុសនោះ។ តើលោក ដឹងថាគាត់មានឋានន្តរស័ក្តិ ឬមានឋានៈអ្វីដែរនៅមុនឆ្នាំ១៩៧៥នោះ?

[១០:០០:៥៨]

**ឆ៖** បាទ ពីមុនឆ្នាំ៧៥ហ្នឹង ខ្ញុំបានដឹង ដឹងគាត់ហ្នឹង ជាទាហានជើងទឹកស័ក្តិ៥ ព្រោះបន្ទាយ គាត់ហ្នឹង បើខ្ញុំចាំមិនភ្លេចទេនៅវត្តភ្នំនេះ។ បាទ នៅវត្តភ្នំ បាទ ហើយគាត់ហ្នឹងបានធ្វើដំណើរទៅ ប្រទេសដទៃៗតាមជើងទឹក បាទ។ ប៉ារបស់ខ្ញុំហ្នឹងដែលបញ្ជាក់នៅក្នុងពាក្យហ្នឹងឈ្មោះថា កែម អ៊ែល ហ្នឹង។ ឋានន្តរស័ក្តិរបស់គាត់ស័ក្តិ៥ ពេលជិតដល់ខែបើកលុយ ថ្ងៃ៣០ហ្នឹង គឺគាត់ថា គាត់បញ្ជាឲ្យកូន ទាហានរបស់គាត់ហ្នឹងមកដឹកម្ដាយខ្ញុំយកទៅបើកលុយ។ ឃើញជាសព្វដងអីចឹង។

**ស៖** ប្រហែលខ្ញុំនៅសល់សំណួរមួយទៀតពាក់ព័ន្ធទៅនឹងឪពុករបស់លោក ដែលគាត់ទទួល មរណភាពហើយនេះ។ នៅក្នុងសេចក្ដីប្រកាសរបស់លោក ដែលលោកបានឆ្លើយនោះ គឺថាគាត់ត្រូវបាន ទៅយក -- ត្រូវបានយកទៅសម្លាប់នៅវត្តមួយនៅក្នុងស្រុក នៅក្នុងស្រុកឈ្មួក។ តើលោកអាចជម្រាប

បានដែរឬទេ ថាហេតុអ្វីបានជាលោកដឹង ដឹងដោយរបៀបណាដែរនៅពេលដែលគេយកគាត់ទៅសម្លាប់នៅវត្តមួយនៅក្នុងវត្តឈូកនោះ? តើវត្តអ្វីដែរ?

[១០:០២:៣៨]

**ឆ៖** ពេលដែលគេចាប់ឪពុកខ្ញុំយកទៅសម្លាប់ចោលនោះ ខ្ញុំឃើញអាប្រធានភូមិមួយឈ្មោះនៅ បានបញ្ជាក់ថា -- ខ្ញុំក៏បានសួរគាត់ "ពូ គេចាប់ប៉ាខ្ញុំយកទៅណា?"។ ដល់ពេលហ្នឹងហើយ "អ៊ូ សម័យហ្នឹងហើយ ឯ្អែងនៅហៅ ប៉ា ទៀត។ គេឲ្យហៅ ឪពុក ឬក៏ឪ"។ អ៊ូ អ៊ីចឹងខ្ញុំថា ខុស អ៊ីចឹងសូមទោសពូ អ៊ីចឹងខ្ញុំរៀនហៅ ឪវិញ។ "គេចាប់ ឪខ្ញុំហ្នឹងយកទៅណា?"។ ប្រធានភូមិហ្នឹងបានឆ្លើយប្រាប់ខ្ញុំថា "គេចាប់យកឪអ្អែងហ្នឹងទៅវត្តទួងស្គរ នៅវត្តបឹងអង្គ ស្រុកឈូក។ ព្រោះអត់មានលោក"។ គេថាអ៊ីចឹង។ ដល់ពេល ខ្ញុំក៏ ឮថាទៅវត្ត គាត់អត់អីទេ នៅរស់សុខស្រួលហើយពេលហ្នឹង។ ដល់តែពេលក្រោយមកទៀត ខ្ញុំបានទៅធ្វើជាកងចល័តលើកដីទំនប់ព្រែកផ្តៅ។ ពេលហ្នឹង គេឲ្យខ្ញុំនៅខាងសេដ្ឋកិច្ចទឹក ជញ្ជូនៗទឹកឲ្យខាងចុងភៅហ្នឹងគេដាំស្ល។ ពេលហ្នឹង ខ្ញុំក៏ឃើញ គេហៅផ្លែក្រឡាញ់ -- ផ្លែអង្កាញ់ៗ ក្រហមៗទុំ ក៏ទៅបេះ ដ៏ទៅបេះទៅ ក្រឡែតទៅឃើញខោអាវឪពុករបស់ខ្ញុំហ្នឹង គាត់ស្លៀក ចងមួយចង្កោមនៅជាប់នឹងដើមដូងហ្នឹង។ ខ្ញុំថា សន្និដ្ឋានថាច្បាស់ហើយ ច្បាស់ជាខោអាវរបស់ឪពុកខ្ញុំហើយ ព្រោះឃើញមួក ឃើញអាវ ឃើញអីហ្នឹងច្បាស់ចែស។ ដល់តែពេលក្រោយមកទៀតយប់ឡើងខ្ញុំបានវិភាគវែកញែកជាមួយម្តាយខ្ញុំ ហើយក៏លួចនិយាយស្ងាត់ៗជាទីបំផុតថា "ឃើញៗខោអាវ ឃើញខោអាវពុក អ៊ីចឹងកុំមាត់ នៅឲ្យស្ងៀម"។

[១០:០៤:៣៣]

ដល់ពេលហ្នឹងហើយ ខ្ញុំក៏បានថា "បែបប្រហែលជារណ្តៅហ្នឹងយ៉ាង គេរើខ្មោចចោលទេដឹងនៅពីលើយើង"។ អ្នកសេដ្ឋកិច្ចទឹកហ្នឹង គេជាជន១៨ គេថា "រណ្តៅហ្នឹងគេរើខ្មោចចោល តែយើងនៅផឹកពីក្រោម វាអត់ទេ អាហ្នឹងជាថ្នាំព្យាបាលរោគ ខ្មោចធ្វើមិនត្រូវ"។ ហើយខ្ញុំក៏ វាអស្ចារ្យយ៉ាងដែរដល់គេឆ្លើយអ៊ីចឹង ហើយខ្ញុំក៏លែងមាត់លែងកទៅ បាទ។

**ស៖** សូមអរគុណលោក វ៉ាន់ឌី។ នៅមានសំណួរចុងក្រោយមួយទៀតតែប៉ុណ្ណោះ ដែលខ្ញុំសូមសួរលោក ហើយដោយសារយើងអស់ពេលហើយ។ នៅក្នុងពាក្យសុំរបស់លោក លោកបានលើកឡើងថា អ៊ំហង់ គាត់ជាអ៊ំរបស់លោកជា -- អាយុជាង៥០ឆ្នាំនោះ ក៏លោកបានលើកឡើងងផងដែរ។ អ៊ំរបស់លោកមួយនេះត្រូវបានខ្មែរក្រហមសម្លាប់នៅក្នុងខែឧសភា ឆ្នាំ១៩៧៥ នៅស្រុកអង្គរជ័យ ខេត្ត

កំពត។ ហើយលោកបានបញ្ជាក់ថា លោកទទួលបានដឹងព័ត៌មាននេះតាមផងប្អូនជីដូនមួយរបស់លោក ណូ។ តើលោកដឹងទេបងប្អូនជីដូនមួយរបស់លោកនេះ បានដឹងអំពីការសម្លាប់ឪពុកមា ឬក៏អ៊ំរបស់លោកនេះដោយរបៀបណាដែរ?

[១០:០៦:១២]

**ឆ៖** បាទ ខ្ញុំបានដឹងតាមរយៈដែលគេសម្លាប់ឪពុកមារបស់ខ្ញុំហ្នឹងឈ្មោះ អ៊ំហង់ បាទនៅខេត្តកំពតហ្នឹង តាមរយៈឈ្មោះ ណូ។ ណូ ហ្នឹងពី៧៩ គេហៅថាអីទាហានរណសិរ្ស បានចុះទៅដល់ទឹកដីខេត្តពោធិ៍សាត់ បាទទឹកដីខេត្តពោធិ៍សាត់ ហើយក៏ស្រាវជ្រាវទៅ សួរនាំទៅ ពេលហ្នឹងខ្ញុំអត់មានស្បៀងអង្ករហូប ខ្ញុំក៏ទៅសុំទាហានរណសិរ្សហ្នឹងហូប ដល់ពេលសួរនាំទៅ គេថាខ្ញុំមកពីតានី មកពីអ៊ីចឹងហើយក៏ស៊ើបសួរទៅថា ស្គាល់ឈ្មោះអ៊ំខ្ញុំហ្នឹងនៅ គាត់នៅសំឡាញ អង្គរជ័យ ស្រុកកំណើតកើតជានៅហ្នឹង។ គាត់ថាស្លាប់បាត់ហើយ គេយកទៅសម្លាប់បាត់ហើយ ហើយអ៊ីចឹងក៏មិនអស់ចិត្តទៀតក្រោយមកដល់ពេលមានសម័យគេចាយលុយ ចាយអីបន្តិចបន្តួចហ្នឹង ម្ដាយខ្ញុំក៏បានទៅស្រាវជ្រាវរកទៀត ឃើញថាស្លាប់មែន ព្រោះដីសម្បែងផ្ទះធ្លីរបស់យាយឪពុកមាខ្ញុំអីហ្នឹងគ្មានសល់ទេ។ បាទ នៅចាំបានប៉ុណ្ណឹង។

**ស៖** នៅសំណួរចុងក្រោយមួយទៀត ខ្ញុំសូមសួរលោក តើ អ៊ំហង់ នេះគឺជាទាហានដែរឬទេនៅក្នុងសម័យ លន់ នល់?

[១០:០៧:៥៥]

**ឆ៖** បាទ អ៊ំហង់ ហ្នឹងឈ្មោះ អ៊ំហង់ ហ្នឹងគាត់អត់ជាទាហានទេ គេហៅថា ឥឡូវយើងមិន -- ពីមុនមិនដឹងគេហៅថាម៉េចទេ ប៉ុន្តែឥឡូវយើងគេហៅថា មេឃុំៗ។ ពីមុនមកមិនដឹងជាគេហៅភាសារបៀបម៉េច ខ្ញុំអត់ដឹង ប៉ុន្តែដឹងសម័យនេះថាមេឃុំ។

**លោក អាប់ឌុលឡាក់ ចារីក៖**

សូមអរគុណលោក គឹម វ៉ាន់ឌី ដែលលោកបានមកទីនេះ ដើម្បីជួយផ្តល់ចម្លើយ ផ្តល់ជាសេចក្តីបង្ហាញដល់យើងខ្ញុំ។ សូមអរគុណលោកប្រធាន ដែលបានផ្តល់ពេលវេលាដល់យើងខ្ញុំ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាស

ក្នុងការតាំងសំណួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។

[១០:០៨:៤៧]

**លោក អេនឌ្រូ អ៊ីនូហ្ស៊ី៖**

សូមអរគុណលោកប្រធាន សូមជម្រាបសួរអស់លោក លោកស្រី។ សូមអរគុណលោក វ៉ាន់ឌី ដែលបានអញ្ជើញមកចូលរួមនៅទីនេះ។ ក្រុមខាង នួន ជា មិនមានសំណួរអ្វីដើម្បីចោទសួរលោកទេ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តអង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក អៀង សារី ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។

សូមអញ្ជើញ!

**លោក អាង ឧត្តម៖**

សូមគោរពតុលាការ! សូមគោរពអង្គសវនាការ! ហើយសួស្ដីលោក គឹម វ៉ាន់ឌី ខ្ញុំ អាង ឧត្តម ហើយខាងស្ដាំដៃខ្ញុំគឺលោក ម៉ៃខល កាណាវាស យើងខ្ញុំទាំងពីរនាក់ជាសហមេធាវីការពារក្ដីលោក អៀង សារី ពេលនេះយើងខ្ញុំមិនមានសំណួរនឹងសួរលោកទេ។ តែយ៉ាងណាក្ដីតាងនាមលោក អៀង សារី យើងខ្ញុំសូមជូនពរលោកឲ្យបានជួបតែជោគជ័យសិរីសួស្ដីពេលត្រឡប់ទៅវិញ និងពេលដល់គេហដ្ឋាន ហើយសូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណ។ ជាបន្តអង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន ដើម្បីមានឱកាសក្នុងការសួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។

[១០:១០:០០]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពអង្គសវនាការ! ក្រុមមេធាវីលោក ខៀវ សំផន អត់មានសំណួរទេ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

លោក គឹម វ៉ាន់ឌី ជាចុងក្រោយនៃការផ្ដល់សក្ខីកម្មរបស់លោក អង្គជំនុំជម្រះផ្ដល់ឱកាសជូន

លោកធ្វើសេចក្ដីថ្លែងរៀបរាប់ជូនអង្គសវនាការ អំពីស្ថានភាពទុក្ខវេទនា និងស្ថានភាពព្យសនកម្ម ដែលបានប៉ះពាល់ចំពោះលោកនៅក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យ ប្រសិនបើលោកមានបំណងធ្វើដូច្នេះ។

**លោក គឹម វ៉ាន់ឌី៖**

សូមគោរពលោកប្រធាន! ខ្ញុំចង់យកឯកសារហ្នឹងមកអាន ដែលខ្ញុំខំសរសេរពីយូរណាស់មកហើយ តើអនុញ្ញាតឲ្យដែរអត់?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

[១០:១១:០៥]

**លោក គឹម វ៉ាន់ឌី៖**

សូមថ្លែងអំណរអរគុណចំពោះលោកប្រធាន ដែលបានផ្ដល់ឱកាសឲ្យខ្ញុំ និងថ្លែងទុក្ខវេទនាដែលខ្ញុំនិងក្រុមគ្រួសាររបស់ខ្ញុំបានទទួល។ ក្នុងរបប –សូមពេលមួយបន្តិចសិន (សាក្សីក្អកក្អួល)– ក្នុងរបបខ្មែរក្រហម តទៅនេះ ខ្ញុំសូមរៀបរាប់ជូនលោកប្រធាន លោក លោកស្រីចៅក្រម អំពីទុក្ខវេទនាដែលរូបខ្ញុំនិងក្រុមគ្រួសារខ្ញុំដែលបានទទួលរងទុក្ខ រងទោស នៅក្នុងរបបខ្មែរក្រហម សូមលើកអំពីទុក្ខវេទនាផ្លូវកាយ។ រូបខ្ញុំ និងក្រុមគ្រួសាររបស់ខ្ញុំត្រូវចាកឆ្ងាយពីផ្ទះសម្បែងដីធ្លីទ្រព្យរបស់ និងចំណេះដឹងរបស់ខ្ញុំ ក៏ដូចជាប្រជាជនដទៃទៀតដែរ។ ដោយសារតែខ្មែរក្រហមនេះហើយ បានធ្វើឲ្យ -- បានធ្វើទារុណកម្មមកលើរូបខ្ញុំ និងក្រុមគ្រួសាររបស់ខ្ញុំ ការនេះ *(ឮមិនច្បាស់)* ចាកឆ្ងាយពីផ្ទះសម្បែង។ បង្ខំឲ្យរូបខ្ញុំ ក្រុមគ្រួសារខ្ញុំធ្វើការធ្ងន់ធ្ងរ ហួសកម្លាំង បង្អត់អាហារ មិនឲ្យហូបឆ្អែត ក៏ដូចជាប្រជាពលរដ្ឋដទៃៗទៀតដែរ។ ធ្វើឲ្យបងប្អូនស្រីរបស់ខ្ញុំ និងសាច់ញាតិរបស់ខ្ញុំជាច្រើននាក់ស្លាប់ដោយសារតែបង្អត់អាហារយ៉ាងវេទនា។ ពួកគេបានសម្លាប់ឪពុក បងប្រុស ឪពុកមា ម្ដាយមីង ព្រមទាំងសាច់ញាតិជាច្រើនទៀត ដោយអយុត្តិធម៌ គួរឲ្យអាសូរជាទីបំផុត។

[១០:១៤:២០]

សព្វថ្ងៃនេះ ធ្វើឲ្យម្ដាយរបស់ខ្ញុំក្លាយជាស្ត្រីមេម៉ាយ រីឯរូបខ្ញុំក្លាយជាកូនកំព្រារហូតមកដល់សព្វថ្ងៃនេះ។ ពេលខ្ញុំគិត -- ពេលខ្ញុំអង្គុយគិតម្ដងៗ រឿងហ្នឹងវាហាក់បីដូចជានៅថ្មីៗ ធ្វើឲ្យអារម្មណ៍របស់ខ្ញុំពុះកញ្ជ្រោល ខ្ញុំចូលបម្រើជាជួរកងទ័ព ដើម្បីសងសឹក តែលទ្ធផលវាមិនបាន វាមិនអាចធ្វើទៅ

បាន។ ធ្វើឲ្យខ្ញុំត្រូវនិរទេសខ្លួនដើម្បីលក់កម្លាំងពលកម្មបានប្រាក់បន្តិចបន្តួចទុកសម្រាប់ចិញ្ចឹមជីវិតរហូតដល់សព្វថ្ងៃទម្រាំថ្ងៃអស្តង្គតរបស់ខ្ញុំ។ សូមលោកប្រធាន លោក លោកស្រីចៅក្រមមេត្តាជួយរកភាពយុត្តិធម៌ ដាក់ទោសទណ្ឌឲ្យសមនឹងអ្វីដែលរូបខ្ញុំបានបង់ បានបាត់បង់សាច់ញាតិក៏ដូចជាអ្នកដទៃ ដែលមានរឿងដូចខ្ញុំឲ្យបានស័ក្តិសមដែលលោកប្រធាន លោក លោកស្រីចៅក្រមធ្វើទៅបាន។

ជាទីចុងបញ្ចប់ សូមថ្លែងអំណរអរគុណដល់លោកប្រធាន លោក លោកស្រីចៅក្រម ពុកម៉ែបងប្អូនដែលមានវត្តមាននៅទីនេះឲ្យជួបតែសេចក្តីសុខគ្រប់ពេលវេលា។ សូមអរគុណ សូមអរព្រះគុណ។

[១០:១៦:៣១]

**ប្រធានអង្គជំនុំ៖**

អរគុណលោក គឹម វ៉ាន់ឌី។ ឥឡូវនេះការស្តាប់សក្ខីកម្មរបស់លោករហូតដល់ពេលនេះបានចប់ហើយ ហើយវត្តមានរបស់លោកនៅ អ.វ.ត.ក នេះលែងមានភាពចាំបាច់ទៀតហើយ។ លោក គឹម វ៉ាន់ឌី សក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះ។ លោកអាចវិលត្រឡប់ទៅលំនៅដ្ឋានរបស់លោក ឬក៏គោលដៅណាដែលលោកមានបំណងចង់ទៅបានហើយ។ ហើយសូមលោកជួបតែសំណាងល្អ មានបាន -- មានសេចក្តីសុខសេចក្តីចម្រើននៅក្នុងជីវិតរបស់លោក។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសក្សី អ្នកជំនាញក្នុងការជូនដើមបណ្តឹងរដ្ឋប្បវេណីរូបនេះវិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គាត់វិញ ឬក៏គោលដៅដែលគាត់ចង់ទៅបានហើយ។

លោក គឹម វ៉ាន់ឌី អាចចាកចេញពីបន្ទប់សវនាការ វិលត្រឡប់ទៅវិញបានហើយ។

*(ដើមបណ្តឹងរដ្ឋប្បវេណីចាកចេញពីបន្ទប់សវនាការ)*

[១០:១៧:៤៦]

ជាបន្តអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅភាគីនៃរឿងក្តី ដើម្បីមានឱកាសក្នុងការធ្វើការកត់សម្គាល់លើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ដែលបានផ្តល់សក្ខីកម្មកាលពីម្សិលមិញ ហើយនិងអម្បាញ់មិញនេះ ប្រសិនបើមានបំណងធ្វើការកត់សម្គាល់។

បាទ ទំនងជាមិនមានទេ។ ឥឡូវហ្នឹងដល់ពេលសម្រាកហើយ អង្គជំនុំជម្រះសូមជម្រាបថានៅក្រោយពេលសម្រាក អង្គជំនុំជម្រះនឹងបន្តធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម TCW-247។

បាទ ឥឡូវនេះដល់ពេលសម្រាក។ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះទៅ រហូតដល់ម៉ោងដប់មួយខ្វះម្ភៃប្រាំនាទីសូមអញ្ជើញចូលវិញ ដើម្បីកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៨នាទី ដល់ម៉ោង ១០:៣៨ នាទី)*

[១០:៣៨:២៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ជាបន្តនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្ដាប់សក្ខីកម្មដែលមាន -- សាក្សីដែលមានរហស្សនាម TCW-247។ មន្ត្រីរដ្ឋបាល តុលាការ អញ្ជើញសាក្សីដែលមានរហស្សនាមTCW-247 ចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ!

[១០:៣៩:១១]

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[១០:៤០:១៤]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្ដីលោកសាក្សី! តើលោកឈ្មោះអី?

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** សូមគោរពលោកប្រធាន សូមគោរពអង្គជំនុំជម្រះ។ ខ្ញុំបាទឈ្មោះ ហ៊ុន ឈុនលី។

**ស៖** អរគុណ។ លោក ហ៊ុន ឈុនលី តើលោកមានអាយុប៉ុន្មានឆ្នាំ?

**ឆ៖** *(ឮមិនច្បាស់)* ឆ្នាំ។

**ប្រធានអង្គជំនុំ៖**

លោកឆ្លើយម្ដងទៀត ពីព្រោះរង់ចាំ ចាំក្បាលមីក្រូប្រតិបត្តិការដោយឲ្យផ្ដល់សញ្ញាភ្លើងក្រហម

សូមលោកចាប់ផ្ដើមមានប្រសាសន៍បាទ។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** តើលោកមានអាយុប៉ុន្មានឆ្នាំ?

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** ខ្ញុំអាយុ ៧៤ឆ្នាំ។

**ស៖** បាទ អរគុណ។ លោក ឈុនលី តើលោកមានទីកន្លែងកំណើតនៅទីកន្លែងណា?

**ឆ៖** ខ្ញុំកើតបាទកើតនៅស្រុកព្រៃឈរ ខេត្តកំពង់ចាម។

**ស៖** អរគុណ។ ចុះទីលំនៅស្ថានរបស់បច្ចុប្បន្ននៅទីកន្លែងណា?

**ឆ៖** ទីលំនៅស្ថានបច្ចុប្បន្នរបស់ខ្ញុំបាទ គឺនៅខណ្ឌចំការមន សង្កាត់ទួលស្វាយព្រៃ១ ផ្លូវ៣១៨ ផ្ទះលេខ១៧ សេ។

**ស៖** បាទ អរគុណ។ លោកប្រកបមុខរបររកស៊ីធ្វើអ្វីដែរសព្វថ្ងៃ? កុំអាល់ទាន់ឆ្លើយតប!

**ឆ៖** ខ្ញុំបាទចូលនិវត្តន៍តាំងពី -- ធ្វើគ្រូពេទ្យចូលនិវត្តន៍តាំងពីឆ្នាំ២០០៤។

**ស៖** អរគុណ។ តើចុះឪពុកម្ដាយរបស់លោកគាត់ឈ្មោះអី?

[១០:៤២:២៣]

**ឆ៖** ឪពុកខ្ញុំឈ្មោះ ហ៊ុន គៀន បានទទួលមរណភាពហើយ។ ម្ដាយខ្ញុំបាទឈ្មោះ សាយ យុន ក៏ទទួលមរណភាពដែរ។

**ស៖** បាទ អរគុណ។ ចុះភរិយារបស់លោកគាត់ឈ្មោះអី? ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** ភរិយារបស់ខ្ញុំទទួលមរណភាពនៅឆ្នាំ២០០៧។ ខ្ញុំមានកូនពីរ, ស្រីមួយ ប្រុសមួយ។

**ស៖** បាទ អរគុណ។ លោក ហ៊ុន ឈុនលី តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការកាលពីព្រឹកមិញនេះថា តាមសមត្ថភាពដែលលោកអាចដឹង លោកមិនមានចំណងញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងបុគ្គលទាំងឡាយត្រូវបានទទួលយកជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងរឿងក្ដីនេះទេ ហើយក៏មិនជាប់ញាតិលោហិត ឬក៏ញាតិពន្ធជាមួយជនជាប់ចោទទាំងបីនាក់ដែរ គឺលោក នួន ជា, លោក អៀង សារី, លោក ខៀវ សំផន។ តើជាការពិតមែនដែរឬទេ?

**ឆ៖** បាទ ជាការពិតទាន។

[១០:៤៣:៤១]

**ស៖** ហើយរបាយការណ៍ដដែលនោះគឺបានរាយការណ៍ថា លោកបានធ្វើសម្បថចំពោះមុខអ្នកតាដំបងដែករួចហើយកាលពីព្រឹកមិញ តើពិតមែនដែរទេ?

**ឆ៖** បាទ ពិតមែនទាន។

**ស៖** បាទ ជាបន្តទៀត អង្គជំនុំជម្រះសូមប្រាប់អំពីសិទ្ធិនិងករណីយកិច្ចក្នុងនាមលោកជាសាក្សីចំពោះ មុខអង្គជំនុំជម្រះ។ លោក ហ៊ុន ឈុនលី ក្នុងនាមលោកជាសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចបដិសេធក្នុងការឆ្លើយទៅនឹងសំណួរ ឬការធ្វើអំណះអំណាងណាមួយ ឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង។ សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងខ្លួនឯង មានន័យថា ដោយសារតែចម្លើយ ឬអំណះអំណាងរបស់លោកនោះនាំឲ្យនឹងត្រូវទទួលរងការចោទប្រកាន់។

អំពីករណីយកិច្ចក្នុងនាមលោកជាសាក្សីដែលត្រូវផ្តល់សក្ខីកម្មក្នុងកិច្ចដំណើរនីតិវិធីសវនាការនៅចំពោះមុខអង្គជំនុំជម្រះនេះលោកត្រូវតែឆ្លើយតបទៅនឹងសំណួរទាំងឡាយដែលភាគី និងចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក។ លោកជាសាក្សីត្រូវតែឆ្លើយតែការណ៍ណាដែលពិត ដែលលោកបានឃើញ បានដឹង បានឮ បានចាំ ឬក៏ធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬក៏បានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ នូវហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះរបស់លោក។ តើលោកយល់អំពីសិទ្ធិ និងករណីយកិច្ចនេះដែរឬទេ?

**ឆ៖** បាទ ខ្ញុំយល់។

**ស៖** បាទអរគុណ។ លោក ហ៊ុន ឈុនលី តើលោកមានដែលធ្លាប់ផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែរឬទេ ក្នុងអំឡុងពេលកន្លងមក?

**ឆ៖** បាទ មិនដែលទេ។

**ស៖** បាទ អរគុណ។

[១០:៤៥:៥៦]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសូមជម្រាបតំណាងសហព្រះរាជអាជ្ញាថា អនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ស្ទួននៃវិធានផ្ទៃក្នុង អ.វ.ត.ក ក្នុងកិច្ចដំណើរការនីតិវិធីសវនាការពិភាក្សាដេញដោលក្នុងការស្តាប់សក្ខីកម្មសាក្សីរូបនេះ។ អង្គជំនុំជម្រះផ្តល់វេទិកាជូនតំណាងសហព្រះរាជអាជ្ញាតាំងសំណួរដេញដោលចំពោះ

សាក្សីនេះមុនភាគីដទៃទៀតនៃរឿងក្តី។ ហើយក៏សូមបញ្ជាក់ដែរថា តំណាងសហព្រះរាជអាជ្ញារួមទាំងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពេលសរុប១ថ្ងៃ ក្នុងការសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញ!

[១០:៤៦:២៩]

**លោក វ៉េង ហ៊ត់៖**

សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រមនៃអង្គជំនុំជម្រះ។ សូមគោរពមិត្តភក្តិរួមការងារទាំងអស់ដែលបានធ្វើការនៅទីនេះទាំងមូល។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វ៉េង ហ៊ត់៖**

**ស៖** សួស្តីលោក ហ៊ុន ឈុនលី ចាប់ពីពេលនេះតទៅ ខ្ញុំសូមការអនុញ្ញាតហៅលោកថាលោកគ្រូ បើលោកមិនជំទាស់ទេ ខ្ញុំហៅលោក "លោកគ្រូ" បាទ។

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** បាទ លោកហៅជាតែលោកធម្មតាក៏បានដែរបាទ។

**ស៖** អរគុណលោក ឈុនលី។ មុននឹងខ្ញុំសួរសំណួរទៅលោក ខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ដោយសារសរសេរ គឺជីវិតគ្រូពេទ្យម្នាក់នៅក្នុងរបបខ្មែរក្រហម កាលពីលោកសរសេរមិនទាន់ដាក់ ERN ជាភាសាអង់គ្លេសទេ ឬក៏ ERN ជាភាសាខ្មែរទេ។ អ៊ីចឹងសៀវភៅនេះត្រូវបានអង្គជំនុំជម្រះបានបញ្ចូលដាក់ ERN ជាភាសាអង់គ្លេស។ ដូច្នេះ ការត្រួតពិនិត្យរបស់ខ្ញុំឃើញថា ទំព័រមួយចំនួនវាអាចល្អៀងបន្តិចពីសៀវភៅលោកសរសេរ។

**លោក វ៉េង ហ៊ត់៖**

អ៊ីចឹងលោកប្រធាន ខ្ញុំការអនុញ្ញាតដាក់សៀវភៅនេះជូនលោក ហ៊ុន ឈុនលី បាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកជូនសាក្សីពិនិត្យ!

**លោក វ៉េង ហ៊ត់៖**

អរគុណលោកប្រធាន។

**សួរដោយលោក វ៉េង ហ៊ត់៖**

**ស៖** ឥឡូវខ្ញុំសូមចាប់ផ្តើមសួរលោក ឈុនលី។ លោក ឈុនលី លោកអាចប្រាប់យើងខ្ញុំដែលជាក្រុមការងារមកពីសហព្រះរាជអាជ្ញា។ ខ្ញុំនេះឈ្មោះ វ៉េង ហ៊ត់ ហើយសហការីខ្ញុំម្នាក់ទៀតគឺលោកថារីក។ ឥឡូវនេះ ខ្ញុំចាប់ផ្តើមសួរលោកថា តើសៀវភៅដែលខ្ញុំបានជូនលោកនេះ "ស្តីពីជីវិតគ្រូពេទ្យម្នាក់នៅក្នុងរបបខ្មែរក្រហម" លោកសរសេរសៀវភៅនេះចប់នៅក្នុងឆ្នាំណាដែរលោក?

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** សូមជម្រាបថា សៀវភៅនោះបោះពុម្ពពីរដង។ លើកទី១ គឺចប់នៅថ្ងៃ១៩ មករា ២០០៦។ អាហ្នឹងលើកទី១ ហើយសៀវភៅដែលលោកបានទទួលនេះជាលើកទី១។ ហើយចំពោះសៀវភៅនេះ សៀវភៅលើកទី២ បោះពុម្ពលើកទី២។ ខ្លឹមសារដដែលទេ គ្រាន់តែកែពាក្យពេចន៍មួយចំនួនប៉ុណ្ណឹង ខ្លឹមសារនៅដដែលបាទ។ នេះមានសរសេរចប់នៅឆ្នាំ២០១០ ហើយមានលេខចុះលេខ អេស.អ៊ី.អាយ. អេស.ប៊ី.អិន។ ខ្ញុំបានប្រគល់៥ក្បាល នៅបណ្ណាល័យជាតិ ហើយនិងពីរក្បាលនៅឯកសារមជ្ឈមណ្ឌលខ្មែរ។

[១០:៥១:១១]

**ស៖** ខ្ញុំចង់ដឹងថា តើលោកសរសេរសៀវភៅនេះដោយខ្លួនឯង ឬមួយក៏លោកមានគំនិតខ្លះដើម្បីបញ្ចេញបញ្ចូល?

**ប្រធានអង្គជំនុំ៖**

ឈប់ៗ! សាក្សីកុំអាលទាន់ឆ្លើយតប បាទ។ សូមបង្អង់បន្តិច ព្រោះនៅនេះយើងមានប្រើប្រព័ន្ធស្តាប់សំឡេង និងបកប្រែភាសាជាបីភាសា។ ជាភាសាខ្មែរ ជាភាសាអង់គ្លេស និងភាសាបារាំង។ ហេតុដូច្នេះ វាទាមទារពេលវេលាមួយឃ្លាតបន្តិច ដើម្បីឲ្យផ្តល់ឱកាសពេលវេលាសមស្របសម្រាប់ការបកប្រែភាសាបានពេញលេញ។ បាទ សូមអរគុណ បាទ។

**ឆ៖** ខ្ញុំសរសេរសៀវភៅនេះ គឺសរសេរនូវអ្វីដែលខ្ញុំបានធ្វើ បានឃើញ បានដឹង បានឮ។ ខ្ញុំអត់មានបញ្ចេញបញ្ចូលទេ។ ពីព្រោះខ្ញុំបានឆ្លងកាត់របបខ្មែរក្រហម នេះគឺថាមិត្តភក្តិខ្ញុំស្លាប់សឹងទាំងអស់នៅសល់តែខ្ញុំ។

**ស៖** តើសៀវភៅនេះ លោកចាប់ផ្តើមសរសេរ ឬក៏មានគំនិតនៃការចាប់ផ្តើមសរសេរនោះ ចាប់ពីឆ្នាំណាដែរ?

**ឆ៖** តាមពិតនៅក្នុងរបប ប៉ុល ពត ខ្ញុំបានកត់ត្រាមួយចំនួននៅតាមក្នុងសៀវភៅតូចរបស់ខ្ញុំ។ ប៉ុន្តែដោយសារខ្មែរក្រហមឆែកឆេរផ្ទះច្រើនពេក ខ្ញុំក៏ដុតចោលទៅ ហើយខ្ញុំខិតខំរកគន្លឹះសំខាន់ៗ ដើម្បីចងចាំនូវព្រឹត្តិការណ៍សំខាន់ៗ។

[១០:៥៣:០៦]

**ស៖** ឥឡូវនេះ យើងខ្ញុំចង់ដឹងនៅថ្ងៃកើតហេតុពីថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥។ តើនៅថ្ងៃទី១៧ ខែមេសា ១៩៧៥ មុនថ្ងៃ១៧ មេសា តើលោកធ្វើអ្វីដែរ ការងារ?

**ឆ៖** មុន១៧ មេសា ១៩៧៥ ខ្ញុំត្រូវចូលបម្រើកងទ័ព ហើយមកធ្វើការជាគ្រូពេទ្យអនុសេនីយ៍ទោនៅមន្ទីរពេទ្យខេត្ត -- មន្ទីរពេទ្យយោធា ខេត្តបាត់ដំបង។

**ស៖** លោកចូលបម្រើកងទ័ពនោះ តើកងទ័ព លន់ នល់ ឬក៏កងទ័ពអ្វីដែរ?

**ឆ៖** កាលនោះ គឺរបប លន់ នល់ គេតម្រូវឲ្យមន្ត្រី ជាពិសេសគ្រូពេទ្យចូលបម្រើយោធារយៈពេលជាង២ឆ្នាំ។

**ស៖** បាទ តើនៅក្នុងមន្ទីរពេទ្យដែលលោកបម្រើការងារបុគ្គលិកពេទ្យជាទាហាន លន់ នល់ ទាំងអស់ប៉ុន្មាននាក់ដែរលោក?

[១០:៥៥:០០]

**ឆ៖** នៅមន្ទីរពេទ្យយោធាខេត្តបាត់ដំបង ដែលគេហៅថាមន្ទីរពេទ្យ៤០៣ នោះ បុគ្គលិកមានជាង៣០នាក់។

**ស៖** តើមន្ទីរពេទ្យដែលលោកធ្វើការនោះ មានអ្នកជំងឺជាទាហាន លន់ នល់ ឬជនស៊ីវិលដែរទេនៅក្នុងស្ថានភាពនុ៎ង?

**ឆ៖** នៅមន្ទីរពេទ្យយោធានោះ គឺមានអ្នកជំងឺគឺសុទ្ធតែជាយោធា។

**ស៖** ខ្ញុំចង់បញ្ជាក់លម្អិតបន្តិច តើយោធានេះ ជាយោធា លន់ នល់ ឬក៏យោធាទាំងកម្ពុជាប្រជាធិបតេយ្យខ្មែរក្រហមដែរ?

**ឆ៖** បាទជាអ្នកជំងឺជាយោធានៃរបប លន់ នល់។

**ស៖** បាទ អរគុណលោក។ ឥឡូវចូលដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៥។ លោកអាចរៀបរាប់ហេតុការណ៍ដែលកើតឡើងនៅពេលនោះដែលលោកចងចាំ គឺនៅចំថ្ងៃទី១៧ ខែមេសា ៧៥ តែម្តងបាទ។

[១០:៥៦:៣៨]

**ឆ៖** នៅព្រឹកម៉ោងប្រាំពីរ ថ្ងៃ១៧ មេសា ១៩៧៥ គឺវិទ្យុភ្នំពេញ តាមវិទ្យុភ្នំពេញ គឺឧត្តមសេនីយ៍ ម៉ី ស៊ីចន និងឧត្តមសេនីយ៍ លន់ ណុន ដែលជាប្អូនសេនាប្រមុខ លន់ នល់ បានប្រកាសការចុះចាញ់នៃរបបសាធារណរដ្ឋ លន់ នល់ ហើយអំពាវនាវឲ្យយោធាទូទាំង -- ឲ្យទាហាន លន់ នល់ ទូទាំងប្រទេសដាក់អាវុធចុះ។ ហើយបន្ទាប់មកទៀតយើងឮសូរសំឡេងមួយដែលគួរឲ្យខ្លាច គឺពួកម្នាភិបាលខ្មែរក្រហមនិយាយថា យើងកងទ័ពបដិវត្តន៍កម្ពុជាទទួលជ័យជម្នះដោយសារការតស៊ូអាវុធ មិនមែនដោយសារការចរចាទេ។

**ស៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

បើកក្បាលមីក្រូហ្វូន អត់បើកផង!

**លោក វ៉េង ហ៊ាត់៖**

អរគុណលោកប្រធាន។

[១០:៥៧:៥៣]

**សួរដោយលោក វ៉េង ហ៊ាត់៖**

**ស៖** ឥឡូវនេះលោកគ្រូចាប់ផ្ដើមកាន់សៀវភៅ ដែលខ្ញុំបានជូនលោកគ្រូអម្បាញ់មិញ ហើយលោកគ្រូចាប់ផ្ដើមពិនិត្យមើល ERN ជាភាសាខ្មែរ គឺនៅក្នុងលោកគ្រូកាន់ គឺមានលេខនៅខាងលើ 00 ខាងចុង 00 ខាងលើ អាហ្នឹងគេហៅ ERN លោកគ្រូ។ លោកគ្រូៗចាំមើលដៃខ្ញុំ គឺនេះជាលេខ ERN ខាងលើនេះ។ បាទ អ៊ីចឹងខ្ញុំអានជូនលោកគ្រូឥឡូវនេះ ERN 00678788--

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការសម្រួលសម្រួល!

**លោក វ៉េង ហ៊ាត់៖**

*(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

លោកអត់បើកក្បាលមីក្រូទេ! ហើយលោកប្រើពាក្យត្រឹមតែលោកទៅបានហើយ!

**លោក វ៉េង ហ៊ត់៖**

អរគុណលោកប្រធាន។

[១០:៥៩:១៣]

**សួរដោយលោក វ៉េង ហ៊ត់៖**

**ស៖** លោកអាន 00678758 ជាភាសាខ្មែរ, ភាសាអង់គ្លេស 00369682។ ចំណែកភាសាបារាំងអត់មានទេ ខ្ញុំ។ ក្នុងៗសៀវភៅនេះលោកសរសេរថា “នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ៧៥ គឺថ្ងៃទី៣ ខ្មែរក្រហមបានផ្សព្វផ្សាយឲ្យដឹងថា ជនជាតិវៀតណាម យួន ទាំងអស់ត្រូវត្រឡប់ទៅប្រទេសយួនវិញ។ នៅថ្ងៃដដែលមានបទបញ្ជាពីថ្នាក់ឲ្យគ្រប់នាយទាហាន លន់ នល់ ចាប់ពីអ្នកដែលមានឋានៈអនុសេនីយ៍ត្រីឡើងទៅ ត្រូវមកប្រមូលផ្តុំនៅសាលារៀនចិនកណ្តាលទីក្រុង។ ចំណែកទាហានមានឋានៈក្រោមអនុសេនីយ៍ត្រី បានមកប្រមូលផ្តុំនៅសាលាបឋមសិក្សាសោហ៊ី ជិតស្ពានថ្មី។ ទាហានទាំងអស់សុទ្ធតែមកដៃទទេ គ្មានអាវុធជាប់ខ្លួន ហើយស្នាក់នៅទាំងថ្ងៃទាំងយប់នៅកន្លែងប្រមូលផ្តុំ”។ សំណួររបស់យើងខ្ញុំ គឺចង់ដឹងថា តើខ្មែរក្រហមបានផ្សព្វផ្សាយបទបញ្ជាពីថ្នាក់លើនេះតាមរយៈអ្វីដែរ?

**ឆ៖** សូមជម្រាបលោកថា ខ្មែរក្រហមមិនប្រើការផ្សព្វផ្សាយជាផ្លូវការ ៗដូចយើងទេ ប៉ុន្តែការផ្សព្វផ្សាយរបស់គេមានប្រសិទ្ធភាពណាស់។ គ្រាន់ឮតៗគ្នាអ៊ីចឹង គឺថាៗទាហាន -- ដែលថា បន្ទាប់មកគឺជនជាតិវៀតណាមហ្នឹងគឺជិះទូកៗអមដោយខ្មែរក្រហម ហើយចុះទៅក្រោមតាមទន្លេសាប។ ហើយទាហានប្រមូលផ្តុំនៅកន្លែងអ៊ីចឹងមែន។ ត្រង់ថាបទបញ្ជាឲ្យចេញជាផ្លូវការដូចគេដទៃទៀតគឺអត់មាន។ ប៉ុន្តែមានប្រសិទ្ធភាព ការផ្សព្វផ្សាយរបស់គេ។

[១១:០២:១៤]

**ស៖** អរគុណលោក។ ឥឡូវនេះខ្ញុំសួរចំណុចតែទាហាន លន់ នល់ ទេ។ តើទាហាន លន់ នល់ ទៅនៅប្រមូលផ្តុំនោះរហូតទៅដល់ពេលណាដែរ?

**ឆ៖** ទាហាន លន់ នល់ គឺចាប់ពីស័ក្តិ១ទៅ គឺត្រូវប្រមូលផ្តុំនៅសាលាចិនកណ្តាលទីក្រុង។ ចំណែកក្រោមស័ក្តិ១ គឺប្រមូលផ្តុំនៅសាលាសោហ៊ី ជិតស្ពានថ្មថ្មី។ ដល់ថ្ងៃ២៣ ខែមេសា ឆ្នាំ១៩៧៥ (ស៊ីក) ម៉ោងមិនទាន់ -- ម៉ោងប្រហែលប្រាំភ្លឺ បានមានឡានធំ ឡានកាំមីញ៉ុងដឹកទាំងទាហានទាំងអស់ នាយទាហានទាំងអស់ គឺដឹកនាយទាហាន អ្នកមុខ អ្នកការ ប្រធានអង្គភាពរដ្ឋ ដែលយើងសព្វថ្ងៃហៅថា ប្រធាននាយកដ្ឋាន គឺថាចេញពីបាត់ដំបងឆ្ពោះមកផ្លូវជាតិលេខ៥។ ចំណែកទាហានក្រោមស័ក្តិ១ គឺ

ចេញ គឺជិះឡាន គឺដឹកឡានឆ្ពោះទៅតាមផ្លូវប៉ៃលិន រួចទៅ ទៅម្តុំមួយគេហៅថាអូរពងមាន់ ផ្លូវដែលទៅអាងកំពីងពួយសព្វថ្ងៃនេះ។

**ស៖** តើមុនដំបូងនោះ លោកដឹងថាគោលបំណងនៃការប្រមូលទាហាននេះ គេ -- ទាហាន លន់ នល់ ទាំងអស់នេះ គេយកធ្វើអីដែរ?

**ឆ៖** ខ្ញុំមិនដឹងថា -- គេនិយាយថា គេហៅ គេឲ្យទាហានចាប់ពីស័ក្ត១ឡើងទៅ ទៅភ្នំពេញ ដើម្បីទៅទទួលសម្តេចឪ ហើយមិនចាំបាច់យករបស់របរច្រើនទេ ម្ហូបអាហារគឺមានជូនពិសាតាមផ្លូវ។

[១១:០៤:៣៦]

**ស៖** តើក្រោយមកជោគវាសនារបស់ទាហានដែលប្រមូល -- ទាហាន លន់ នល់ ដែលប្រមូលផ្តុំ រួមទាំងមន្ត្រីរាជការរបស់ លន់ នល់ ទាំងអស់នោះ យ៉ាងម៉េចដែរ លោកដឹងទេ?

**ឆ៖** ខ្ញុំជាង១ខែមកហើយទេបានដឹង។ បានដឹងដោយសារស្ហ្វ័រឡានម្នាក់ប្រាប់ខ្ញុំថា "ទាហាននៅនោះគេដឹកទៅដល់ៗភ្នំធិបដេ ហើយគេចូលទៅក្នុងហើយបាញ់ចោលទាំងអស់"។ ចំណែកទាហានក្រុមស័ក្តិ១ ដែលជម្លៀសទៅតាមផ្លូវទៅប៉ៃលិន គេអត់សម្លាប់ទេ គេឲ្យធ្វើស្រែចម្ការនៅម្តុំមួយគេហៅថា អូរពងមាន់។

**ស៖** លោកអាចដឹងពីចំនួនទាហាន និងមន្ត្រីរាជការដែលគេយកទៅបាញ់សម្លាប់ចោទទាំងអស់ហ្នឹងប្រហែលជាប៉ុន្មានដែរបាទ?

**ឆ៖** ខ្ញុំមិនអាចថាប៉ុន្មានទេ ប៉ុន្តែបើតាមខ្ញុំដឹង គឺប្រហែលឡានប្រាំកាំម៉ីញ៉ុង ព្រោះមាននាយទាហានផង មានអ្នកមុខអ្នកការផង មានប្រធានអង្គភាពខេត្តផង។

**ស៖** អរគុណលោក។ ឥឡូវនេះ ខ្ញុំចាប់ផ្តើមសួរអំពីពេទ្យយោធាវិញ។ នៅក្នុងសៀវភៅរបស់លោក ERN ជាភាសាខ្មែរ 00678761 ទៅដល់ 62, ERN ជាភាសាអង់គ្លេស 00369683 ដល់ 84 លោកបានប្រាប់ រៀបរាប់អំពី "ការសម្លាប់គ្រូពេទ្យទាហាន នៅមន្ទីរពេទ្យយោធា៤០៣ ដែលលោកធ្វើការ" លោករៀបរាប់អ៊ីចឹង។ ហើយខ្ញុំចង់សួរថា តើលោកអាចរៀបរាប់ពីព្រឹត្តិការណ៍នេះឲ្យបានក្បោះក្បាយជូនអង្គសវនាការបានដែរទេបាទ?

[១១:០៧:២០]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ! សូមអញ្ជើញលោកមេធាវីការពារក្តីលោក នួន ជា!

**លោក ហ្សាស្តើ ប៉ោ៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរអស់លោក លោកស្រីទាំងអស់គ្នា ទាំងនៅក្នុងនិងក្រៅសាលសវនាការ។ មតិរបស់ខ្ញុំគឺពាក់ព័ន្ធទៅនឹងសំណួរដែលបានសួរពីមុនមក ហើយដែលសំណួរនេះគឺសួរពាក់ព័ន្ធទៅនឹងទាហាន លន់ នល់ ដែលត្រូវបានគេយកចេញពីទីរួមខេត្តបាត់ដំបង ហើយខាងព្រះរាជអាជ្ញាបានសួរនូវសំណួរមួយចំនួន ប៉ុន្តែមិនបានសួរសំណួរដែលសំខាន់សំផុត ដែលថាសាក្សីនេះបានឃើញដោយផ្ទាល់ ឬមួយក៏គាត់គ្រាន់តែស្តាប់ឮពីអ្នកដទៃ។ ខ្ញុំគិតថាប្រហែលជាព្រះរាជអាជ្ញា គាត់និងនិយាយថា យើងនឹង -- ខាងយើងមានឱកាសសួរប្រធានបទមួយនេះ វាជាការពិតហើយ ប៉ុន្តែខ្ញុំគិតថា វាជាការអនុវត្តដ៏ល្អ ប្រសិនបើយើងធ្វើការសាកសួរសាក្សីឲ្យដឹងថា តើគាត់ដឹងដោយខ្លួនឯង ឬក៏ឮពីគេ។ ដូច្នេះ ខ្ញុំគិតថាមិនមែនជាការជំទាស់ទេ ប៉ុន្តែគ្រាន់តែការស្នើសុំដល់ខាងព្រះរាជអាជ្ញាឲ្យធ្វើការសាកសួរសាក្សីអំពីការដឹងរបស់គាត់ ថាតើគាត់ដឹងដោយផ្ទាល់ ឬមួយក៏គាត់គ្រាន់តែស្តាប់ឮ។ ហើយវាក៏ -- ហើយវាក៏ជាប្រយោជន៍ដល់ខាងព្រះរាជអាជ្ញាផងដែរ ដែលព្រះរាជអាជ្ញាធ្វើការសាកសួរអំពីមូលដ្ឋាននៃៗព័ត៌មានបែបនេះ។ សូមអរគុណ។

[១១:០៨:៥៧]

**លោក វើង ហ៊ត់៖**

លោកប្រធាន អរគុណទៅដល់មេធាវីការពារក្តី។ ចំពោះចំណុចនេះប្រសិនបើលោក ពេលក្រោយ ពេលវេលារបស់លោក លោកអាចសួរគាត់បាន។ វាជាសេរីភាពរបស់លោកដែលទុកឲ្យលោក។ ចំណែកខ្ញុំ ខ្ញុំមានពេលវេលាមួយចំនួនដែរ អ៊ីចឹងខ្ញុំត្រូវសួរតាមលំដាប់លំដោយ។ ចំពោះឯកសារពិស្តារនៅក្នុងនេះ គឺលោកមានឮដែរ គាត់សរសេរថាចំនួនជាង២០០នាក់ឯណោះ ក៏ប៉ុន្តែឱកាសនេះ គឺជាឱកាសរបស់លោក។

លោកប្រធាន ខ្ញុំ -- បើលោកប្រធានអនុញ្ញាត ខ្ញុំសួរបន្តបាទ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

**លោក វើង ហ៊ត់៖**

អរគុណលោកប្រធាន។

[១១:១០:០៥]

**សួរដោយលោក វ៉េង ហ៊ាត់៖**

**ស៖** លោកសាក្សី អម្បាញ់មិញ ខ្ញុំសួរលោកថា តើលោកអាចរៀបរាប់ពីព្រឹត្តិការណ៍ដែលគេសម្លាប់គ្រូពេទ្យទាំង១៣នាក់ហ្នឹងបានដែរឬទេ? លោកជួយរៀបរាប់ជូនអង្គសវនាការ។

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់!

**លោក ហ៊ិន ឈុនលី៖**

**ឆ៖** នៅពេលនោះ គឺនៅថ្ងៃ២០ ខែមេសា ១៩៧៥ ម៉ោងប្រាំបីកន្លះ ប្រធានមន្ទីរពេទ្យលោកវរសេនីយឯក តាន់ តុ បានធ្វើការប្រជុំបុគ្គលិកពេទ្យទាំងអស់។ គាត់មានប្រសាសន៍ថា “គាត់ទើបនឹងមកពីប្រជុំពីសាលាខេត្ត។ គេតម្រូវឲ្យបុគ្គលិកពេទ្យទាំងអស់ យាមទាំងថ្ងៃទាំងយប់ និងហូបបាយនៅមន្ទីរពេទ្យ ដើម្បីផ្តល់ការថែទាំដល់អ្នកជំងឺឲ្យបានល្អ”។ បាទ គាត់និយាយខ្លីប៉ុណ្ណឹង។ ហើយរួចទៅយើងក៏បែកគ្នាទៅ បែកគ្នាទៅធ្វើការងាររៀង១ខ្លួននៅមន្ទីរពេទ្យទៅ បាទ។

[១១:១១:៣០]

ដល់វេលាម៉ោងប្រាំល្ងាច ចំពោះខ្ញុំ ខ្ញុំមិនដឹងថា មានអ្វីមួយជំរុញឲ្យខ្ញុំនៅមិនស្ងៀម។ ខ្ញុំនឹកដល់កូនខ្ញុំ តែពីរនាក់ ក្មួយពីរនាក់ ឪពុកម្តាយ ចំពោះប្រពន្ធខ្ញុំជាប់នៅភ្នំពេញ។ ខ្ញុំក៏សុំច្បាប់លោកវរសេនីយ៍ឯកប្រធានមន្ទីរពេទ្យ សុំគាត់មកដេកនៅផ្ទះ។ ពេលនោះឯង ព្រលឹមឡើងថ្ងៃ២១, នៅថ្ងៃ២១ ខែមេសា ១៩៧៥ ខ្មែរក្រហមបានហៅបុគ្គលិកពេទ្យទាំងអស់ ចាប់ពីស័ក្តិ១ឡើងទៅ ចំនួន១៣នាក់ ជិះឡានទៅដើម្បីទទួលក្រុមដែលគេហៅថា “ក្រុមពេទ្យបដិវត្តន៍”។ ប៉ុន្តែបើកឡានទៅដល់ប្រហែល៦គីឡូម៉ែត្រពីមន្ទីរពេទ្យ ទៅកន្លែងមួយគេហៅថា អូម៉ាល់ គឺឡាននោះ ក៏បត់តាមផ្លូវតូច ហើយគេឲ្យអ្នកជំងឺចេញទាំងអស់ ចេញពីឡានទាំងអស់ រួចទៅគេបាញ់ទាំងអស់ ងាប់ទាំង១៣នាក់ បាទ។ ហើយចំពោះខ្ញុំបាទវិញ ដែលដឹង១តែរឿង គឺថ្ងៃមកទេ បានដឹង។ ពីព្រោះពេលនោះ ពេលយប់ ខ្ញុំដេកអត់លក់សោះ ខ្ញុំដេកមិនលក់ទាល់ភ្លឺ។ ព្រលឹមឡើង ខ្ញុំដើរទៅមន្ទីរពេទ្យស៊ីវិល ដែលខ្ញុំធ្លាប់ធ្វើការ ហើយខ្ញុំមកចូលបន្ទប់មួយអគារមួយ ចូលទៅ ខ្ញុំប្រះលើគ្រែលក់ទៅ។ លក់ទៅ ដល់ម៉ោង ស្រាប់តែ ម៉ោងពីរ ខ្ញុំឮសូរ១ បុគ្គលិកពេទ្យម្នាក់ហៅឈ្មោះខ្ញុំ។ ខ្ញុំងើបឡើង ទៅឃើញជាគិលានុបដ្ឋាកម្នាក់ ហើយគាត់ប្រាប់ គាត់និយាយថា “បងឯងរស់ហើយ១ ខ្មែរក្រហមបានបាញ់ពេទ្យទាហាន១៣នាក់ នៅក្នុងស្រែរបស់ខ្ញុំ។ ខ្ញុំស្គាល់តែលោក តាន់ តុ មួយទៀត ខ្ញុំមិនដឹងអ្នកណាខ្លះទេ” ថាអ៊ីចឹងបាទ។

**ស៖** អរគុណលោក។ នៅក្នុងស្ថានភាពជាក់ស្ដែងនោះ តើលោកដឹងថា មូលហេតុអីបានគេសម្លាប់ពេទ្យយោធាទាំង១៣នាក់នោះ? គេមានប្រាប់មូលហេតុច្បាស់លាស់ទេ បាទ?

[១១:១៤:៣៣]

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយៗ!

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** ខ្ញុំយល់ឃើញថា នេះជានយោបាយសុខាភិបាលរបស់ខ្មែរក្រហម។ គឺទី១ សម្លាប់ពេទ្យទាហាន ចាប់ពីស័ក្ដិ១ ឡើងទៅឲ្យអស់ ហើយបន្ទាប់មកបានជាបន្តបន្ទាប់ ពេទ្យស៊ីវិល។

**ស៖** តើលោកអាចដឹងច្បាស់ទេថា ការសម្លាប់របៀបនេះបញ្ជាពីថ្នាក់មកដែរបាទ?

**ឆ៖** ខ្ញុំមិនអាចៗឆ្លើយបាន មិនដឹង។ គេនិយាយថាអង្គការថ្នាក់លើៗអ៊ីចឹង យើងមិនដឹងអ្នកណាខ្លះ។

**ស៖** ចុះអ្នកជំងឺដែលស្នាក់នៅព្យាបាលនៅមន្ទីរពេទ្យ បន្ទាប់ពីគេសម្លាប់ពេទ្យជំនាញៗ ដែលមានបទពិសោធន៍អស់នោះ តើអ្នកជំងឺទាំងអស់នោះមានស្ថានភាពដូចម្ដេចដែរបាទ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

អត់ទាន់អាចនិយាយបានទេបាទ។

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** នៅពេលដែលគេទៅប្រាប់ខ្ញុំថា "គេបានសម្លាប់ពេទ្យជាសហការីរបស់ខ្ញុំ"។ ខ្ញុំហាក់ដូចជាមានអ្វីមួយជំរុញខ្ញុំឲ្យដើរមកកាន់មន្ទីរពេទ្យ។ ខ្ញុំដើរមកកាន់មន្ទីរពេទ្យយោធា។ មកដល់ខ្ញុំប្រុងចូលមកតាមៗទ្វារចំហៀង រៀបចំហើយស្រាប់តែមានកូនទាហានមួយវាចាប់ដៃខ្ញុំចេញ ចាប់ដៃខ្ញុំមកក្រោយ។ វាស្លៀកស៊ីវិលទេ វាថា "កុំៗចូល ពួកវាសម្លាប់ពួកយើងអស់ហើយ"។ ហើយខ្ញុំទៅៗចូលទៅខាងមុខតាមទ្វារមុខ ខ្ញុំចង់ៗចូលទៀត ប៉ុន្តែមានម្នាក់ទៀតចាប់ដៃខ្ញុំចេញ។ ហើយខ្ញុំឃើញ ខ្ញុំខំសម្លឹងមើលក្រែងមានបុគ្គលិកពេទ្យណាដែលនៅសេសសល់ ខ្ញុំអត់ឃើញមានបុគ្គលិកពេទ្យមួយទេ ឃើញតែអ្នកជំងឺដែលដើរចេញពីមន្ទីរពេទ្យ ខ្លះមានបងប្អូន ខ្លះបងប្អូនមកជួយកំដរ ខ្លះមានរ៉ឺម៉កជួយដឹកៗបាទ។

គឺអាណោចអាធ័មណាស់បាទ។

[១១:១៧:៤២]

**ស៖** ក្នុងភ្ជាប់សំណួរនេះដដែល។ ខ្ញុំចង់បញ្ជាក់ឲ្យលោកនិយាយឡើងវិញ តើបន្ទាប់ពីសម្លាប់ទាហានពេទ្យយោធា លន់ នល់ ១៣នាក់ ហើយមន្ទីរពេទ្យស៊ីវិលផ្សេងទៀតដែលជាមន្ត្រីរាជការស៊ីវិលនៅក្នុងរបប លន់ នល់ ដែរនោះ គេៗមានសកម្មភាពយ៉ាងដូចម្ដេចលោកដឹងទេបាទ?

**ឆ៖** សុំទោសលោកមានប្រសាសន៍ម្ដង។

**ស៖** បន្ទាប់ពីសម្លាប់អ្នកជំនាញ វេជ្ជបណ្ឌិតពេទ្យយោធាទាំង១៣នាក់ អស់ពីមន្ទីរពេទ្យយោធាហើយ តើមន្ទីរពេទ្យស៊ីវិលមានមន្ត្រីរាជការ លន់ នល់ ដែលមានបទពិសោធន៍នៅទីនោះ តើគេមានធ្វើអ្វីចំពោះគាត់ដែរឬទេ បន្ទាប់ពីថ្ងៃទី១៧ មេសា ភ្លាមៗហ្នឹងបាទ?

**ឆ៖** ចំពោះមន្ទីរពេទ្យស៊ីវិល គេមិនទាន់បានប៉ះពាល់ទេបាទ។ ប៉ុន្តែអ្នកជំងឺចេញ មានតែចេញទេ អត់មានចូលទេអ្នកជំងឺ។ ហើយបុគ្គលិកពេទ្យស៊ីវិលហ្នឹងក៏មិននៅយូរដែរ ក្រោយមកគេសម្លាប់ជាបន្តៗទៀត ជាពិសេសចាប់ពីឆ្នាំ៧៧ ទៅ។

**ស៖** អរគុណលោក។ ខ្ញុំសួរទាក់ទងនឹងចំណុចបន្ថែមទៀត នៅក្នុង ERN ជាភាសាខ្មែរ 00678863, ERN ជាភាសាអង់គ្លេស 00369685, លោកបានសរសេរថា “ថ្វីដ្បិតបើវិទ្យុភ្នំពេញឈប់ការផ្សាយ ប៉ុន្តែមានការនិយាយតៗគ្នាថា សម្ដេចព្រះ នរោត្តម សីហនុ នឹងយាងត្រឡប់មកពីប៉េកាំងមកភ្នំពេញនៅពេលឆាប់ៗខាងមុខនេះ។ ជាមួយគ្នានេះ ពួកខ្មែរក្រហមបានផ្សព្វផ្សាយបទបញ្ជាឲ្យគ្រប់មន្ត្រី ប្រធានអង្គភាពក្នុងខេត្ត គ្រប់នាយទាហានចាប់ពីអនុសេនីយត្រីឡើងទៅ ទៅរៀបចំឡើងរថយន្តកាមីញ៉ុងទៅភ្នំពេញ នៅព្រឹកថ្ងៃទី២៣ មេសា ឆ្នាំ១៩៧៥ វេលាម៉ោងប្រាំព្រឹកដើម្បីទៅទទួលសម្ដេចឪ។ ពួកវាបានបញ្ជាក់ថា មិនចាំបាច់យកអីវ៉ាន់ទៅជាមួយទេ ម្ហូបអាហារ និងមានផ្ដល់តាមផ្លូវ”។ ខ្ញុំចង់សួរថា តើខ្មែរក្រហមបានផ្សព្វផ្សាយបទបញ្ជាឲ្យគ្រប់មន្ត្រីយោធានៅភ្នំពេញតាមរយៈអ្វីដែរ?

**ប្រធានអង្គជំនុំ៖**

កុំអាល់ទានឆ្លើយតបសាក្សី!

សូមអញ្ជើញលោកមេធាវី អាង ឧត្តម!

[១១:២១:២៥]

**លោក អាង ឧត្តម៖**

សូមគោរពតុលាការ សូមគោរពអង្គសវនាការ។ ខ្ញុំមិនបានជំទាស់ទេ ក៏ប៉ុន្តែសូមសំណូមពរឲ្យសហព្រះរាជអាជ្ញាបញ្ជាំងឯកសារដែលលោកយោង និងអាននោះនៅក្នុងកញ្ចក់ទូរទស្សន៍ផង។ ហើយសូមបញ្ជាំងឲ្យយូរបំផុតដើម្បីឲ្យភាគីតាមដាន បើសិនជាអាចធ្វើបាន។ សូមអរគុណ។

**លោក វ៉េង ហ៊ត់៖**

លោកប្រធាន ដោយសារពេលវេលានេះកំណត់ណាស់ ដល់ពេលអ៊ីចឹងខ្ញុំមិនបានរៀបចំបញ្ជាំងនៅពេលនេះទេ បើសិនជាលោកប្រធានអនុញ្ញាត ខ្ញុំសួរបន្តតែម្តង។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញបន្ត!

[១១:២២:១០]

**លោក វ៉េង ហ៊ត់៖**

អរគុណលោកប្រធាន។

**សួរដោយលោក វ៉េង ហ៊ត់៖**

**ស៖** លោកសាក្សី ខ្ញុំសូមអនុញ្ញាតអានមួយសាទៀត ខ្លាចលោកភ្លេច -- ចាំបាទ អញ្ជើញ!

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** ខ្ញុំសូមជម្រាបថា ខ្មែរក្រហមគេមិនប្រើសម្ភារៈទំនើប ឧបករណ៍ទំនើបក្នុងការផ្សព្វផ្សាយនូវព័ត៌មាន ឬបទបញ្ជារបស់គេទេ។ ប៉ុន្តែខ្ញុំៗឆ្ងល់ដែរ វាអត់ប្រើអីទំនើបទេ ប៉ុន្តែការផ្សាយរបស់វាគឺឆាប់ៗ ពូណាស់ ឆាប់ដឹងតៗគ្នា។ ហេតុដូច្នេះបានជានៅថ្ងៃ២៣ហ្នឹង គឺថាទាំងមន្ត្រីជាប្រធានអង្គភាពរដ្ឋ ទាំងនាយទាហាន ទាំងអ្នកមុខអ្នកការ គឺឡើងឡានកាមីញ៉ុងទៅភ្នំពេញ ដែលគេនិយាយថាទៅទទួលសម្តេចឪបាទ។ ហើយក្រោយមកទៀតទេ ដែលខ្ញុំដឹងថា គេយកទៅបាញ់ចោលនៅភ្នំធិបដេ។

[១១:២៣:៣៤]

**ស៖** អរគុណលោក។ ខ្ញុំនឹងបន្តសំណួរទៅមុខទៀត នៅក្នុងឯកសារ ERN ជាភាសាខ្មែរ 00678769, ភាសាអង់គ្លេស 00369689 លោកបានសរសេរថា "ទោះបីបានដឹងសភាពការណ៍ជាមុនហើយក៏ដោយ ប្រជារាស្ត្រក្រុងបាត់ដំបងនៅតែការភ័យ និងភ្ញាក់ផ្អើលយ៉ាងខ្លាំងនៅពេលព្រលឹមស្រាងៗថ្ងៃទី២៥ ខែមេសា ឆ្នាំ១៩៧៥។ ពួកទាហានឯកសណ្ឋានខ្មៅ ជួតក្បាលក្រមា បាញ់កាំភ្លើង

ផ្លូងផាំង ព្រោងព្រាតឡើងទៅលើគ្រប់កន្លែងនៃទីក្រុង។ ចំណែកពួកវាផ្សេងទៀត ដើរទៅតាមផ្លូវមុខផ្ទះ ស្រែកសន្ធាប់ ខ្លាំងៗតាមប្រដាបបំពងសំឡេង។ ចេញពីផ្ទះៗ!!"។ ខ្ញុំសួរលោក តើលោកទទួលដំណឹងពីការជម្លៀសតាមរយៈសេចក្តីប្រកាសផ្លូវការជាមុនដែរទេ?

**ឆ៖** ដូចខ្ញុំបានជម្រាបលោកអ៊ីចឹង គឺថាជាមួយខ្មែរក្រហម គ្មានអ្វីជាផ្លូវការទេ។ ប៉ុន្តែវាមានប្រសិទ្ធភាពណាស់។

**ស៖** សំណួរទី២ តើលោកដឹងថាអ្នកណាបញ្ជាឲ្យទាហានឯកសណ្ឋានខ្មៅបាញ់កាំភ្លើងផ្លូងផាំង ស្រែសន្ធាប់ខ្លាំងៗឲ្យប្រជាជនចេញពីផ្ទះហ្នឹងទេ?

**ឆ៖** គឺគ្មាននរណាដឹងទេ បើគេនិយាយតែពី អង្គការថ្នាក់លើៗ តែប៉ុណ្ណឹង។

[១១:២៥:៥៥]

**ស៖** នៅក្នុងស្ថានភាពជាក់ស្តែង តើមានអ្នកណាពេលនោះចេញមុខមកថា ទទួលខុសត្រូវលើការជម្លៀសហ្នឹងដែរឬទេ?

**ឆ៖** បាទ អត់ឃើញមានទេ បាទ។ ឃើញតែកាំភ្លើងផ្លូងផាំងចេញពីផ្ទះហ្នឹង។ ឮតែកាំភ្លើងស្នូរកាំភ្លើងចេញពីផ្ទះគ្រប់គ្នា។

**ស៖** ឥឡូវនេះ ខ្ញុំនិយាយពីស្ថានភាពភ្លាមៗដែលលោកបានឃើញជាក់ស្តែង ស្តីពីការជម្លៀសដូចជាលោកឃើញមានមនុស្សធ្វើដំណើរ ក្មេងចាស់ជរា អ្នកជំងឺយ៉ាងដូចម្តេចដែរបាទ?

**ឆ៖** នៅក្រុងបាត់ដំបងហ្នឹង ការជម្លៀសមានច្រើនទិស បាទមានច្រើនទិស ហើយទិសខ្ញុំនេះ គឺខ្ញុំមិន -- ក្នុងក្រុមខ្ញុំហ្នឹង ទិសខ្ញុំហ្នឹង គឺខ្ញុំមានឃើញចាស់ៗដែរ ប៉ុន្តែមិនឃើញអ្នកណាដូចថាស្លាប់តាមផ្លូវ គ្មានទេ។

**ស៖** នៅក្នុងស្ថានភាពដែលបាញ់ផ្លូងផាំង ច្រងេងច្រងាងពេញផ្លូវអ៊ីចឹង តើមានក្រុមគ្រួសារណាហ៊ានប្រឆាំង មិនព្រមចេញពីផ្ទះទេនៅពេលនុ៎ង?

[១១:២៧:៤៥]

**ឆ៖** ខ្ញុំមិនបានដឹងទេ។ ប៉ុន្តែខ្ញុំជឿជាក់ថា ពួកហ្នឹងចេញទាំងអស់ ហើយសូមជម្រាបថា នៅ

បាត់ដំបង ការជម្លៀស គឺមួយសប្តាហ៍ក្រោយខ្មែរក្រហមឈ្នះកងទ័ព លន់ នល់ ១សប្តាហ៍។ ពុំមែនភ្លាមៗដូចនៅភ្នំពេញទេ។

**ស៖** នៅពេលដែលប្រជាជនដើរចេញពីផ្ទះ តើលោកបានឃើញព្រះសង្ឃត្រូវបានជម្លៀសចេញពីវត្តដែរឬទេ?

**ឆ៖** ព្រះសង្ឃបើតាមខ្ញុំឃើញ គឺក្រោយចូលឆ្នាំ៧៦ហើយទេ បានគេដេញលោកសង្ឃពីវត្ត។ គ្រាន់តែលោកសង្ឃមានចំនួនតិច។ ដល់៧៦ ក្រោយឆ្នាំ៧៦ គេដេញលោកសង្ឃចេញទាំងអស់។

**ស៖** ខ្ញុំសូមអានឯកសាររបស់លោកដដែល ERN ភាសាខ្មែរ 00678759, ឯកសារភាសាអង់គ្លេស 00369682។ លោកបានសរសេរថា "ដំណឹងមួយទៀតដែលគួរកាន់តែខ្លាចនោះ គឺការនាំចេញទៅក្រៅនៃព្រះចៅអធិការវត្តកំផែង ព្រះនាម អាចារ្យសាង។ អាចារ្យសាង ជាព្រះសង្ឃមួយអង្គដែលល្បីខាងទេសនា ប្រឆាំងសម្តេច សីហនុ និងកាន់ជើងរបបសាធារណរដ្ឋយ៉ាងខ្លាំងក្លា"។ សំណួររបស់ខ្ញុំគឺ ខ្ញុំចង់ដឹងថាតើអ្នកណាជាអ្នកនាំព្រះអង្គចេញទៅក្រៅដូច្នេះបាទ ហើយតើមូលហេតុអីដែលនាំព្រះសង្ឃចេញដូច្នេះ?

**ឆ៖** មុនថ្ងៃជម្លៀសប្រជារាស្ត្រខ្មែរក្រហមយកចេញទៅក្រៅ មិនមែនអាចារ្យ សាង តែម្នាក់មួយអង្គទេ គឺយកលោក ស៊ីវ ហេង ដែលត្រូវជាមា នួន ជា ដឹកឡានទៅ គាត់ពិការមួយចំហៀងខ្លួនផងដឹកទៅតាមផ្លូវទៅប៉ៃលិន។ ហើយក្រោយមកទៀតបានយកអាចារ្យ សាង។ ខ្ញុំមិនដឹងថា អ្នកណាៗបង្គាប់ឲ្យយកទេបាទ ព្រោះគេនិយាយសុទ្ធតែ ថ្នាក់លើៗ។

**ស៖** តើក្នុងហេតុការណ៍នេះលោកដឹងថា វាសនារបស់គាត់ ទាំងព្រះចៅអធិការ ទាំងលោក ស៊ីវ ហេង យ៉ាងម៉េចដែរចុងក្រោយ?

**ឆ៖** គេសម្លាប់ចោល។

**ប្រធានអង្គជំនុំ៖**

ឆ្លើយៗតបម្តងទៀត! មិញមីក្រូអត់ទាន់ប្រតិបត្តិការ។

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** បាទ តែខ្មែរក្រហមយកឡាន -- យកឡានដឹកចេញទៅក្រៅ គឺគេយកទៅសម្លាប់ចោលហើយ ទាំងលោក ស៊ីវ ហេង ទាំងអាចារ្យ សាង។

**លោក វ៉េង ហ៊ត់៖**

ខ្ញុំសូមអាន ERN ជាភាសាខ្មែរ 00678762, ភាសាអង់គ្លេស 00369685។ លោកសរសេរថា "សម្តេច ប៊ុន សំភាជ ជាគណៈសង្ឃខេត្ត និងចៅអធិការវត្តពោធិ៍វាល" យើងខ្ញុំចង់ដឹងថា សម្តេចសង្ឃ

ត្រូវបានជម្លៀសដែរទេ ក្រោយថ្ងៃទី១៧ មេសា? និងតើមានហេតុការណ៍អ្វីខ្លះចំពោះព្រះសង្ឃអង្គនេះ?

[១១:៣៣:០០]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាល់អាលឆ្លើយតប!

សូមអញ្ជើញលោកមេធាវី!

**លោក ហ្សាស្តេី ប៉ោ៖**

សូមអរគុណលោកប្រធាន។ ជាថ្មីម្តងទៀត បញ្ហាស្រដៀងគ្នានេះ ដូចដែលខ្ញុំបានលើកនៅខាងដើម ពាក់ព័ន្ធទៅនឹងប្រភពនៃការដឹងរបស់សាក្សីរូបនេះ។ ខ្ញុំនឹងនិយាយដោយត្រង់ៗតែម្តង ខ្ញុំជំទាស់ការសួរសំណួរបែបនេះ។ ការិយាល័យសហព្រះរាជអាជ្ញាមានកាតព្វកិច្ចផ្ទៀងផ្ទាត់ តើសាក្សីដឹងព័ត៌មានទាំងអស់នេះ ចេញមកពីប្រភពណា? នៅពេលដែលសាក្សីនិយាយថា បុគ្គលទាំងពីរនេះត្រូវបានគេសម្លាប់ចោល សហព្រះរាជអាជ្ញាត្រូវតែសាកសួរ តើគាត់បានឃើញ បានស្តាប់ឮ ប្រសិនបើស្តាប់ ឮស្តាប់ឮពេលនៅក្នុងពេលណា ឆ្នាំណាដែរ។

ហេតុអ្វីបានជាសហព្រះរាជអាជ្ញាមានកាតព្វកិច្ចធ្វើដូច្នេះ? សាក្សីអាចមានសិទ្ធិផ្តល់សក្ខីកម្មទៅលើអ្វីដែលខ្លួនបានឃើញ និងស្តាប់ឮតែប៉ុណ្ណោះ។ សហព្រះរាជអាជ្ញាមិនត្រូវ -- ដូច្នេះសហព្រះរាជអាជ្ញាត្រូវសួរថាសាក្សីនេះដឹងនៅពេលណា ហើយអង្គជំនុំជម្រះត្រូវធ្វើការផ្ទៀងផ្ទាត់ ថាតើការដឹងនេះគឺដឹងដោយខ្លួនឯងផ្ទាល់ បានស្តាប់ឮនៅពេលនោះ ឬក៏បានអានឯកសារតែប៉ុណ្ណោះ ហើយតើសាក្សីនេះដឹងប្រភពនេះមកពីណា។

ជាការពិត យើងខ្ញុំនឹងសួរបញ្ជាក់បំភ្លឺនៅក្នុងម៉ោងដែលយើងសួរទៅសាក្សីនេះ ក៏ប៉ុន្តែសហព្រះរាជអាជ្ញាមានកាតព្វកិច្ចត្រូវសួរ ថាតើព័ត៌មានទាំងអស់នោះដឹងមកពីប្រភពណា នៅពេលណា ដោយរបៀបណា។ ដូច្នេះ ខ្ញុំសូមជំទាស់នូវការតាំងសំណួរដោយមិនមានការបញ្ជាក់បំភ្លឺទៅដល់សាក្សី។ ខ្ញុំស្នើសុំ ទៅអង្គជំនុំជម្រះសាលាដំបូងឱ្យស្នើសុំទៅខាងសហព្រះរាជអាជ្ញា សួរទៅកាន់សាក្សី ថាសាក្សីបានឃើញហេតុការណ៍នេះ ឬក៏បានស្តាប់ឮហេតុការណ៍នេះ ប្រសិនបើស្តាប់ឮនោះ តើស្តាប់ឮនៅពីពេលណាដែរ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញលោកមេធាវី ម៉ៃខល កាណាវាស!

[១១:៣៥:១៦]

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន លោក លោកស្រចៅក្រម។ អរុណសួស្តីអស់លោក លោកស្រីទាំងអស់គ្នា។

ជាដំបូងខ្ញុំសូមគាំទ្រការសន្និដ្ឋាន និងការជំទាស់របស់ក្រុមមេធាវីការពារក្តី នួន ជា ហើយខ្ញុំក៏សូមបន្ថែមផងដែរ សាក្សីភាគច្រើននិយាយថា “ពួកគេនិយាយៗ” គាត់ឮពួកគេ ហើយសហព្រះរាជ-អាជ្ញាសួរសំណួរបន្ទាប់ ហើយមិនបានសួរថាតើ “ពួកគេ” នោះសំដៅលើអ្នកណាគេ។

ការជំទាស់មូលដ្ឋានរបស់ខ្ញុំនោះគឺថា យើងទំនងជា ខ្ញុំប្រើពាក្យថា “ទំនងជា” ដោយសារតែយើងមិនឃើញទេ យើងទំនងថានៅទីនេះប្រើប្រាស់ប្រព័ន្ធច្បាប់បារាំង។ ចៅក្រមត្រូវសួរសំណួរដើម្បីទាញយកចម្លើយឱ្យច្រើន បន្ទាប់មកអនុញ្ញាតឱ្យភាគីសួរបន្ត។ ក៏ប៉ុន្តែអង្គជំនុំជម្រះបានផ្តល់វេទិកានេះទៅដល់សហព្រះរាជអាជ្ញាជាអ្នកដឹកនាំការតាំងសំណួរ។ ដូច្នេះហើយសហព្រះរាជអាជ្ញាមានតួនាទីត្រូវសួរសំណួរឱ្យបានហ្មត់ចត់គ្រប់ទាំងអស់ ដែលចៅក្រមជាអ្នកធ្វើ។

[១១:៣៦:២៦]

ខ្ញុំសូមលើកឡើងនូវអ្វីដែលចៅក្រម ឡាវែន៍ លើកឡើងយោបល់របស់ខ្ញុំ។ បញ្ហានៅពេលនេះគឺថា សហព្រះរាជអាជ្ញាមិនអាចនិយាយមកកាន់យើងថា មេធាវីនោះអាចសួរដេញដោលនៅក្នុងពេលម៉ោងរបស់ខ្លួន។ បញ្ហានេះគឺថាយើងខ្ញុំមិនអាចមានសិទ្ធិដេញដោលសួរឆ្លងតទល់នោះទេ។ ដូច្នេះហើយគឺថានៅក្នុងប្រព័ន្ធនេះ អង្គជំនុំជម្រះនេះបែរជាបង្វែរតួនាទីរបស់ខ្លួនទៅឱ្យសហព្រះរាជអាជ្ញាជាអ្នកសួរឱ្យបានលម្អិតនូវព័ត៌មានទាំងអស់។

ហើយនៅពេលនេះគឺថាអង្គជំនុំជម្រះហាក់ដូចជាបង្វែរប្រព័ន្ធច្បាប់នេះ ឱ្យទៅជាប្រព័ន្ធច្បាប់ *អេដវើសសារៀល* គឺប្រព័ន្ធច្បាប់តទល់គ្នា។ ដូច្នេះសហព្រះរាជអាជ្ញាគឺមានតួនាទីតាមផ្លូវច្បាប់ក្នុងនាមក្នុងប្រព័ន្ធតទល់គ្នា ដើម្បីទាញយកព័ត៌មានទាំងអស់ ជៀសវាងតែព័ត៌មានដឹកមុខ។ ក្រោយមកគឺថាយើងនេះជួបប្រទះនូវបញ្ហាពេលវេលាខ្លី។ ចៅក្រម ឡឺម៉ុងដ៍ បានបញ្ជាក់នៅក្នុងសារព័ត៌មានរួចមក ហើយកាល -- អំពីបញ្ហានេះនៅក្នុងហ្នឹង។

[១១:៣៧:៤៤]

យើងដឹងហើយថានេះ គឺជានៅក្នុងប្រព័ន្ធមួយដែលអនុវត្តប្រព័ន្ធច្បាប់ស៊ីវិល ក៏ប៉ុន្តែយើងហាក់

ដូចជាប្រើប្រាស់ប្រព័ន្ធចម្រុះគ្នានៅទីនេះ។ ដូច្នេះប្រសិនបើអង្គជំនុំជម្រះមើលប្រតិចារឹកមុនៗនោះ គឺវាគ្រាន់តែជួយទៅដល់អង្គជំនុំជម្រះតែប៉ុណ្ណោះ ហើយអង្គជំនុំជម្រះត្រូវដឹងផង ហើយត្រូវយល់ថានៅពេលដែលនិយាយថា "ពួកគេ" នោះ គឺសំដៅទៅលើអ្នកណាគេដែរ។ ខ្ញុំយល់នៅទីនេះអនុវត្តប្រព័ន្ធស៊ីវិល។ នៅទីនេះគឺថាភស្តុតាងអាចចេញមកពីប្រភពច្រើន ក៏ប៉ុន្តែយ៉ាងណាក៏ដោយភស្តុតាងទាំងអស់ត្រូវតែផ្អែកទៅលើសញ្ញាបញ្ជាក់ជាឯករាជ្យ ដែលអាចយើងទុកចិត្តបាន។

ដូច្នេះហើយខ្ញុំសូមលើកឡើងថា សក្ខីកម្មចម្លើយរបស់សាក្សីនេះ គឺផ្អែកទៅលើការស្មានតែប៉ុណ្ណោះ ដោយគាត់លើកឡើងនៅក្នុងអត្ថន្តរថា "ពួកគេ"ៗ។ ដូច្នេះហើយការធ្វើដូច្នេះនេះ វាហាក់ដូចជាបដិសេធនូវសិទ្ធិរបស់យើងដោយផ្ទាល់ក្នុងការតទល់ទៅលើសាក្សី។

ដូច្នេះខ្ញុំគិតថាសហព្រះរាជអាជ្ញាមិនចំណាយពេលវេលាច្រើនទេ គ្រាន់តែសួរថា តើលោកដឹងដោយខ្លួនឯង ឬក៏ស្តាប់ពួគេ ប្រសិនជាស្តាប់ពួពីគេ តើនរណាគេ។ ហើយប្រសិនគាត់មិនដឹង មិនបញ្ហានេះទេ។ នេះគួរតែសហព្រះរាជអាជ្ញាធ្វើដូច្នេះ មិនទុកឲ្យយើងជាអ្នកសួរដេញដោលទៅលើ -- បញ្ជាក់ទៅលើបញ្ហានេះទេ។ នេះជាបញ្ហានៃការរៀបចំនីតិវិធី ហើយយើងដឹងហើយថាការធ្វើដូច្នេះគឺវានឹងដកពេលវេលារបស់យើងក្នុងការសួរបញ្ជាក់ ថាតើនរណាគេហ្នឹង ពួកគេហ្នឹងសំដៅលើនរណាគេ។ នេះជាកាតព្វកិច្ចរបស់សហព្រះរាជអាជ្ញា។

[១១:៣៩:៣៤]

២ថ្ងៃមុនលោក ស្មីត បាននិយាយថា "ហេតុអីបានខ្ញុំប៉ានធ្វើការសួរ ស្នើសុំឲ្យខាងសហព្រះរាជអាជ្ញាធ្វើការងារមួយចំនួន" ខ្ញុំព្យាយាម--

**ប្រធានអង្គជំនុំ៖**

លោកមេធាវីនិយាយឲ្យជាក់លាក់លើបញ្ហាជំទាស់នេះទៅ ព្រោះថ្ងៃនេះយើងបានកំណត់ធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីរូបនេះ។ វេទិកាដែលលោកអាចមាន គឺលោកអាចលើកឡើងនៅក្នុងអំឡុងពេលប្រជុំរៀបចំសវនាការ។ ហើយអង្គជំនុំជម្រះបានអនុវត្តតាមវិធានដែលមានចែង យើងបានជម្រាបជូនរួចហើយ។ វិធានដែលមានចែងគឺមាត្រា វិធាន៩១។ លំដាប់លំដោយនៃនីតិវិធីក្នុងការ -- នៅដំណាក់កាលនេះ កំណត់អំពីលំដាប់លំដោយក្នុងការសួរជនជាប់ចោទ សាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី។ នេះយើងបានប្រជុំពិភាក្សាគ្នារួចហើយ លើកិច្ចដំណើរការនៃនីតិវិធីនៅក្នុងកិច្ចរៀបចំកិច្ចដំណើរការសវនាការ។

ឥឡូវនេះ បើលោកមានបំណងធ្វើការជំទាស់ជាក់លាក់ណាមួយ សូមលោកកំណត់ព្រំដែននៃការជំទាស់របស់លោកឲ្យបានត្រឹមត្រូវ ឲ្យបានជាក់ច្បាស់ ដើម្បីអង្គជំនុំជម្រះមានមូលដ្ឋានពិចារណា។ ហើយប្រសិនបើលោកមានបំណងកែប្រែនូវកិច្ចដំណើរការរៀបចំសវនាការ លោកអាចដាក់ពាក្យស្នើសុំមកអង្គជំនុំជម្រះដើម្បីរៀបចំកែប្រែ ឬក៏កែប្រែទាំងវិធានផ្ទៃក្នុងដែលអង្គជំនុំជម្រះយកធ្វើជាមូលដ្ឋានក្នុងការយកមកពិភាក្សាដេញដោលនេះ។

[១១:៤១:១០]

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថា ខ្ញុំមានសិទ្ធិក្នុងការលើកឡើងនូវយោបល់សូមស្នើវិសោធនកម្មទៅលើវិធាន។ ក៏ប៉ុន្តែអ្វីដែលខ្ញុំលើកឡើង គឺគាំទ្រទៅលើការសន្និដ្ឋានជំទាស់របស់ក្រុមមេធាវីការពារក្តី ដែលបានលើកឡើងអម្បាញ់មិញនេះ។

សូមអរគុណលោកប្រធាន ដែលបានផ្តល់ឱកាសឲ្យយើងខ្ញុំឆ្លើយតប លើកសេចក្តីសន្និដ្ឋានជំទាស់ទៅលើបញ្ហានេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ចារីក៖**

សូមអរគុណលោកប្រធាន។ ប្រសិនបើខ្ញុំឆ្លើយតបមួយចំនួនពាក់កណ្តាលទៅលើការលើកឡើងរបស់ក្រុមមេធាវីការពារក្តីនោះគឺថា គ្មានការលើកឡើងណាមួយរបស់ខាងមេធាវីការពារក្តីមានមូលដ្ឋានទៅលើការជំទាស់ ការសួរសំណួររបស់សហព្រះរាជអាជ្ញានោះទេ គឺថា យើងបានព្យាយាមធ្វើការ -- ធ្វើយ៉ាងណាឲ្យមានការបង្ហាញការពិតនៅក្នុងការដេញដោលសាក្សីរបស់ខ្លួននេះហើយ។ សហព្រះរាជអាជ្ញាគឺថាមានសិទ្ធិក្នុងការធ្វើ និងលើកឡើងអំពីតម្លៃនៃភស្តុតាងរបស់ខ្លួនផងដែរ។ ហើយការជំទាស់របស់ខាងក្រុមមេធាវីការពារក្តីនេះគឺហាក់ដូចជាធ្វើប្រទាក់កថា អំពីរបៀបដែលយើងសួរទៅកាន់សាក្សី។

[១១:៤២:៣៦]

អង្គជំនុំជម្រះមានសិទ្ធិនឹង -- អាចពិចារណាទៅលើវិធាន៩១ នៃវិធានផ្ទៃក្នុងបាន។ ដូច្នេះហើយវាគ្មានអ្វីដែលវាមិនសមរម្យនៅក្នុងការតាំងសំណួររបស់យើងនោះទេ។ ក្រុមមេធាវីការពារក្តីនោះអាច

មានសិទ្ធិសួរបញ្ជាក់ទៅបាន មិនថាគាត់ថាប្រព័ន្ធនេះជាប្រព័ន្ធតទល់ ឬប្រព័ន្ធណាមួយនោះទេ។ ហើយគឺថា ក្រុមមេធាវីការពារក្ដីនោះបានអនុវត្ត និងធ្វើតាមទៅលើរបៀបនេះរួចមកហើយ ក្នុងរយៈពេល១២ខែចុងក្រោយ គ្មានការជំទាស់នោះទេ។ ហើយយើងក៏មិនមានការជំទាស់ទៅលើការតាំងសំណួរភាគច្រើន ដែលថាវាពេលខ្លះទៅមិនមានលក្ខណៈសមរម្យ និងសមស្របពីខាងក្រុមមេធាវីការពារក្ដីនោះដែរ។ សូមអរគុណលោកប្រធាន។

[១១:៤៣:១៣]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៤៥:៤៣]

**ប្រធានអង្គជំនុំ៖**

សេចក្ដីជំទាស់ និងសំអាងហេតុនៃសេចក្ដីជំទាស់របស់មេធាវីការពារក្ដីទៅនឹងរបៀបតាំងសំណួររបស់តំណាងសហព្រះរាជអាជ្ញា មិនមានមូលដ្ឋានត្រឹមត្រូវទេ។ នៅពេលនេះអង្គជំនុំជម្រះមិនលើកយកការវាយតម្លៃភស្ដុតាង នៅចំពោះមុខនេះមកពិភាក្សានោះទេ។ នេះគឺជាការដំណើរការស្ដាប់សក្ខីកម្មសាក្សី។ ដូច្នេះសេចក្ដីជំទាស់ហ្នឹងគ្មានប្រសិទ្ធភាពទេ។ ទន្ទឹមនឹងនេះដែរ អង្គជំនុំជម្រះក៏សូមរំឭកដល់តំណាងសហព្រះរាជអាជ្ញាផងដែរ សូមឲ្យរៀបចំនូវសំណួរបានជាក់ច្បាស់ ដើម្បីការប្រព្រឹត្តទៅមានប្រយោជន៍ និងមានប្រសិទ្ធភាពក្នុងការស្វែងរកការពិត ជៀសវាងការធ្វើសវនាការចប់ គឺលទ្ធផលគឺមិនមានអ្វីដែលជាប្រយោជន៍នៅក្នុងការយកមកពិចារណានោះ។

[១១:៤៦:៤៣]

**លោក វ៉េង ហ៊ាត់៖**

អរគុណលោកប្រធាន។

**សួរដោយលោក វ៉េង ហ៊ាត់៖**

**ស៖** សាក្សីលោក ឈុនលី លោកចាំសំណួរខ្ញុំមុននេះដែរទេ? ខ្ញុំសួរសំណួរលោកម្ដងទៀត។ លោកបានសរសេរថា "សម្ដេចសង្ឃ ប៉ុន សំភាជ ប្រធានគណៈសង្ឃខេត្ត និងជាចៅអធិការវត្តពោធិ៍វាល"។ សួរថាតើលោកដឹងថាសម្ដេចសង្ឃ ត្រូវបានគេជម្លៀសក្រោយថ្ងៃ១៧ ខែមេសា ហើយលោកដឹងថាមានហេតុការណ៍អ្វីកើតឡើងចំពោះព្រះអង្គដែរទេ?

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** សម្ដេច ប៉ុន សំភាជ លោកជម្លៀសទៅភូមិកំណើតរបស់លោកឈ្មោះអូរដំបង ឃុំអូរដំបង បាទ។ ហើយក្រោយមក ខ្ញុំជួបអតីតសង្ឃម្នាក់ គាត់ប្រាប់ខ្ញុំថា ខ្មែរក្រហមបាននាំលោកយកទៅទាំងចីពររបាត់ខ្លួនហើយបាទ។

**ស៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

[១១:៤៨:២៤]

**ប្រធានអង្គជំនុំ៖**

បើកក្បាលមីក្រូហ្វូន!

**សួរដោយលោក វ៉េង ហ៊ាត់៖**

**ស៖** ខ្ញុំនៅសំណួរមួយចុងក្រោយ តែមានតូចៗនៅក្នុងនេះ។ នៅក្នុង ERN 00678813, ភាសាអង់គ្លេស 00369721 ទៅដល់ 22។ ក្នុងនោះលោកសរសេរថា “នោះគឺ ខៀវ សំផន បណ្ឌិតវិទ្យាសាស្ត្រសេដ្ឋកិច្ច ចេញពីមហាវិទ្យាល័យនៅទីក្រុងប៉ារីស។ ខៀវ សំផន អានរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រ អ៎ ! នៃកម្ពុជាប្រជាធិបតេយ្យ ដែលមានតែ២៥មាត្រា។ ក្នុងនោះមានពីរមាត្រា ដែលខ្ញុំចាំជាងគេ។ មាត្រាមួយនោះចែងថា “ពលរដ្ឋកម្ពុជាទាំងពីរភេទ មានសិទ្ធិជឿ ឬមិនជឿសាសនា”។ ចំណែកមាត្រាមួយទៀតចែងថា “ពលរដ្ឋកម្ពុជាទាំងពីរភេទ មានសិទ្ធិមានការងារធ្វើគ្រប់ៗគ្នា”។ ខ្ញុំចង់សួរលោកថា តើលោកប្រាកដទេថា ខៀវ សំផន អានរដ្ឋធម្មនុញ្ញ ហើយលោកស្គាល់ ខៀវ សំផន នេះដែរឬទេ?

**ឆ៖** ខ្ញុំស្គាល់ ខៀវ សំផន នៅពេលដែលគាត់ធ្វើការនៅភ្នំពេញ ក្នុងឋានៈជាប្រធានកាសែតអុបសេវាទ័រ។ ហើយចំពោះរឿងដែលលោកនិយាយអំមិញនេះ គឺទាក់ទងនឹងសម្ដេច សីហនុ ដែរ គឺពេលនោះខ្មែរក្រហម នៅមន្ទីរពេទ្យឃោធាខ្មែរក្រហម ដែលខ្មែរក្រហមហៅខ្ញុំទៅធ្វើការ។ ខ្មែរក្រហមបានបើកវិទ្យុខ្លាំងៗ ហើយហៅបុគ្គលិកមកស្ដាប់។ មុនហ្នឹង អ្នកនិយាយដំបូងគឺសម្ដេច សីហនុ លោកនិយាយជាភាសាខ្មែរ “សុំលាលែងពីតួនាទីប្រមុខរដ្ឋ”។ ក្រោយមកទៀត លោកជាភាសាបារាំង។

[១១:៥១:១៨]

បន្ទាប់មកបាន ខៀវ សំផន ត្រូវតែងតាំងជាប្រធានគណៈប្រធានរដ្ឋ។ ហើយ ខៀវ សំផន អានរដ្ឋធម្មនុញ្ញ និងមាត្រា២ ដែលលោកមានប្រសាសន៍អម្បាញ់មិញហ្នឹង ដែលខ្ញុំមិនអាចភ្លេចបានមាត្រា។

**ស៖** អរគុណលោក។ បន្ទាប់ពីលោក ខៀវ សំផន ប្រកាសថា "ពលរដ្ឋកម្ពុជាទាំងពីរភេទមានសិទ្ធិជឿ ឬមិនជឿសាសនានោះ" តើក្រោយមក ប្រជាជន ហើយអាចប្រតិបត្តិតាមជំនឿសាសនាដោយសេរី ដូចការប្រកាសរបស់គាត់បានដែរឬទេ?

**ឆ៖** ដូចខ្ញុំបានជម្រាបលោករួចហើយថា នៅបាត់ដំបង ចាប់ពីចូលឆ្នាំខ្មែរ ឆ្នាំ១៩៧៦ ព្រះសង្ឃត្រូវដេញចេញទាំងអស់ពីវត្ត។

**ស៖** ចុះចំពោះអ្នកប្រតិបត្តិសាសនាគ្រិស្ត តើមានការដេញចេញពីវត្ត ដូចព្រះពុទ្ធសាសនាដែរទេ បាទ?

[១១:៥២:៥១]

**ប្រធានអង្គជំនុំ៖**

ឈប់កុំអាលទាន់ឆ្លើយ!

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** នៅបាត់ដំបងក្រុងមានព្រះវិហារគ្រិស្តមួយយ៉ាងធំ ហើយខ្មែរក្រហមបានវ៉ៃកម្ទេចចោលសូម្បីតែថ្មមួយដុំ ក៏មិនសល់ ក៏មើលមិនឃើញដែរ រាបស្មើតែម្តង។

**ស៖** ចុះមេសាសនាគ្រិស្ត តើលោក--

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប! កុំអាលទាន់ឆ្លើយ រង់ចាំក្បាលមីក្រូហ្វូន ប្រតិបត្តិការសិន ណ៎ា!

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** ចំពោះប្រធានសាសនាគ្រិស្តឈ្មោះ សម្តេច ទេព ប៉ូលអ៊ីម។ ខ្ញុំមិនបានឃើញទេ ប៉ុន្តែគឺគេសម្លាប់លោក ហើយខ្ញុំដឹងថា ខាងគ្រិស្តសាសនា គេនឹងសង់សាលារៀនមួយ នៅកន្លែងដែលគេបាញ់លោកចោល នៅភូមិចំណោម ស្រុកមង្គលបុរី។

**លោក វ៉េង ហ៊ាត់៖**

អរគុណលោក។ សំណួររបស់ខ្ញុំចប់ហើយ ហើយអរគុណដែលលោក ឈុនលី បានជួយការិយាល័យសហព្រះរាជអាជ្ញា ប៉ុន្តែការិយាល័យនៅមន្ត្រីយើងសួរលោកបន្ថែមទៀត។ អរគុណលោកប្រធាន ខ្ញុំចប់ អស់សំណួរហើយ។

[១១:៥៥:២៤]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** អរុណសួស្តីលោកវេជ្ជបណ្ឌិត ឈុនលី។ សហសេវិករបស់ខ្ញុំបានណែនាំខ្ញុំរួចមកហើយ ខ្ញុំឈ្មោះ ថារីក អាប់ឌុលឡាក់។ ខ្ញុំតំណាងខាងតំណាងសហព្រះរាជអាជ្ញាផងដែរ ហើយខ្ញុំនឹងសួរលោកនៅក្នុងព្រឹកនេះ។ ដោយសារតែពេលវេលាខ្លីមុនពេលឈប់សម្រាកនេះ ប្រសិនបើខ្ញុំអាចសុំសួរលើហេតុការណ៍ថ្ងៃ១៧ ខែមេសា និងពីរបីថ្ងៃ ឬក៏ប៉ុន្មានថ្ងៃក្រោយថ្ងៃ១៧ ខែមេសា ដូចដែលលោកបានរៀបរាប់សរសេរនៅក្នុងសៀវភៅរបស់លោក។ ប្រសិនបើខ្ញុំអាចឲ្យលោក -- ប្រសិនបើអាចនោះគឺខ្ញុំសូមឲ្យលោកមើលអត្ថបទមួយចំនួន -- ទំព័រមួយចំនួននៅក្នុងសៀវភៅរបស់លោក គឺត្រង់ខ្មែរ ERN លេខ 00678765, អង់គ្លេសគឺ 00369686។ ហើយនៅត្រង់ផ្នែកនោះគឺថា មានការរៀបរាប់អំពីការប្រជុំមួយ ដែលបានរៀបចំឡើងថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ នៅក្នុងមន្ទីរពេទ្យស៊ីវិលមួយ នៅក្នុងខេត្តបាត់ដំបង។ ខ្ញុំនឹងអានចំណុចមួយ ឬក៏ពីរប៉ុណ្ណោះឲ្យលោកស្តាប់ លោកនិយាយថា ខែក ប៉ែន ហៅ មិត្តស៊ូ បានចូលមកមន្ទីរពេទ្យខេត្តបាត់ដំបង ពេទ្យស៊ីវិល ជួបពិភាក្សាយ៉ាងខ្លីជាមួយនឹងវេជ្ជបណ្ឌិត ពីង គឹមស៊ា ប្រធានសុខាភិបាលខេត្ត និងវេជ្ជបណ្ឌិត យឹម គឹមសាន ប្រធានមន្ទីរពេទ្យខេត្ត។ បន្ទាប់មក ខ្ញុំសូមរៀបរាប់ លោក មិត្តស៊ូ នេះជាអ្នកធ្វើជាប្រធានក្នុងពេលប្រជុំ។ លោកបានលើកឡើងថា មិត្តស៊ូ នេះធ្វើសុន្ទរកថា គាត់បានលើកឡើងដូចតទៅថា “អង្គការឲ្យមានការដកប្រធានពេទ្យចាស់ ហើយធ្វើការជ្រើសរើសពេទ្យថ្មី ប្រធានពេទ្យថ្មីមួយរូប យកអ្នកមកពីវណ្ណៈកសិករ”។ លោកបានចូលរួមនៅក្នុងកិច្ចប្រជុំនេះ។ ដូច្នេះ ខ្ញុំសូមសួរលោក ឲ្យលោកបង្ហាញទៅមើល៍ ថាតើគេមានហេតុផលអ្វីដែលគេដកវេជ្ជបណ្ឌិត យឹម គឹម សាន ឈប់ឲ្យធ្វើជាប្រធានមន្ទីរពេទ្យនោះ? តើមានហេតុផលអ្វីដែរ ដែលគេដកគាត់ចេញ?

[១១:៥៨:៥១]

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** ខ្ញុំសូមជម្រាបថា មិត្តស៊ូ នេះ ឈ្មោះគាត់ ឈ្មោះដើមគាត់ ខែក ប៉ែន។ គាត់ជាអតីតសាស្ត្រាចារ្យ ដែលធ្លាប់បង្រៀននៅវិទ្យាល័យនៅតាមខេត្ត។ ដូច្នេះ គាត់ជាបញ្ញវន្តមួយរូបដែរ មិត្តស៊ូ នេះ ហើយនៅពេលដែលគាត់ប្រជុំនោះ នៅពេលគាត់ហៅបុគ្គលិកពេទ្យមកប្រជុំនោះ ខ្ញុំមិនយល់ដែរ បុគ្គលិកពេទ្យទាំងអស់ក៏មិនយល់ ហើយក៏មិនប៊ានសួរទៀត។ ត្រង់ថា គាត់ថា “បដិវត្តចេញពីវណ្ណៈ

កសិករ ដូច្នេះសុខាភិបាល -- ដូច្នេះវណ្ណៈកសិករអាចដឹកនាំអ្វីទាំងអស់ រួមទាំងវិស័យសុខាភិបាលផង”។ ដូច្នេះហើយបានជាគាត់ថាត្រូវរំលាយចេញ ហើយឲ្យជ្រើសរើសកម្មករម្នាក់ធ្វើជាប្រធានមន្ទីរពេទ្យ ជំនួសគ្រូពេទ្យដែលមានវិជ្ជាជីវៈ។ ប៉ុន្តែគាត់ជ្រើសរើសអ៊ីចឹងមែន សូម្បីតែកម្មករដែលត្រូវជ្រើសរើស ក៏គាត់មិនជាសប្បាយចិត្តដែរ។ ហើយបន្ទាប់ពីគាត់ជ្រើសរើសទៅ ស្អែកឡើងជម្លៀសៗទៅស្រែវិញ ដដែល គ្មានបានការ។ ខ្ញុំមិនយល់ដែរ។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំមើលឃើញពេលវេលាដូចជាដល់ ដូច្នេះតើលោកប្រធានចង់ឲ្យខ្ញុំសម្រាក ឬក៏ខ្ញុំ បន្តទៅមុខទៀត?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះ ដល់ពេលសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ហើយ អង្គជំនុំជម្រះ ប្រកាសសម្រាកដើម្បីពិសាថ្ងៃត្រង់ ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីកិច្ចដំណើរការសវនាការ។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែង សម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សីអ្នកជំនាញដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលសម្រាកពិសា អាហារថ្ងៃត្រង់ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញ នៅវេលាម៉ោងមួយ សាមសិបនាទី។

សម្រាកចុះ!

បាទ សូមអញ្ជើញលោកមេធាវី!

[១២:០១:២៤]

**លោក ហ្សាស្តេ ប៉ោះ៖**

សូមអរគុណលោកប្រធាន។ លោក នួន ជា ឈឺក្បាល ឈឺចង្កេះ និងមិនអាចផ្តង់អារម្មណ៍ បាន។ ដូច្នេះ ស្នើសុំតាមដានចូលរួមសវនាការនីតិវិធីនេះពីបន្ទប់ខាងក្រោម។ យើងខ្ញុំនឹងដាក់លិខិតបោះ បង់សិទ្ធិជូនលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានស្តាប់សំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានធ្វើឡើង តាមរយៈ មេធាវីការពារក្តីរបស់គាត់ ស្នើសុំទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ សម្រាប់រយៈពេលធ្វើ

សវនាការពេញមួយរសៀលថ្ងៃនេះ ដោយមូលហេតុបញ្ហាសុខភាពមិនអាចអង្គុយយូរ តាមដានក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការបាន។ សំណើសុំរបស់លោក នួន ជា ធ្វើឡើងមានមូលហេតុសមស្រប អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យលោក នួន ជា ទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់រយៈពេលធ្វើសវនាការពេញមួយរសៀលថ្ងៃនេះ ដោយលោក នួន ជា បានលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ ក្នុងកិច្ចដំណើរការសវនាការក្នុងបន្ទប់សវនាការនេះ។ អង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្តីលោក នួន ជា ប្រគល់មកឲ្យអង្គជំនុំជម្រះភ្លាមនូវពាក្យសុំលះបង់សិទ្ធមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ដោយមានចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃយ៉ាងជាក់ច្បាស់របស់លោក នួន ជា។

[១២:០២:៥៥]

ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ សម្រាប់លោក នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក នួន ជា និងលោក ខៀវ សំផន ទៅកាន់បន្ទប់ឃុំខ្លួនខាងក្រោម ដោយនៅរសៀលនេះទុកឲ្យលោក នួន ជា នៅក្នុងបន្ទប់ដែលរៀបចំទុកជាស្រេច នូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ ដោយឡែក លោក ខៀវ សំផន ឲ្យនាំខ្លួនគាត់ត្រឡប់មកកាន់បន្ទប់សវនាការនេះវិញឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១២:០៣ នាទី ដល់ម៉ោង ១៣:៣១ នាទី)*

[១៣:៣១:១៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ សួស្តីលោក លោកស្រីចៅក្រម ភាគីទាំងអស់ និងលោកវេជ្ជបណ្ឌិត ឈុនលី។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** មុនពេលឈប់សម្រាកយើងបានពិភាក្សាគ្នា អំពីកិច្ចប្រជុំមួយដែលលោកបានចូលរួមប្រជុំនៅក្នុងអតីតមន្ទីរពេទ្យស៊ីវិលមួយក្នុងខេត្តបាត់ដំបង ហើយលោកបានលើកឡើងថា មានការតែងតាំងប្រធានថ្មី។ ក្នុងកិច្ចប្រជុំនោះមាន ខែក ប៉ែន ហៅ មិត្តស៊ូ ជាប្រធានដឹកនាំប្រជុំតាមអ្វីដែលលោកឆ្លើយ។ ដើម្បីសួរបញ្ជាក់ឡើងវិញ កត់ត្រាក្នុងប្រតិចារឹក តើលោកដឹងទេថាលោក មិត្តស៊ូ នេះ មិត្តស៊ូ ហ្នឹង គាត់មានតួនាទីអ្វីដែរក្នុងសម័យខ្មែរក្រហម?

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** ក្នុងសម័យខ្មែរក្រហម មិត្តស៊ូ ឈ្មោះគាត់ ឈ្មោះដើមហៅថា ខែក ប៉ែន គាត់ជាប្រធានតំបន់៤។

[១៣:៣២:២២]

**ស៖** សូមអរគុណ។ ខ្ញុំនឹងសួរសំណួរមួយចំនួនទៀត ពាក់ព័ន្ធទៅនឹងស្ថានភាពនៅក្នុងខេត្តបាត់ដំបង ចន្លោះថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ និងថ្ងៃ២៥ ខែមេសា ឆ្នាំ១៩៧៥ ដែលលោកនិយាយថានៅពេលនោះមានការជម្លៀសខេត្ត។ ហើយបន្ទាប់មក ខ្ញុំនឹងមើលប្រធានបទមួយចំនួនដែលលោកបានឆ្លើយផងដែរ។ លោកបានជម្រាបសហព្រះរាជអាជ្ញាជាតិ លោករៀបរាប់ប្រាប់សហព្រះរាជអាជ្ញាជាតិអំពីការបាត់ខ្លួនបុគ្គលិកពេទ្យចំនួន១៣នាក់ ដែលធ្វើការនៅក្នុងមន្ទីរពេទ្យខេត្តបាត់ដំបង។ ដើម្បីបញ្ជាក់បំភ្លឺ តើលោកដឹងមកពីណា ដែលសរសេរនៅក្នុងចំណុចមួយក្នុងសៀវភៅរបស់លោកនោះ គឺថាចំណុចនេះគឺបានសរសេរឡើងនៅក្នុងខ្មែរ ERN លេខ 00678768, អង់គ្លេស 00369688។ អ្វីដែលលោករៀបរាប់នៅក្នុងនោះ លោកវេជ្ជបណ្ឌិត ឈុនលី គឺការដែលលោកនិយាយជជែកជាមួយនឹងម្តាយរបស់លោក ដែលម្តាយរបស់លោកនោះ បានលើកឡើងប្រាប់លោកថា គាត់បានទៅនិយាយជាមួយនឹងម្តាយរបស់បុគ្គលិកពេទ្យម្នាក់ ដែលក្នុងចំណោម១៣នាក់ត្រូវបានគេយកទៅសម្លាប់ចោលនោះ។ ហើយម្តាយរបស់ខ្មោចបុគ្គលិកពេទ្យម្នាក់ ដែលស្លាប់នោះគឺថា គាត់ប្រាប់ថា ត្រូវបានឃើញខ្មោចកូនរបស់គាត់។ ហើយតើលោកអាចរៀបរាប់ទេ តើលោកបានជជែកជាមួយនឹងម្តាយរបស់លោកលើបញ្ហានេះនោះ

ពាក្យពេចន៍ ដែលលោកនិយាយនោះគឺ លោកបាននិយាយអំពីអ្វីខ្លះ?

[១៣:៣៥:៣៦]

**ឆ៖** នៅថ្ងៃ២១ ខែមេសា ១៩៧៥ នៅវេលាម៉ោងប្រាំព្រឹក គឺបុគ្គលិកពេទ្យ ពួកខ្មែរក្រហមបានឲ្យពេទ្យទាហានចាប់ពីស័ក្តិ១ ឡើងទៅចំនួន១៣នាក់ យកទៅតាមផ្លូវទៅប៉ៃលិន រួចឲ្យចុះពីឡានយកទៅបាញ់ចោលទាំងអស់បាទ បាញ់ចោលទាំងអស់។ នេះគឺជា អ្វីដែលខ្ញុំមិនអាចភ្លេចបាន។ ហើយខ្ញុំរួចខ្លួនក៏ដោយសារថៃដន្យដែរ។ ហើយចំពោះម្តាយខ្ញុំវិញ គាត់បានដាស់តឿនខ្ញុំជាញឹកញាប់ ពីព្រោះគាត់តែងអញ្ជើញទៅវត្តនៅថ្ងៃសីល ហើយពេលទៅវត្តគាត់តែងជួបយាយៗ ដែលរត់ចេញពីតំបន់ខ្មែរក្រហម គាត់ថាវេទនាណាស់នៅតំបន់ខ្មែរក្រហមហ្នឹង គឺថាពួកខ្មែរក្រហមបង្ខំកូនចៅឲ្យចូលធ្វើទាហាន យកស្រូវអង្ករ ហើយអ្នកណា គេចោទថា អ្នកណាថាក្បត់គេសម្លាប់ចោល។ គាត់ប្រាប់ខ្ញុំថា កុំឲ្យនៅស្រុកខ្មែរ ឲ្យចេញទៅ ខ្ញុំមិនជឿគាត់ ហើយបានចុងក្រោយខ្ញុំមានការខ្មាសអៀនណាស់ ម្តាយខ្ញុំយល់ថាម្តាយខ្ញុំគាត់មានប្រាជ្ញាជាងខ្ញុំ។ ហើយចំពោះលោកនិយាយដែលថា គាត់ទៅមើលកូនគាត់ដែលស្លាប់នោះ គឺគាត់ខំប្រមូលអារម្មណ៍ ហើយបានរឹងប៉ឹង ហើយគាត់ដើរទៅដល់កន្លែងសពគាត់ –តាមគាត់និយាយប្រាប់ម្តាយខ្ញុំបាទ– គាត់ថាទៅគាត់យកធូបដាក់លើដៃកូនអ៊ីចឹង ដាក់លើទ្រូងកូនអ៊ីចឹង ហើយឲ្យពរកូន ហើយគាត់ត្រឡប់មកផ្ទះវិញ។

**ស៖** សូមអរគុណ។ ពេទ្យទាហាន១៣នាក់ ដែលធ្វើការនៅក្នុងមន្ទីរពេទ្យនោះ តើលោកស្គាល់អ្នកទាំង១៣ នុ៎ងដែរឬទេ?

**ឆ៖** សុទ្ធតែជាសហការីរបស់ខ្ញុំ។

**ស៖** ខ្ញុំសួរសំណួរលោកមួយទៀត។ តើលោកធ្លាប់ជួបអ្នកទាំងបីនោះដែរឬទេ ក្រោយពីពួកគេបាត់ខ្លួននោះ? បាទសូមកែតម្រូវ តើលោកធ្លាប់ជួបអ្នកទាំង១៣ ពេទ្យទាហានទាំង១៣នាក់នោះដែរឬទេក្រោយពីពួកគេបាត់ខ្លួន។

[១៣:៣៨:៥៦]

**ឆ៖** បាទ បាញ់ចោលនៅវាលស្រែទាំងអស់។ បាញ់ចោលនៅវាលស្រែទាំងអស់ នៅហៅថាភូមិ ឃុំអូម៉ាល់ នៅទាល់មុខស្ថានីយកសិកម្មខេត្ត។ ខ្ញុំជួបតែប្រពន្ធ ប្រពន្ធជួប ហើយប្រពន្ធខ្លះនៅស្រុកក្រៅ ខ្លះនៅស្រុកខ្មែរ។

**ស៖** ដើម្បីបញ្ជាក់ ថាតើខ្ញុំស្តាប់ឮអង្គហេតុនេះត្រឹមត្រូវដែរឬទេ។ អ្នកជាពេទ្យទាហានទាំង

១៣នាក់ ដែលត្រូវគេយកចេញទៅបាត់នោះគឺថា ក្រោយមកលោកមិនដែលធ្លាប់ជួបឃើញពួកគេទៀតទេ តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ ជាការពិត គឺបាត់សូន្យតែម្តង។

**ស៖** សូមអរគុណ។ ចំណុចមួយទៀតដែលខ្ញុំចង់សួរឡើងផងដែរគឺថា ខ្ញុំនឹងសួរដោយខ្លីៗ និងសង្ខេបតែប៉ុណ្ណោះ។ លោកបានរៀបរាប់អំពីការបាត់ខ្លួនរបស់បុគ្គលម្នាក់ឈ្មោះ ស៊ីវ ហេង ជាសាច់ញាតិរបស់ នួន ជា។ ហើយខ្ញុំនឹងអានអត្ថបទចំណុចមួយនៅក្នុងសៀវភៅរបស់លោកត្រង់ខ្មែរលេខ ERN 00678758 ទៅដល់ 59, អង់គ្លេស 00369682 លោកបាននិយាយដូចតទៅនេះថា៖ "យើងបានឮថានៅជិតបាត់ដំបងនោះ គឺមានខ្មែរក្រហមនោះបានប្រមូលយកចាប់ ស៊ីវ ហេង ដាក់លើឡាន។ ហើយបន្ទាប់មកបានបើកដឹកនាំគាត់ បើកទៅតាមផ្លូវទៅប៉ៃលិន"។ ហើយក្រោមនេះគឺថា "ស៊ីវ ហេង ជាអតីតអ្នកតស៊ូខ្មែរជាន់ខ្ពស់ម្នាក់ប្រឆាំងអាណានិគមបារាំងតាំងពីអំឡុងឆ្នាំ១៩៤០ ដោយបានសហការជាមួយនឹងអ្នកតស៊ូឡាវដឹកនាំឲ្យទ្រង់ សុផានុវង្ស និងអ្នកតស៊ូវៀតណាមដឹកនាំដោយ ហូ ជីមិញ បន្ទាប់ពីសន្និសីទអន្តរជាតិនៅទីក្រុងហ្សឺណែវឆ្នាំ១៩៥៤ ដែលបានបញ្ចប់សង្គ្រាមនៅឥណ្ឌូចិនមកលោក ស៊ីវ ហេង បានចុះចូលជាមួយនឹងព្រះមហាក្សត្រនរោត្តម សីហនុ ហើយបានបម្រើកងទ័ពខេមរភូមិន្ទក្នុងឋានៈជាវរសេនីយ៍ឯក។ គេគ្មានសង្ស័យឡើយអំពីវាសនាលោក ស៊ីវ ហេង និងកូនរបស់គាត់ ពីព្រោះខ្មែរក្រហមចាត់ទុកជានិច្ចថាជាខ្មាំងចំពោះអ្នកបោះបង់ចោលជួរ ឬក្បត់បដិវត្តន៍"។

[១៣:៤២:០២]

ខ្ញុំសូមសួរលោកសិន តើលោកដឹងថា -- ថាតើលោកហេតុអ្វីបានជាដឹងថាលោក ស៊ីវ ហេង នេះគឺជាទាហាន ជាវរសេនីយ៍ឯកមួយរូបនៅក្នុងជួរកងទ័ពខេមរភូមិន្ទ នៅក្នុងសម័យសីហនុ នោះ តើលោកដឹងរបៀបណាដែរ?

**ឆ៖** ខ្ញុំក្នុងឋានៈជាបញ្ញវន្តមួយរូប ខ្ញុំដឹងពីៗព្រឹត្តិការណ៍នេះ។ បាទ លោក ស៊ីវ ហេង គឺថាគាត់ៗអ្នកតស៊ូជើងចាស់ ហើយបន្ទាប់ពីកុងហ្សឺរ៉ង់ហ្សេ -- បន្ទាប់ពីសន្និសីទទីក្រុងហ្សឺណែវ គាត់បានមកចុះចូលសម្តេច សីហនុ។ សម្តេច សីហនុ បានឲ្យគាត់ពាក់ៗស័ក្តិប្រាំជាវរសេនីយ៍ឯកបាទ។ ហើយខ្ញុំក៏ស្គាល់ប្រពន្ធគាត់ទៀតបាទ។ ហើយប្រពន្ធៗ ស៊ីវ ហេង នេះត្រូវជាប្អូនប្រពន្ធ នួន ជា។

**ស៖** សូមអរគុណ។ យើងនឹងត្រឡប់មកនិយាយអំពីឃុំគរ -- ឃុំវត្តគរនេះ នៅពេលក្រោយ។ ក្នុងពេលដែលយើងពិភាក្សាគ្នាអំពីអំឡុងថ្ងៃទី១៧ មេសា ទៅដល់ ថ្ងៃ២៥ ខែមេសា ឆ្នាំ១៩៧៥ នេះ គឺខ្ញុំ

ចង់សួរលោកនូវអត្ថបទ និងចំណុចមួយនៅក្នុងសៀវភៅរបស់លោកត្រង់ៗជំពូកដែលមុននិយាយអំពីការជម្លៀស។

[១៣:៤៥:០៩]

ខ្មែរ ERN គឺ 00678768, អង់គ្លេស 00369688។ លោកបានសរសេររៀបរាប់នៅក្នុងនោះថា "យើងមន្ត្រីរដ្ឋាភិបាលប្រហែលជាមានចំណេះដឹងអំពីមនោគមវិជ្ជា និងការឃោសនារបស់ខ្មែរក្រហម។ យើងសង្ឃឹមថា យើងអាចចូលរួមក្នុងការកសាងប្រទេសក្រោមការដឹកនាំ។ ហើយយើងជឿថានឹងមានការវិវត្តរីកចម្រើនជឿនលឿន និងស្អាតស្អំ"។ ខ្ញុំសូមសួរលោកបន្តិចទៅលើចំណុចនេះជាពិសេសហេតុអ្វីបានជាលោកនិយាយថា លោកត្រូវបានខ្មែរក្រហមបោក? ជាពិសេសនៅក្នុងសម័យនោះ មុនពេលដែលជម្លៀស មានការជម្លៀសនោះ ឬក៏ប្រហែលជាអាចនៅក្នុងអំឡុងពេលក្រោយជម្លៀសនោះ ហេតុអ្វីបានជាលោកថាលោក ចាញ់បោកការឃោសនារបស់ខ្មែរក្រហម?

**ឆ៖** បាទ ពេលនោះៗ ខ្មែរយើងមួយចំនួនជាពិសេសយុវជន គឺថាមានជំនឿជឿជាក់យ៉ាងខ្លាំងទៅលើ ខៀវ សំផន, ហ៊ូ យន់, ហ៊ូ នឹម ដែលយើងចាត់ទុកថាជាមនុស្សស្អាតស្អំបាទ។ ចំពោះ -- ហេតុដូច្នេះបានជាម្ដាយខ្ញុំនិយាយប្រាប់រឿងពិតយ៉ាងណាៗ ខ្ញុំមិនជឿទេបាទ ដល់ក្រោយមកឃើញវាអ៊ីចឹងបានខ្ញុំមានការខកចិត្ត មិនដឹងយល់ថាម៉េចបានគេទៅជាអ៊ីចឹងវិញ។

[១៣:៤៦:១៩]

**ស៖** ខ្ញុំសូមសួរអំពីការជម្លៀសវិញម្ដង។ លោកបានរៀបរាប់ និយាយអំពីទិដ្ឋភាពនៃការជម្លៀសខ្លួននោះរួចមកហើយ ហើយខ្ញុំគ្រាន់តែចង់សួរលម្អិតជាងមុនបន្តិចតែប៉ុណ្ណោះ។ ត្រង់ខ្មែរ ERN 00678869, អង់គ្លេសគឺ 00369689។ ជំពូក ក្នុងជំពូកទី២ នៃសៀវភៅរបស់លោកដែលហៅថា "ជម្លៀសចេញពីទីក្រុង" ដែលមានចំណងជើងថា "ជម្លៀសចេញពីទីក្រុង"។ លោកបាននិយាយអំពី "ព្រឹកថ្ងៃទី១៨ ខ្មែរក្រហមស្លៀកពាក់ខ្មៅ ហើយមានចងជួតក្បាលផងនោះ បានមកក្នុងទីក្រុង ហើយមានអ្នកខ្លះដើរចុះដើរឡើងនៅតាមផ្លូវមុខផ្ទះរបស់យើង ស្រែកឲ្យយើងចេញពីផ្ទះ!ៗ"។ តើខ្ញុំសូមសួរលោកនេះ តើព្រឹត្តិការណ៍នេះលោកឃើញផ្ទាល់ភ្នែករបស់លោកខ្លួនឯងនៅថ្ងៃ -- នៅក្នុងខែមេសាឆ្នាំ១៩៧៥ ឬក៏ឃើញ -- មិនឃើញផ្ទាល់ភ្នែកនោះទេ?

[១៣:៤៧:៥០]

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

ក្បាលមីក្រូអត់ទាន់ប្រតិបត្តិការទេបាទ។

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** បាទ នៅបាត់ដំបងនេះ គឺថាការជម្លៀសគឺមួយសប្តាហ៍ក្រោយខ្មែរក្រហមកាន់កាប់ -- ឈ្មោះលើទ័ព លន់ នល់។ ហើយពេលដែលជម្លៀស គឺខ្ញុំឃើញផ្ទាល់ គឺទាហានគេកំហែងយើងគ្រប់តាមគ្រប់វិធីគ្រប់បែបយ៉ាងដើម្បីឲ្យយើងចេញពីផ្ទះ។ កាំភ្លើងបាញ់ផង ស្រែកផង ឧគ្ឃោសនសព្ទផង។ បាទ ឃើញផ្ទាល់ភ្នែកបាទ។

[១៣:៤៨:៤៤]

**ស៖** ខ្ញុំទុកចំណុចនេះមួយឡែកសិន ហើយខ្ញុំសួរលោកសិនថា ពីមុន -- ខាងដើមនោះ គឺថា លោក និយាយថាម្តាយរបស់លោករួមជាមួយនឹងប្រជាជនដទៃទៀត បានលើកឡើងថា "លោកគួរតែមានការភ័យខ្លាចកងកម្លាំងខ្មែរក្រហម"។ តើលោកអាចជម្រាបបន្តិចបានដែរឬទេ? តើមានហេតុផលអ្វីដែលម្តាយរបស់លោក និងប្រជាជនដទៃទៀតនោះ បានលើកឡើងថាមានការភ័យខ្លាចការមកដល់របស់ខ្មែរក្រហមនោះ?

**ឆ៖** ពីព្រោះថា នៅពេលនោះកងទ័ព លន់ នល់ បានទទួលបរាជ័យជាបន្តបន្ទាប់ ហើយប្រជារាស្ត្រមួយចំនួនគេទៅៗប៉ៃលិន ដើម្បីឆ្លងទៅថៃ មួយក្រុមទៀតគេទៅប៉ោយប៉ែត ដើម្បីឆ្លងទៅថៃដែរ។ ហើយគេបបួលខ្ញុំទៀត ប៉ុន្តែខ្ញុំមិនទៅ ដោយខ្ញុំយល់ថា ខ្ញុំអាចនៅបម្រើប្រទេសជាតិជាមួយអ្នកដែលជឿនលឿន ដែលស្អាតស្អំ ដែលខ្ញុំយល់ថាគេជាមនុស្សល្អ។

**ស៖** សូមអរគុណ។ នៅពេលនេះ យើងត្រឡប់ទៅនិយាយអំពីហេតុការណ៍នៅថ្ងៃទី២៥ ខែមេសា វិញម្តង។ ក្នុងពេលដែលទាហានខ្មែរក្រហមបានដើរនៅគ្រប់កន្លែងនៃទីក្រុង ហើយបានបង្ខំឲ្យប្រជាជនចាកចេញពីផ្ទះនោះ តើគេមានឲ្យហេតុផលទេ គេមានប្រាប់ហេតុផលទេ ហេតុអ្វីបានជាប្រជាជនត្រូវចាកចេញពីផ្ទះ ចាកចេញពីក្រុង?

**ឆ៖** ហេតុផលនេះគឺថាបានឮពីរបីថ្ងៃមុន គឺថាគេថាប្រជារាស្ត្រនឹងត្រូវជម្លៀស ដើម្បីឲ្យទៅបង្កបង្កើនផលនៅជនបទ។

[១៣:៥១:១០]

**ស៖** នៅថ្ងៃនោះ គឺខែមេសា ឆ្នាំ១៩៧៥ តើអាហារ ស្បៀងអាហារនោះមានខ្វះខាតទេនៅក្នុង

ក្រុងបាត់ដំបង ឬក៏ គឺគេជម្លៀសប្រជាជនដោយសារខ្វះស្បៀង ខ្វះអាហារអី តើមានការខ្វះខាតស្បៀងអាហារដែរឬទេនៅទីនោះ?

**ឆ៖** ស្បៀងគេ គឺថាម្នាក់ៗយកស្បៀងទៅជាមួយ មានអង្ករ មានស្ករ មានប្រហុក មានត្រីទៅជាមួយ មិនខ្វះទេ។ ពីព្រោះមិនមែនខ្មែរក្រហមចូលភ្លាម ដេញភ្លាម គេទុកមួយសប្តាហ៍បានយើងចេញ។

**ស៖** សូមអរគុណ។ សំណួររបស់ខ្ញុំ ប្រហែលជាខ្ញុំសួរមិនច្បាស់។ នៅក្នុងខែមេសា តាមការចាំរបស់លោកអំពីស្ថានភាពមុនពេលជម្លៀសនោះ តើមុនពេលជម្លៀសនោះ មានការខ្វះខាតអាហារ ឬគ្រោះទុរ្ភិក្សនៅខេត្តបាត់ដំបងដែរឬទេ?

**ឆ៖** ខ្ញុំអត់ជួបប្រទះនូវការខ្វះខាតម្ហូបអាហារទេ ខ្ញុំមិនបានឃើញទេៗ។

**ស៖** នៅពេលដែលគេជម្លៀសខេត្តបាត់ដំបង តើមានអ្វីកើតឡើងដែរចំពោះមន្ទីរពេទ្យខេត្តបាត់ដំបង រួមទាំងទីរួមខេត្តបាត់ដំបងដែរនោះ?

**ឆ៖** នៅពេលដែលគេជម្លៀសប្រជារាស្ត្រចេញពីបាត់ដំបង គឺអ្នកជំងឺចេញពីមន្ទីរពេទ្យទាំងអស់។ មន្ទីរពេទ្យទៅជាទទេ ហើយក្រុងក៏ជាក្រុងខ្មោច។

[១៣:៥៣:៣៨]

**ស៖** តាមការសង្កេតរបស់លោក តើមានករណីលើកលែង មានការលើកលែងដែរឬទេ ឧទាហរណ៍ថា ចំពោះមនុស្សចាស់ ឬក៏អ្នកជំងឺនោះមានការលើកលែងដែរឬទេ? ហើយមានការលើកលែងឲ្យនៅក្នុងទីក្រុងដើម្បីទទួលការព្យាបាលដែរឬទេ?

**ឆ៖** អត់មានទេ ពីព្រោះថាមន្ទីរ -- បុគ្គលិកពេទ្យក៏ចេញដែរ។ ដល់អ៊ីចឹងទេ អ្នកជំងឺគ្មានប្រយោជន៍អ្វីនឹងនៅមន្ទីរពេទ្យ។

**ស៖** យើងចូលត្រឡប់ និយាយអំពីបញ្ហាហេតុផលៗ ដែលគេប្រាប់អំពីការជម្លៀសវិញម្តង។ លោកបានប្រាប់ខ្ញុំថា លោកបានឮហេតុផលនេះ គេប្រាប់ហេតុផលនេះពីរបីថ្ងៃមុនថ្ងៃជម្លៀស ដែលគេប្រាប់ថាឲ្យជម្លៀសប្រជាជនទៅតាមស្រែធ្វើការបង្កបង្កើនផល។ តើទាហានដែលបង្ខំឲ្យប្រជាជនចាកចេញពីផ្ទះនោះ តើគេមានប្រាប់ហេតុផលដល់យើងទេ ហេតុអ្វីបានពួកគេបង្ខំឲ្យយើងចាកចេញពីផ្ទះ?

**ឆ៖** គេបាន ឮតៗគ្នាមុនជម្លៀស គេថាយើងត្រូវ -- អ្នកក្រុងត្រូវតែចេញទៅនៅទៅស្រែដើម្បីរួមចំណែកបង្កបង្កើនផល។

[១៣:៥៦:០០]

**ស៖** ដូច្នេះតាមខ្ញុំយល់មិនខុសនោះគឺថា ទាហានខ្មែរក្រហមដែលមកជម្លៀសនេះ គឺគេមិនប្រាប់ហេតុផលទេនៅថ្ងៃជម្លៀសនោះ តើអ៊ីចឹងដែរឬទេ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

សាក្សីឆ្លើយ សូមឆ្លើយ! មិញឆ្លើយ ប៉ុន្តែអត់បើកក្បាលមីក្រូទេ បានន័យថាក្បាលមីក្រូហ្វូនមិនទាន់ប្រតិបត្តិការ។

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** នៅពេលដែលជម្លៀសនោះ គេមិនមាននិយាយអ្វីទេ។ យើងមិនឮសួរអ្វីទេ ក្រៅពីសំឡេងកាំភ្លើង សំឡេងគំរាមកំហែងប៉ុណ្ណឹង។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** តើលោកនៅចាំទេថា តើចំនួនប្រជាជននៅក្នុងក្រុងបាត់ដំបងហ្នឹង មានចំនួនប៉ុន្មានដែរនៅក្នុងខែមេសា ឆ្នាំ១៩៧៥? បានន័យថាមានចំនួនប៉ុន្មានដែរ ចំនួនប្រជាជនហ្នឹង នៅក្នុងខេត្តបាត់ដំបងរស់នៅ?

[១៣:៥៧:២១]

**ឆ៖** ខ្ញុំនិយាយដោយត្រង់ចុះ ខ្ញុំមិនដឹងចំនួនប៉ុន្មានទេពេលនោះបាទ។

**ស៖** សូមអរគុណ។ នៅពេលនេះ យើងចូលនិយាយអំពីការផ្លាស់ទីលំនៅរបស់លោកវិញម្តងដែលលោកត្រូវបានគេជម្លៀសទៅដំរីស្លាប់នៅក្នុងសៀវភៅរបស់លោក ជាពិសេសលោកបានរៀបរាប់នៅក្នុងជំពូកទី៣ នៃសៀវភៅរបស់លោក។ ជាដំបូងខ្ញុំសូមអនុញ្ញាតសួរលោកអំពី អាជ្ញាធរ -- រចនាសម្ព័ន្ធ អាជ្ញាធរដែលលោកបានរៀបរាប់ត្រង់ទំព័រ ERN លេខ 00678774 និងអង់គ្លេស 00369693។ នៅត្រង់ចំណុចនុ៎ង គឺលោកបានរៀបរាប់ថា លោករស់នៅក្នុងភូមិដំរីស្លាប់ ឃុំព្រៃកនរិទ្ធ ឬស្រុក៤៣ ភូមិភាគពាយ័ព្យ។ តើលោកអាចរៀបរាប់ជូនអង្គសវនាការដែរឬទេ? តើលោកសង្កេតឃើញថារចនាសម្ព័ន្ធគ្រប់គ្រងនៅក្នុងភូមិរបស់លោកនោះ គឺថាមានការរៀបចំរចនាសម្ព័ន្ធរដ្ឋបាលយ៉ាងម៉េចដែរនៅក្នុងនុ៎ង នៅទីនោះ?

[១៣:៥៨:១២]

**ធ៖** នៅ -- ខ្ញុំបានសរសេរនៅក្នុងសៀវភៅហើយ គឺថារចនាសម្ព័ន្ធខ្មែរក្រហមនោះ គឺមានភូមិ គេមានប្រធានមួយ អនុប្រធានពីរ មានឃុំ ប៉ុន្តែគ្រាន់ថាគ្មានជាការិយាល័យអីទេ គេយកផ្ទះប្រជារាស្ត្រនេះធ្វើជាកន្លែងនៅផង ជាស្នាក់ការភូមិផង ស្នាក់ការឃុំផង។ ហើយបើស្រុកវិញគឺនៅឆ្ងាយពីហ្នឹង ខ្ញុំមិនដែលបានឃើញ ប៉ុន្តែនៅឆ្ងាយពីហ្នឹង បាទ ស្រុក។ ហើយបន្ទាប់ពីស្រុកមក គ្មានខេត្តទេ។ បន្ទាប់ពីស្រុកមក គឺតំបន់តែម្តង។ តំបន់រួចបានភូមិភាគ។ ដូច្នេះរចនាសម្ព័ន្ធខ្មែរក្រហមបាត់ពាក្យខេត្តមួយ ហើយស្រុកទៀត ដាក់លេខស្រុក ស្រុកលេខ ដូចស្រុកខ្ញុំបាទនៅអ៊ីចឹង ស្រុកៗ កាលណោះគេហៅថាស្រុកដូនទាវ ឬស្រុក៤៣ ហើយភូមិភាគៗ ភូមិភាគពាយ័ព្យ។

**ស៖** នៅពេលនេះយើងផ្តោតទៅលើរចនាសម្ព័ន្ធរដ្ឋបាលសិន។ នៅក្នុងសៀវភៅរបស់លោក ត្រង់ទំព័រដដែល ដែលខ្ញុំបានលើកឡើងអម្បាញ់មិញនេះ គឺគេបង្កើតក្រុមអ្នកឃាម ហៅថាឈ្លប ឬក៏គិញ។ តើលោកអាចបញ្ជាក់ប្រាប់បន្តិចបានដែរឬទេ ថាតើកងឈ្លប ឬក៏ក្រុមហ្នឹង តើមានតួនាទីអ្វីដែរ?

[១៤:០១:១៤]

**ធ៖** នេះគឺប្រធានភូមិក៏មានឈ្លប ប្រធានឃុំក៏មានឈ្លប ហើយឈ្លបហ្នឹងគឺគេជ្រើសរើសក្នុងចំណោមកូនប្រជាជនក្រីក្រ តែមានចិត្តសាហាវមោះមុត។ គឺថាប្រើឲ្យសម្លាប់ សម្លាប់ អត់រួញរាទេ បាទ អាហ្នឹងឈ្លប។ ហើយមានឈ្លបបង្កប់មួយទៀតៗ គឺច្រើនជ្រើសរើសក្មេងៗ ក្មេងៗនៅជំទង់ដែលពេលយប់វាអាចមកលូនក្រោមគ្រែយើង លួចស្តាប់យើងនិយាយ រួចទៅរាយការណ៍ទៅថ្នាក់លើ។

**ស៖** នៅត្រង់ទំព័រដដែលនេះ លោកបានរៀបរាប់អំពីគណៈកម្មការភូមិ ហើយលោកបានផ្តល់នូវឈ្មោះមនុស្សខ្លះដែលស្ថិតនៅក្នុងគណៈកម្មការ និងគណៈកម្មការឃុំនោះ។ លោកនិយាយថា "ប្រធានភូមិនីមួយៗ --" ខ្ញុំសូមតាំងសំណួរឡើងវិញ "គណៈកម្មការភូមិនីមួយៗមានប្រធានម្នាក់ជា -- មានប្រធានម្នាក់ដែលជាខ្មែរក្រហម និងអនុប្រធានភូមិពីរនាក់ជាអ្នកភូមិ ដែលហៅថាប្រជាជនចាស់ ឬអ្នកមូលដ្ឋាន"។ ថាតើខ្ញុំសង្ខេបឃ្លាប្រយោគរបស់លោកឡើងវិញនេះត្រឹមត្រូវដូច្នេះមែនទេ?

**ធ៖** បាទ អ៊ីចឹងមែនហើយបាទ។

[១៤:០៣:១៧]

**ស៖** ចំណុចនេះវានាំឲ្យខ្ញុំឈានចូលទៅដល់កន្លែងដែលលោកពិភាក្សាត្រង់ផ្នែកមួយ ដែលនិយាយអំពីការចាត់ចំណាត់ថ្នាក់ប្រជាជនជាថ្មី ដែលលោកបានជួបប្រទះនោះ។ លោកនិយាយថាការ

បែងចែកប្រជាជនទៅជាអ្នក ១៧មេសា ឬក៏ប្រជាជនចាស់ ឬហៅថាអ្នកមូលដ្ឋាននោះ ប្រសិនណាជាលោកបានដឹង តើគេមានគោលបំណងអ្វីបានជាបែងចែកប្រជាជនទៅជាប្រភេទបែបនេះ?

**ឆ៖** តាមការយល់ឃើញរបស់ខ្ញុំផ្ទាល់ ការបែងចែកនេះគឺជាការរើសអើងរបស់ពួកខ្មែរក្រហមមិនមែនរបស់ប្រជាជនខ្មែរទេ។ គឺសូម្បីតែនៅក្នុងភូមិបែងចែកជាប្រជាជនក្រ ប្រជាជនក្រមែនទែន ក្រមែនទែន ប្រជាជនធូរធារ ប្រជាជនក្រ ប្រជាជនក្រខ្លាំង។ ហើយប្រជាជនថ្មីវិញ អាហ្នឹងគេបែងចែកជាប្រជាជនថ្មី ប៉ុន្តែនៅមានការបែងចែកមួយទៀត គឺពួកខ្មែរក្រហមមិនចូលចិត្តទេ អ្នកដែលស្បែក ៗ ជ្រះស្រឡះ ហៅស្បែក១ដែលមិនដែលត្រូវថ្ងៃនោះបាទ។ ស្អប់ណាស់ចំពោះខ្មែរក្រហមបាទ។

**ស៖** លោកវេជ្ជបណ្ឌិត ឈុនលី ខ្ញុំសូមសួរបញ្ជាក់បន្តិចអំពីច្បាប់ ឬក៏ហៅថាគោលនយោបាយថ្មីដែលលោកបានកត់ត្រាក្នុងកូនសៀវភៅរបស់លោកនោះ។ មុននឹងខ្ញុំសួរទៅលោក គឺថាយើងខ្ញុំនឹងមិននិយាយអំពីជីវភាពប្រជាជននៅក្នុងសហករណ៍ទេ យើងនិយាយអំពីរចនាសម្ព័ន្ធអំណាច ហើយនិងការជម្លៀសដោយប្រជាជនដោយបង្ខំ។ ខ្ញុំនឹងមិនសួរអំពីជីវិតរស់នៅក្នុងសហករណ៍ទូលំទូលាយទេ តែសួរតែពីរបីសំណួរទេ ពាក់ព័ន្ធនឹងគោលនយោបាយថ្មី១ដែលលោកបានរៀបរាប់នៅក្នុងសៀវភៅរបស់លោក។ ហើយបើលោកអាចពន្យល់បន្ថែមបន្តិចបានទេ នេះត្រង់នៅទំព័រគឺ ERN ជាភាសាខ្មែរ 00678777, ហើយ ERN ជាភាសាអង់គ្លេស 00369695។ ចំណុចនេះលោកសរសេរវែងបន្តិច ប៉ុន្តែខ្ញុំនឹងលើកយកចំណុចដែលខ្ញុំចង់ពិភាក្សាជាមួយលោកនោះ គឺថា "ប្រជាជនត្រូវតែបង្ខំចិត្តស្លៀកពាក់ខោអាវចាស់ៗ ដើម្បីឲ្យមើលទៅឃើញគាត់ចាស់ ហើយស្បែកជើងប៊ូ ឬក៏ស្បែកជើងផ្ទាត់ហ្នឹងគឺថាត្រូវបោះចោល គេបោះស្បែកជើងឃ្លុប ស្បែកជើងសង្រែកចោល ហើយក្នុងនោះក៏លោកបានសរសេរថាគ្មានអ្នកណាម្នាក់ហ៊ានពាក់វ៉ែនតាដើម្បីកុំឲ្យគេស្គាល់ថា ជាបញ្ញវន្ត"។ តើអានេះអ្វីដែលលោកបានឃើញយ៉ាងដូច្នេះមែនទេ ហើយអ្វីដែលលោកបានសរសេរនៅក្នុងសៀវភៅរបស់លោកដូច្នេះមែនទេ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

[១៤:០៧:៤៦]

**ប្រធានអង្គជំនុំ៖**

ឈប់សិន!

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** បាទ នេះជាការពិត គឺថាអ្នកដែលគ្មានអស់ខោអាវចាស់ទៅ មានខោអាវថ្មីគេយកទៅ

ជ្រលក់ភក់ ជ្រលក់ភក់ៗហើយ លាងទឹកហើយហាលថ្ងៃដើម្បីឱ្យឃើញចាស់អ៊ីចឹងបាទ។ ហើយស្បែកជើង វែនតាអី គឺថាមិនត្រូវ មិនប៊ានពាក់ទេ ហើយសូម្បីតែស្រីៗក៏មិនប៊ានតែងខ្លួនអីឱ្យវាហ៊ឺហាដែរ បាទ។

**សួរដោយលោក អាប់ឌុលឡាក់ ថាវីក៖**

**ស៖** តើលោកយល់ហេតុផលទេ ដែលចំពោះគោលនយោបាយបែបហ្នឹង តើលោកយល់ហេតុផលគោលនយោបាយហ្នឹងទេ?

**ឆ៖** ខ្ញុំគ្រាន់តែយល់ថា ខ្មែរក្រហមធ្វើអ្វីគឺអវិជ្ជមានទាំងអស់។ ខ្ញុំយល់ដូច្នេះ គឺធ្វើអ្វីដើម្បីបំផ្លាញប្រទេសជាតិ ដើម្បីបំផ្លាញប្រជារាស្ត្រ។ ផ្អែកពីការសង្កេត និងការស្មានរបស់ខ្ញុំ។

[១៤:០៩:៣៤]

**ស៖** ហេតុអ្វីបានជាប្រជាជនលាក់របៀបនេះ ដូចជាមិនប៊ានពាក់វែនតាដើម្បីកុំឱ្យគេដឹងថាជាបញ្ញវន្ត? ខ្ញុំអាចសួរឡើងវិញ ហេតុអ្វីបានជាប្រជាជនលាក់អំពីប្រវត្តិរបស់ខ្លួន ដែលជាបញ្ញវន្តនោះ កុំឱ្យគេដឹងថាជាបញ្ញវន្តយ៉ាងដូច្នេះ? តាមការកត់សម្គាល់របស់លោក លោកយល់ថាម៉េច?

**ឆ៖** ពួកខ្មែរក្រហមមិនចូលចិត្តទេអ្នកដែលៗមានតម្រិះវេជ្ជា ទី១។ អ្នកដែលមានតម្រិះវេជ្ជាខ្ពង់ខ្ពស់ ហើយកាលពាក់វ៉ែនតានេះ ច្រើនតែជាបញ្ញវន្ត ហើយពួកនេះមិនចូលចិត្តបញ្ញវន្តទេ បាទ។ គេហៅថា ដោយៗគេហៅពួកបញ្ញវន្ត ដោយពាក្យៗ ចំអក គេថា ពួកបញ្ញាសុញ។ គេមិនហៅថា "បញ្ញវន្ត" ទេ គេហៅថា "ពួកបញ្ញាសុញ" បាទ គឺអ៊ីចឹង។ ហើយការពាក់វ៉ែនតា គឺគ្មានអ្នកណាប៊ានពាក់ទេ ខ្ញុំក៏ត្រូវបោះបង់វ៉ែនតាដែរ បាទ។

[១៤:១១:០៨]

**ស៖** បាទ ខ្ញុំសួរមួយសំណួរពីរសំណួរទៀត ទៅលើគោលនយោបាយថ្មីហ្នឹង ដែលលោកបានកត់សម្គាល់នោះ។ នៅត្រង់ ERN ជាភាសាខ្មែរ 00678779, ERN អង់គ្លេស 00369696។ លោកបានរៀបរាប់អំពីការប្រមូលប្រវត្តិរូប ដែលលោកថា ៣ថ្ងៃក្រោយពីការតាំងទីលំនៅ ប្រជាជនព្យាយាមប្រមូលប្រវត្តិរូបពីប្រជាជន ដែលរស់នៅតាមក្រុមហ្នឹង ហៅថា ប្រវត្តិរូបរួម។ គេកត់ត្រាឈ្មោះ ភេទ និងមុខរបរ របស់បុគ្គលម្នាក់ៗ។ គេប្រាប់ប្រជាជនថា "ត្រូវតែប្រាប់ឱ្យត្រង់ជាមួយអង្គការ គឺកុំកុហកអង្គការ គឺប្រាប់អង្គការតែអ្វីដែលពិត"។ ដូច្នេះ តាមការកត់សម្គាល់របស់លោក តើលោកយល់ពីគោលបំណង នៃការប្រមូលប្រវត្តិរូបនេះទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញមេធាវីអន្តរជាតិមេធាវីការពារក្តីលោក នួន ជា!

**លោក ហ្សាស្តើ ប៉ោ៖**

ខ្ញុំមានភាពស្ទាក់ស្ទើរមិនប៉ានជំទាស់តាំងពីដើម ប៉ុន្តែសំណួរសួរទាំងអម្បាលម៉ាននេះ គឺសួរឲ្យសាក្សីស្មានៗ ឬក៏ថាបកស្រាយនូវស្ថានភាពណាមួយនោះ ដែលថាសាក្សីមិនមានការដឹងដោយផ្ទាល់ ឬក៏មានបទពិសោធន៍ដោយផ្ទាល់នោះទេ។ ហើយសហព្រះរាជអាជ្ញាសួរ និយាយអំពីការបែងចែកប្រជាជនថ្មី ប្រជាជនមូលដ្ឋាន ឲ្យសាក្សីស្មានថា ហេតុអ្វីបានជាគេលាក់មិនប៉ានពាក់វ៉ែនតា យ៉ាងដូច្នេះ? សំណួរនេះ គឺថាមានគួរឲ្យចាប់អារម្មណ៍មែន ប៉ុន្តែគួរតែសួរថា តើគាត់បានដឹង ឬក៏មានបទពិសោធន៍ ហើយៗក៏ត្រូវតែសួរថា តើគោលនយោបាយហ្នឹង គឺថាវាមិនត្រឹមត្រូវដោយរបៀបម៉េច? សួរថាតើ -- គួរសួរអ៊ីចេះ ថាតើបទពិសោធន៍របស់គាត់ គាត់ដឹងយ៉ាងម៉េចដែរ ចំពោះគោលនយោបាយហ្នឹង? ដោយមិនត្រូវសួរសំណួរណា ដែលឲ្យសាក្សីឆ្លើយដោយស្មាននោះទេ។ សូមអរគុណ។

[១៤:១៣:៥៣]

**ប្រធានអង្គជំនុំ៖**

សូមអរគុណ។ សូមអញ្ជើញលោកមេធាវី អាង ឧត្តម!

**លោក អាង ឧត្តម៖**

ដើម្បីគាំទ្រទៅលើសំណើ របស់លោកមេធាវីការពារក្តីលោក នួន ជា។ ខ្ញុំសូមរំឭកថា នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១២ ហ្នឹង អង្គជំនុំជម្រះសាលាដំបូងបានចេញ *រួចហើយ* បានចេញបញ្ញត្តិមួយថា "មានអ្នកតែអ្នកឯកទេស អ្នកជំនាញទេ ដែលអាចស្មានបាន។ ចំណែកឯសាក្សី មិនអាចឆ្លើយដោយស្មាននោះទេ"។ នេះតាមការកត់សម្គាល់របស់ខ្ញុំ។ សូមអរគុណ។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតប។ ទី១ ខ្ញុំមិនបានសួរឲ្យសាក្សីឆ្លើយដោយស្មាននោះទេ។ ខ្ញុំសួរលោកវេជ្ជបណ្ឌិតឲ្យគាត់រៀបរាប់អំពីព្រឹត្តិការណ៍ដែលគាត់បានឃើញ។ វាមិនមែនជាការត្រឹមត្រូវដែលសួរថា គាត់យល់ថាម៉េចទេ? ខ្ញុំប្រយ័ត្នណាស់ មិនប៉ានសួរសំណួរបែបនេះទេ។ ខ្ញុំមិនឲ្យគាត់ឆ្លើយដោយរបៀបជាអ្នកជំនាញនោះទេ ទៅលើគោលនយោបាយដ៏ទូលំទូលាយនេះទេ។ ខ្ញុំសួរគាត់អំពីព្រឹត្តិការណ៍ ដែលគាត់បានឃើញ ហើយថាគាត់យល់យ៉ាងម៉េច ចំពោះព្រឹត្តិការណ៍ដែលគាត់បាន

យើញនោះ។ បាទ ការបែងចែករវាងមនុស្ស ហើយនិងមនុស្សយន្តនោះគឺថា មនុស្សត្រូវតែមានការកត់សម្គាល់ និងស្វែងយល់អ្វីដែលមនុស្សបានឃើញ។ សហមេធាវីការពារក្តីគឺថា គាត់ចង់ឲ្យខ្ញុំតាំងសំណួរទៅសួរដូចជា *រ៉ូបូត*គឺថា សួរមនុស្សយន្តទៅវិញនោះ ដែលអ្វីដែលគាត់បានឃើញដោយផ្ទាល់ភ្នែកតែម្តង ដែលថាចង់សំដៅថា មនុស្សគឺថាមិនអាចមានការកត់សម្គាល់បាន។ ដូច្នេះគឺ មិនត្រូវទេ។ ដូច្នេះខ្ញុំសូមអញ្ជើញឲ្យអង្គជំនុំជម្រះមេត្តាច្រានចោល នូវការជំទាស់នេះ។ ខ្ញុំសួរគាត់នេះ សំអាងទៅលើមូលដ្ឋាន នៃបទពិសោធន៍របស់គាត់។ សូមអរគុណ។

[១៤:១៦:០៩]

**លោក អាង ឧត្តមៈ**

ដើម្បីបន្ថែមនៅចំណុចនេះ--

**ប្រធានអង្គជំនុំៈ**

យើងអត់មានឆ្លើយតបលើសេចក្តីឆ្លើយតបចុងក្រោយ របស់ភាគីម្ខាងទៀតទេ លោកមេធាវី។ យើងបានកំណត់នូវវិធាន នៃការជំទាស់តវ៉ានេះយ៉ាងជាក់ច្បាស់ណាស់។ យើងមិនអនុញ្ញាតឲ្យលោកធ្វើដូច្នេះទេ នៅក្នុងការជំទាស់តវ៉ានោះ។

[១៤:១៦:៥១]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:១៧:១២]

**ប្រធានអង្គជំនុំៈ**

បាទ អង្គជំនុំជម្រះសម្រេចថា សេចក្តីជំទាស់របស់មេធាវីការពារក្តី លើការតាំងសំណួររបស់តំណាងសហព្រះរាជអាជ្ញាចំពោះសាក្សីរូបនេះ នៅសំណួរចុងក្រោយនេះគឺ សេចក្តីជំទាស់ហ្នឹង មិនត្រឹមត្រូវទេ សេចក្តីជំទាស់មិនមានប្រសិទ្ធភាព។

ការសួរនេះ គឺជាបទពិសោធន៍របស់បុគ្គល ដែលអង្គជំនុំជម្រះបានអនុញ្ញាត នៅក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន គឺទាំងបទពិសោធន៍របស់ខ្លួនបានជួបប្រទះ ឬក៏ធ្វើការកត់សម្គាល់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យពាក់ព័ន្ធទៅនឹងសំណួរ ដែលសួរផង។ ហើយសូមបញ្ជាក់ថា ប្រហែលជាលោកមេធាវី អាង ឧត្តម គាត់មានការភ័ន្តច្រឡំថា មានតែអ្នកជំនាញទេ ដែលអាចឆ្លើយស្មានៗបាន។ ទាំងអ្នកជំនាញក៏មិនអាចឆ្លើយស្មានដែរ មិនមានអ្នកឆ្លើយណាមួយ អាចឆ្លើយស្មានៗនៅចំពោះមុខអង្គជំនុំ

ជម្រះបានទេ។ មួយឆ្លើយតាមជំនាញដែលខ្លួនមានចំណេះដឹងជ្រៅជ្រះលើវិស័យណាមួយ ដែលអង្គជំនុំជម្រះចាត់តាំងគាត់ក្នុងនាមអ្នកជំនាញ ឲ្យជួយវាយតម្លៃ ជួយធ្វើសេចក្ដីសន្និដ្ឋានចំពោះអង្គជំនុំជម្រះ។ មួយទៀតគឺ សាក្សី។ អ៊ីចឹង គឺបញ្ជាក់ច្បាស់ក្រែងលោអាចមានការភ័ន្តច្រឡំ។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម។ ខ្ញុំសូមតាំងសំណួរខ្ញុំឡើងវិញ។

[១៤:១៨:៥៧]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** ទាក់ទងទៅនឹងការស្រង់ប្រវត្តិរូបនេះ តើលោកបានប្រគល់ប្រវត្តិរូបលោកទៅឲ្យអ្នកណា?

**លោក ហ៊ិន ឈុនលី៖**

**ឆ៖** បាទ ខ្ញុំនឹងឆ្លើយជូន ហើយការឆ្លើយរបស់ខ្ញុំគឺ ពុំមែនទៅលើការប៉ាន់ស្មាន ស្រមើស្រមៃទេ ជាការពិត ព្រោះខ្ញុំរស់នៅក្នុងរបបខ្មែរក្រហមជិត៤ឆ្នាំ។ ការស្រង់ប្រវត្តិរូបនេះ គឺខ្មែរក្រហមបានចាត់តាំងប្រធានក្រុមនីមួយៗ ប្រធានក្រុមគេមកស្រង់ប្រវត្តិរូប អ្នកនៅតាមភូមិ គឺថា ឈ្មោះ អាយុ មុខរបរ...។ល។ បាទ ប៉ុន្តែចំពោះខ្ញុំ ខ្ញុំមិនដាក់ថាខ្ញុំធ្លាប់ធ្វើពេទ្យទាហានទេ ខ្ញុំថាខ្ញុំធ្លាប់ធ្វើពេទ្យនៅមន្ទីរពេទ្យខេត្តបាត់ដំបង ពីព្រោះខ្ញុំអ្នកបាត់ដំបងស្គាល់ខ្ញុំជាគ្រូពេទ្យស៊ីវិលជាងគ្រូពេទ្យទាហាន ពីព្រោះខ្ញុំធ្វើការពេទ្យស៊ីវិលយូរហើយ -- យូរ ក្រោយមកបានខ្ញុំត្រូវកែនចូលធ្វើពេទ្យទាហានបាទ។

**ស៖** តើលោកដឹងទេថា ខ្មែរក្រហមគេធ្វើយ៉ាងម៉េចដែរជាមួយប្រវត្តិរូបដែលខ្មែរក្រហមបានស្រង់ទៅហ្នឹង?

**ឆ៖** ខ្ញុំមិនៗដឹងថាគេយកទៅធ្វើ -- មិនដឹងថាប្រវត្តិរូបហ្នឹងទៅដល់ណា ហើយគេវិភាគយ៉ាងណាៗ ខ្ញុំមិនដឹងទេបាទ។

**ស៖** បើសិនណាជាខ្ញុំអាចតាំងសំណួរឡើងវិញ សុំតាំងឡើងវិញ។ តើលោកបានប្រគល់ប្រវត្តិរូបរបស់លោកទៅឲ្យអ្នកណា?

**ឆ៖** ឲ្យទៅប្រធានក្រុមដែលមកស្រង់ប្រវត្តិរូបមកឲ្យយើងធ្វើ ធ្វើរួចយើងប្រគល់ឲ្យគេ។

**ស៖** សូមអរគុណ។ ឥឡូវខ្ញុំសូមចូលទៅអង្គប្រជុំមួយដែលលោកប្រជុំនៅក្នុងខែឧសភា ឆ្នាំ៧៥ នៅត្រង់ -- ប្រហែលជាខ្ញុំអាចអានមិនត្រូវដូចជាឈ្មោះវត្តតាំងងារ ឬក្ដាំងងារនេះគឺថានៅក្នុងសៀវភៅរបស់លោក។

**អ្នកបកប្រែ៖**

បាទ លោកប្រធានសូមអធ្យាស្រ័យ តាម ERN អម្បាញ់មិញអត់ទាន់លោកប្រធាន។ សូមឲ្យលោកសហព្រះរាជអាជ្ញាថាម្តងទៀត។

**ប្រធានអង្គជំនុំ៖**

តំណាងសហព្រះរាជអាជ្ញាអានលេខ ERN អម្បាញ់មិញសាជាថ្មីម្តងទៀត ហើយឲ្យយឺតពីព្រោះអ្នកបកប្រែបកមិនទាន់ទេ។

[១៤:២២:៤២]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** ERN ជាភាសាខ្មែរ 00678778 ដល់ 9, អង់គ្លេស 00369696។ នៅត្រង់ផ្នែកនេះលោកវេជ្ជបណ្ឌិត ឈុនលី លោកបាននិយាយអំពីអង្គប្រជុំនៅដើមខែឧសភា ៧៥ ដែលៗមេដឹកនាំខ្មែរក្រហមឈ្មោះ ប៉ែន និងឈ្មោះ ស៊ូ នេះគឺថាបានធ្វើសេចក្តីថ្លែងសុន្ទរកថាយ៉ាងយូរ។ គឺ ខែក ប៉ែន ហៅ ស៊ូ នេះគឺបានធ្វើសុន្ទរកថាយ៉ាងយូរ។ លោកបាននិយាយអំពីសេចក្តីថ្លែងការណ៍របស់គាត់ទាក់ទងទៅនឹងកងទ័ពប្រជាជនបដិវត្តន៍។ ឥឡូវនេះលោកថា "ជាលើកទី១ នៅក្នុងប្រវត្តិសាស្ត្រកម្ពុជាយើងគឺអង្គការកងទ័ពបដិវត្តន៍កម្ពុជាកើតចេញអំពីប្រជាកសិករក្រីក្រ វណ្ណៈប្រជាកសិករក្រីក្រ ហើយបានរំដោះប្រជាជនកម្ពុជាចេញអំពីខ្ញុំកញ្ជះចក្រពត្តិអាមេរិក"។ ហើយខាងក្រោមមកទៀតលោកបានសរសេរថា "ទាក់ទងទៅនឹងផែនការរបស់អង្គការដូចខាងក្រោម៖ ផែនការនេះតម្រូវឲ្យយើងទាំងអស់គ្នាលះបង់តាំងពី -- គឺធ្វើម៉េចឲ្យយើងទៅជាកសិករ គឺថាបូជាអាយុជីវិត ក៏ដូចជាទ្រព្យសម្បត្តិឯកជន កម្មសិទ្ធិសតិអារម្មណ៍ទាំងអស់"។ តើលោកអាចជម្រាបអង្គជំនុំជម្រះបានទេយោងតាមបទពិសោធន៍របស់លោកថាតើសេចក្តីថ្លែងការណ៍ ឬក៏ការណែនាំជាចុងក្រោយនេះគឺបានអនុវត្តដែរទេដែលនិយាយថា គឺត្រូវលះបង់កម្មសិទ្ធិសម្ភារៈផ្ទាល់ខ្លួន និងកម្មសិទ្ធិសតិអារម្មណ៍ផងនោះ តើការណែនាំបែបនេះបានអនុវត្តទេ?

[១៤:២៥:១៦]

**ឆ៖** នៅអង្គប្រជុំនៅវត្តក្លាំងងារនោះ មិត្តស៊ូ បាននិយាយថា "អង្គការមានផែនការធ្វើឲ្យប្រទេសកម្ពុជាទាំងមូលទៅជា ដូចក្រឡាៗចត្រង្គអីចឹង។ គេថាផ្ទៃដី១០០ម៉ែត្រៗអីចឹងបាទ។ មើលពី

លើទៅឃើញជាផ្ទៃដី១០០ម៉ែត្រៗស្មើគ្នាបាទ ទី១។ ទី២ គឺថា ឲ្យប្រជារាស្ត្រលះបង់ទាំងកម្មិសិទ្ធិឯកជន និងទាំងកម្មសិទ្ធិបញ្ញា អ៎! ទាំងកម្មសិទ្ធសតិអារម្មណ៍”។ ទី៣ មួយទៀតដែល មិត្តស៊្វ និយាយក្នុងនេះ គឺមិត្តស៊្វ និយាយថា “អង្គការមិនត្រូវការចំណាយពេលឥតប្រយោជន៍៧ឆ្នាំ ដើម្បីបណ្តុះបណ្តាលវេជ្ជបណ្ឌិតទេ។ អង្គការបណ្តុះបណ្តាលវេជ្ជបណ្ឌិតតែ១សប្តាហ៍ គឺគ្រប់គ្រាន់។ ហើយគ្រូពេទ្យទាំងនោះ នឹងមានមុខនៅគ្រប់ទីកន្លែងទៅមុខ ទីកន្លែងដែលប្រជារាស្ត្រធ្វើការ” បាទ។ នេះ៣ចំណុចសំខាន់ដែលមិត្តស៊្វ និយាយនៅក្នុងៗសុន្ទរកថា មិត្តស៊្វ នេះបាទ។

[១៤:២៦:៤៥]

ហើយចំពោះការអនុវត្តវិញ លោកជ្រាបស្រាប់ហើយថា កម្មសិទ្ធិសតិអារម្មណ៍ កម្មសិទ្ធិៗកម្មសិទ្ធិទ្រព្យសម្បត្តិ កម្មសិទ្ធិសតិអារម្មណ៍ ជាពិសេសកម្មសិទ្ធិសតិអារម្មណ៍ទោះបីគេនិយាយថា មិនឲ្យមានក៏មិនអាចបំបាត់បានដែរ។ ពីព្រោះជាតិយើង មនុស្សយើងជាមនុស្ស មិនមែនជាសត្វទេ។ ទី២ ផ្ទៃក្រឡាដីឲ្យបានស្មើគ្នាទូទាំងកម្ពុជា ១០០ម៉ែត្រការ៉េបួនជ្រុងនោះ ក៏ខ្ញុំឃើញថា នៅកន្លែងដែលខ្ញុំធ្វើការធ្វើបានតែកន្លែងមួយចំនួនទេ មិនបានៗទូទាំងស្រុកផងបាទ។ ទី៣ ចំពោះគ្រូពេទ្យវិញ អ្នកណាដែលបណ្តុះបណ្តាលគ្រូពេទ្យ ដុកទ័រ ៧ថ្ងៃ ហើយសម្លាប់ចោលគ្រូពេទ្យចាស់ទៅ វាមិនដែលមានបាទ។ នេះគឺចេញពីមិត្តស៊្វ គាត់និយាយតែម្តងថា “អង្គការមិនចំណាយពេលឥតប្រយោជន៍ ៧ឆ្នាំ ដើម្បីបណ្តុះបណ្តាលវេជ្ជបណ្ឌិតទេ”។ បាទ នេះគឺជា -- ខ្ញុំយល់ថា ជាៗគោលនយោបាយមួយដែលខ្មែរក្រហមប្រើប្រាស់ដើម្បីសម្លាប់ប្រជារាស្ត្រ។

[១៤:២៨:២៧]

**ប្រធានអង្គជំនុំៈ**

សូមអញ្ជើញ!

**លោក សុន អរុណៈ**

ខ្ញុំថា សាក្សីមិនគួរធ្វើសេចក្តីសន្និដ្ឋានទេពេលនេះ។

**ប្រធានអង្គជំនុំៈ**

អរគុណ។ អង្គជំនុំជម្រះសូមរំឭកលោក ហ៊ុន ឈុនលី ថាលោក សូមលោកឆ្លើយតបទៅនឹងកម្រិតសំណួរដែលសួរបានហើយ។ ជៀសវាងឆ្លើយហួសផុតពីសំណួរដែលសួរ ឬក៏ផ្តល់នូវ បញ្ចេញនូវមតិយោបល់អត្តនោម័តិផ្ទាល់ខ្លួនចំពោះនៅក្នុងកិច្ចដំណើរការសវនាការនេះ។ លោកស្តាប់សំណួរឲ្យបាន

ហើយយល់សំណួរ ឆ្លើយតបឲ្យសមល្មមនូវ -- ទៅនឹងភាពចាំបាច់នៃសំណួរដែលសួរបានហើយ។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោកវេជ្ជបណ្ឌិត ឈុនលី បាទ ខ្ញុំសូមឲ្យលោកឆ្លើយសង្ខេបបានហើយ ដោយសារតែយើងត្រូវការចង់បានព័ត៌មានពីលោកច្រើនណាស់។ ព្រឹត្តិការណ៍បន្ទាប់ដែលខ្ញុំចង់លើកយកមកសួរជាសង្ខេបទេ គឺការជម្លៀសលោកទៅមន្ទីរពេទ្យព្រែកហ្លួង ព្រឹត្តិការណ៍នេះកើតឡើងនៅក្នុងសៀវភៅរបស់លោកនៅក្នុងខែឧសភា ឆ្នាំ៧៥។ ខ្ញុំសូមសួរលោកខ្លីទេ។ ដំបូងគឺនៅ ERN ជាភាសាខ្មែរ 00678782, ERN 00369699 ជាភាសាអង់គ្លេស។ លោកបាននិយាយអំពីការលោកបានទទួលសំបុត្រមួយដែលមានឈ្មោះ មិត្តស៊ូ ហើយមានបោះត្រា ដែលជាលេខាតំបន់៣២។ លោកវេជ្ជបណ្ឌិត ឈុនលី តើវាត្រឹមត្រូវដែរទេ ដែលលោកបានទទួលលិខិតមួយពី មិត្តស៊ូ ឲ្យបញ្ជូនលោកទៅមន្ទីរពេទ្យព្រែកហ្លួង តើត្រឹមត្រូវទេ?

**ឆ៖** ខ្ញុំនៅធ្វើស្រែ ទៅភ្ជួរស្រែបាន១ខែ ក្រោយមកខ្ញុំបានទទួលសំបុត្រពី មិត្តស៊ូ ឲ្យខ្ញុំទៅធ្វើការនៅមន្ទីរពេទ្យព្រែកហ្លួង។ មន្ទីរនេះជា យកវិទ្យាល័យព្រែកហ្លួងធ្វើជាមន្ទីរពេទ្យ។

[១៤:៣១:២៩]

**ស៖** ខ្ញុំមិនចំណាយពេលច្រើនសួរអំពីបញ្ហាពេទ្យនោះទេ ក៏ប៉ុន្តែអ្វីដែលខ្ញុំសួរនោះ គឺចង់ដឹងអំពីរចនាសម្ព័ន្ធរដ្ឋបាលតែប៉ុណ្ណោះ។ ហើយគឺខ្ញុំនឹងសួរអំពីគោលនយោបាយដែលវាពាក់ព័ន្ធផងដែរ។ តើខ្ញុំអាចសុំសួរលោកដំបូងសិន តើនរណាគេជាអ្នកទទួលខុសត្រូវមន្ទីរពេទ្យព្រែកហ្លួងហ្នឹង?

**ឆ៖** នៅមន្ទីរពេទ្យព្រែកហ្លួង ប្រធានគឺជាស្រីម្នាក់ អាយុប្រហែល២៥ឆ្នាំ។ ខ្ញុំភ្លេចឈ្មោះទៅបាទ។

**ស៖** តើគាត់ជាគ្រូពេទ្យដែលទទួលបានការបណ្តុះបណ្តាលផងដែរឬទេ?

**ឆ៖** ខ្ញុំមិនស្គាល់ពីអតីតកាលរបស់គាត់ទេ។ អំពីការបណ្តុះបណ្តាលរបស់គាត់ក៏ខ្ញុំមិនដឹងដែរ។

**ស៖** សូមអរគុណ។ លោកបានសរសេរនៅក្នុងសៀវភៅរបស់លោកពាក់ព័ន្ធនឹងមន្ទីរពេទ្យនេះនៅក្នុងខែកក្កដា ឆ្នាំ១៩៧៥។ នៅក្នុងអំឡុងពេលនោះ យោងតាមសៀវភៅរបស់លោក លោកបានទៅមើលស្រុកមោងឫស្សីផងដែរ។ ខ្ញុំសូមសួរបញ្ជាក់បំភ្លឺលោកត្រង់មួយចំណុច។ លោកបានប្រាប់សហ

ព្រះរាជអាជ្ញាខាងដើមថា លោកនិយាយជាមួយនឹងបុរសមួយរូបជាអ្នកបើកឡាន។ ហើយបើកឡានដឹកទាហាន លន់ នល់ និងមន្ត្រីរដ្ឋការ លន់ នល់។ នៅក្នុងសៀវភៅរបស់លោក លោកនិយាយអំពីបុរសម្នាក់នុំង។ បុរសដែលលោកនិយាយនោះ គឺនៅត្រង់ទំព័រ 00678789, អង់គ្លេស គឺ00369705។ លោកបាននិយាយ អតីតគ្រូម្នាក់នៅសាលកវិទ្យាល័យវិចិត្រសិល្បៈ ហើយលោកបាននិយាយថា គឺគាត់បើកឡានដឹកទាហាន លន់ នល់ និងមន្ត្រីរដ្ឋការ លន់ នល់ យកទៅកន្លែងសម្លាប់ចោល។ តើកន្លែងនោះលោករៀបរាប់យ៉ាងម៉េចដែរ?

[១៤:៣៤:៤៧]

**ឆ៖** កាលណោះ ខ្ញុំធ្វើការនៅមន្ទីរព្រែកហ្លួង ហើយថ្ងៃមួយនោះគេឱ្យខ្ញុំ និងបុគ្គលិកពីរបីនាក់ទៀតទៅមោងឫស្សី ដើម្បីទៅតាមក្រុមសិល្បៈ ដែលប្រធានជាកូន មិត្តស៊ូ។ ក្រុមសិល្បៈសម្តែងនៅភូមិ -- នៅភូមិជ្រៃ ស្រុកមោងដែរបាទ។ ហើយឈ្មោះលោកគ្រូ ចាន់ -- ឈ្មោះគ្រូ ចាន់ នេះ គាត់ជាអតីតសាស្ត្រាចារ្យនៅមហាវិទ្យាល័យវិចិត្រសិល្បៈ គាត់ធ្លាប់នៅភ្នំពេញ -- គាត់ជាប់នៅ គាត់នៅបាត់ដំបងបាទ ធ្លាប់នៅបាត់ដំបង។ គាត់ទៅ -- គេហៅគាត់ទៅជាមួយដែរក្នុងឋានៈគាត់ជាអ្នកសិល្បៈមួយដែរបាទ។ ហើយមនុស្សដែលខ្ញុំទៅដល់ ឡានយើងឈប់នៅវត្តជ្រៃ ពេលថ្ងៃ ខ្ញុំ ហើយនិងគ្រូ ចាន់ ដែលជាគ្រូវិចិត្រសិល្បៈហ្នឹងបាននាំគ្នាដើរមកមោងឫស្សីៗ។ មកជួបអ្នកបើកឡានរបស់យើង ដែលគាត់អង្គុយនៅដុំថ្មមួយ ហើយពេលនោះនៅធុំក្លិនខ្មោចនៅឡើយ ដោយមាន -- ហើយគាត់យល់ពីអារម្មណ៍របស់ខ្ញុំ គាត់ថា ខ្មោចនៅជុំវិញនេះមិនទាន់កប់អីនៅឡើយទេ។ ហើយគាត់និយាយរហូតទៅដល់រឿងរ៉ាវនៅៗ គាត់ថាគាត់ជាអ្នកដឹកទាហានៗ ចាប់ពីស័ក្តិ១ឡើងទៅ មកភ្នំធិបដេ ដើម្បីឱ្យខ្មែរក្រហមបាញ់ចោលនោះ។ គាត់និយាយប្រាប់។ ខ្ញុំដឹងដោយសារគាត់។

[១៤:៣៧:០០]

**ស៖** សូមអរគុណដែលលោកបានបញ្ជាក់បំភ្លឺទៅលើព្រឹត្តិការណ៍ហេតុការណ៍មួយនេះ។ មុនពេលដែលយើងចាកចេញឈប់ពិភាក្សាទៅលើបញ្ហាមន្ទីរពេទ្យព្រែកហ្លួងនេះ គឺថាលោករៀបរាប់ហេតុការណ៍នៅក្នុងឆ្នាំ១៩៧៥ ត្រង់ខ្មែរលេខ ERN 00678793, អង់គ្លេសមានលេខ 00369707។ លោកបានរៀបរាប់ថា "ចាប់តាំងពីខែមិថុនា ឆ្នាំ១៩៧៥ ទឹកនៅស្ទឹងសង្កែឡើងជារៀងរាល់ថ្ងៃ ហើយលោកឃើញមានខ្មោចអត់ខោអាវហើម គោក្របីហើមហូរមកតាមស្ទឹងនោះ"។ នៅខាងក្រោមបន្តិចគឺលោកបានលើកឡើងថា "ខ្មោចហើមដែលអណ្តែតទឹកនោះគឺបានបង្ហាញថា ខ្មែរក្រហមចាប់ផ្តើមកាប់សម្លាប់

ប្រជាជនហើយ"។ ខ្ញុំសូមសួរលោក តើលោកឃើញខ្មោចហើមអណ្តែតទឹកនៅតាមស្ទឹង តាម -- ដូចដែលលោកបានរៀបរាប់នៅក្នុងសៀវភៅរបស់លោកនេះដោយផ្ទាល់ភ្នែកដែរឬទេ?

**ឆ៖** បាទ នៅខែ៦ ៧៥ នេះគឺអ្នកស្រុកទាំងខ្ញុំ ទាំងអ្នកស្រុកឃើញផ្ទាល់ភ្នែក ហូរទឹក -- ហូរតាមស្ទឹង មានខ្មើយ មានពួក មានខ្មោចស្រី មានខ្មោចប្រុស អត់មានគោក្របីទេ អត់ទេ។ ហើមអណ្តែតចុះទៅក្រោមតាមទៅតាមទន្លេសាបនេះទៅបាទ។ ត្រង់ថាគេ អត់ហ៊ាន គ្មានអ្នកណាហ៊ានសួរថា ខ្មោចហ្នឹងមកពីណា អីមកណា គ្មានអ្នកណាហ៊ានសួរទេបាទ។ គ្រាន់តែឃើញអ៊ីចឹង គឺម្នាក់ៗគិតធ្វើម៉េចយកសុខរៀងៗខ្លួនបាន គ្រាន់មានបារម្ភ មានការបារម្ភ។

[១៤:៣៩:២៤]

**ស៖** សូមអរគុណ។ នៅពេលនេះ ខ្ញុំសូមសួរលោកអំពីមន្ទីរពេទ្យមួយទៀតដែលលោកបម្រើការងារផងដែរ គឺអតីតពេទ្យទាហាននៅក្រុងបាត់ដំបង បានន័យថាជាពេទ្យដែលលោកបានធ្វើការងារនៅមុនខែមេសា ឆ្នាំ១៩៧៥។ នៅក្នុងសៀវភៅរបស់លោកត្រង់ចុងទំព័រ -- ជំពូក៤ ដែលលោកបានសរសេរ គឺថា "មិត្តហួន នេះបានចាត់លោកឱ្យធ្វើការងារនៅអតីតពេទ្យទាហាន ដែលគាត់ជាសមាជិកគណៈកម្មាធិការតំបន់៣"។ តើលោកអាចរៀបរាប់ជូនយើងខ្ញុំបានដែរឬទេថា ការគ្រប់គ្រងនៅមន្ទីរពេទ្យនោះ គឺយ៉ាងម៉េចដែរ? នរណាជាអ្នកកាន់កាប់គ្រប់គ្រងមន្ទីរពេទ្យនៅពេលដែលលោកទៅដល់ធ្វើការងារនៅទីនោះ?

**ឆ៖** បន្ទាប់ពីខ្ញុំបានធ្វើការនៅមន្ទីរពេទ្យព្រែកហ្លួងជាង២ខែ ខ្ញុំបានទទួលសំបុត្រមួយ ស៊ីញ៉េ -- ដាក់ឈ្មោះលោកមិត្ត ហឿន ឱ្យទៅធ្វើការនៅមន្ទីរពេទ្យយោធា មន្ទីរពេទ្យយោធាខ្មែរក្រហមដែលគេឈ្មោះថា ពាក្យខ្លីថា មន្ទីរពេទ្យ ព-២។ ព-២ នេះគឺមន្ទីរពេទ្យយោធាបាទ។ ហើយមិត្តហឿន ដែលៗហៅខ្ញុំនេះ គាត់ជាប្អូនថ្លៃគណៈភូមិភាគ របស់ ញឹម ហៅ តាកៅ ហៅ មូល សម្បត្តិ។

[១៤:៤១:៣៤]

**ស៖** ខ្ញុំប្រហែលជាស្តាប់អត់ទាន់ចំណុចចុងក្រោយដែលលោកឆ្លើយអម្បាញ់មិញ។ តើលោកអាចបញ្ជាក់សាថ្មីដែរទេ តើអ្នកណាគេដែរ ជាអ្នកកាន់កាប់មន្ទីរពេទ្យ ព-២ នេះ?

**ឆ៖** មន្ទីរពេទ្យ ព-២ មានប្រធានមួយនាក់ និងអនុប្រធានពីរនាក់។ អាហ្នឹងមន្ទីរពេទ្យ ព-២ គឺមន្ទីរពេទ្យយោធា។ ចំពោះមន្ទីរពេទ្យស៊ីវិលវិញ គេហៅថាមន្ទីរពេទ្យ ព-១។ មន្ទីរពេទ្យ ព-១ ក៏មានប្រធាន អនុប្រធានអ៊ីចឹងដែរ ប៉ុន្តែមន្ទីរពេទ្យទាំងពីរនេះ ព-១ និង ព-២ នៅក្រោមការគ្រប់គ្រងរបស់មិត្ត

ហឿន ដែលជាអនុប្រធាន -- សូមទោស អនុប្រធានទេ អនុប្រធានតំបន់៣ និងជាប្អូនថ្លៃ រស់ ញឹម ហៅ តាកៅ ហៅ មូល សម្បត្តិ បាទ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកសហព្រះរាជអាជ្ញា។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាក នៅបន្ទប់សម្រាប់ រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញ ដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញនៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៣នាទី ដល់ម៉ោង ១៥:០៥ នាទី)*

[១៥:០៦:០៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក វេជ្ជបណ្ឌិត ឈុនលី មុនពេលឈប់សម្រាក និយាយអំពីរចនាសម្ព័ន្ធអំណាចគ្រប់គ្រងទៅលើមន្ទីរពេទ្យ ព-១ និង ព-២។ ឥឡូវ ខ្ញុំសូមឲ្យលោកឆ្លើយសង្ខេបខ្លីៗ ព្រោះខ្ញុំចង់ចូលទៅប្រធានបទផ្សេងទៀត។ បើខ្ញុំយល់មិនច្រឡំទេ អ្នកជំងឺនៅមន្ទីរពេទ្យ ព-២ មន្ទីរពេទ្យយោធានោះ គឺថា

អ្នកជំងឺសុទ្ធតែជាកងទ័ពខ្មែរក្រហម តើអ៊ីចឹងមែនទេ?

[១៥:០៧:២៣]

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** បាទ ជាការពិត។

**ស៖** តាមការកត់សម្គាល់របស់លោក តើថ្នាំពេទ្យដែលផ្ដល់ជូននូវមន្ទីរពេទ្យហ្នឹង គឺមានថ្នាំសង្កូវហ្នឹងគ្រាប់គ្រាន់ទេ?

**ឆ៖** ដើមឡើយ យើងប្រើថ្នាំដែលនៅសេសសល់នៅក្នុងមន្ទីរពេទ្យ។ ដល់ចូលឆ្នាំ១៩៧៦ បានមានថ្នាំចិន គឺមានថ្នាំគ្រុនចាញ់ និងថ្នាំអង់ទីប៊ីយ៉ូទិក។ អាចគ្រាប់គ្រាន់ប្រើប្រាស់ក្នុងមន្ទីរពេទ្យ។

**ស៖** សូមអរគុណ។ ខ្ញុំសូមចូលចំណុចមួយ និយាយអំពីមុខងាររបស់មន្ទីរពេទ្យ នៅក្នុងសៀវភៅរបស់លោក លោករៀបរាប់បុគ្គលម្នាក់ដែលមានឈ្មោះ ប៊ុន ដែលជាប្រធានមន្ទីរពេទ្យ។ មានព្រឹត្តិការណ៍ពិសេសមួយដែលខ្ញុំចង់សួរទៅលោក ដែលលោករៀបរាប់អំពីសកម្មភាពរបស់ ប៊ុន។ ERN ជាភាសាខ្មែរ 00678815, ERN ជាភាសាអង់គ្លេស 00369723។ លោកបានរៀបរាប់ថា លោកបានជួប ប៊ុន ធ្វើការនៅខាងផ្នែកបន្ទប់វះកាត់។ (បាទ អ្នកបកប្រែសូមកែប្រែ គឺឈ្មោះ ផុន គឺធ្វើការនៅបន្ទប់វះកាត់) ហើយលោកបានរៀបរាប់ដូចខាងក្រោម៖ “ខ្ញុំចាំច្បាស់ថា ផុន ដឹកនារីអភព្វទៅរៀនវះកាត់ពិសោធន៍។ ដូចខ្ញុំតែធ្លាប់ឮពួកវានិយាយអំពីពេទ្យវះកាត់របស់ពួកវា”។

បាទ ខ្ញុំសូមបញ្ចប់ត្រឹមនេះ។ លោកអាចរៀបរាប់ជូនអង្គជំនុំជម្រះបានទេ ថាតើនូវអ្វីដែលបានកើតឡើងពាក់ព័ន្ធទៅជាមួយនឹងបុគ្គលឈ្មោះ ផុន នេះ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ! សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្ដីលោក នួន ជា!

[១៥:១០:៣៤]

**លោក ហ្សាស្តើ ប៉ោ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ទៅនឹងសំណួរនេះ ដោយសារវាក្រៅពីយុត្តាធិការពាក់ព័ន្ធទៅនឹងការជម្លៀសប្រជាជននៅដំណាក់កាលទី១ ឬទី២។ ហើយវាពាក់ព័ន្ធ -- ហើយក៏មិនពាក់ព័ន្ធរចនាសម្ព័ន្ធអំណាចដែរ គឺថាសំណួរដែលសួរត្រង់ផ្នែកនេះ គឺមិនពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០១ នោះទេ។ សូមអរគុណ។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតប។ ខ្ញុំគិតថា ជាការពាក់ព័ន្ធណាស់ ទាក់ទងទៅនឹងមុខងារនៃរចនាសម្ព័ន្ធអំណាចនៅទីកន្លែងនោះតែម្តង គឺថាខ្ញុំបានជ្រើសរើសសំណួរតិចបំផុត ដែលរៀបរាប់អំពីមុខងាររបស់មន្ទីរពេទ្យ ដូចដែលយើងបានឮហើយ ដែលស្ថិតនៅក្រោមរចនាសម្ព័ន្ធអំណាចរបស់ខ្មែរក្រហម។ ហើយការលើកឡើងរបស់ខ្ញុំគឺថា វាមានគោលនយោបាយដែលវាស្ថិតនៅក្នុងវិសាលភាព នៃសវនាការនេះ។ មេធាវីការពារក្តីគឺថា ការលើកឡើងមិនត្រឹមត្រូវទេ។ ដូច្នេះ ប្រសិនណាជាអង្គជំនុំជម្រះអនុញ្ញាត គឺថាខ្ញុំសូមសួរទៅលោកវេជ្ជបណ្ឌិតដោយសង្ខេបទេ ត្រង់ចំណុចនេះ។ សូមអរគុណ។

[១៥:១២:០០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:១៤:៣៦]

**ប្រធានអង្គជំនុំ៖**

សេចក្តីជំទាស់ និងសំអាងហេតុនៃសេចក្តីជំទាស់មិនមានមូលដ្ឋានត្រឹមត្រូវទេ។ ដូច្នេះ សេចក្តីជំទាស់មិនមានប្រសិទ្ធភាព ប៉ុន្តែក៏អង្គជំនុំជម្រះក៏កត់សម្គាល់ឃើញដែរថា សំណួរនេះគឺមានភាពពាក់ព័ន្ធតិចតួច។ ដូច្នេះ សូមព្រះរាជអាជ្ញារៀបចំសំណួរធ្វើយ៉ាងណាឲ្យមានការពាក់ព័ន្ធទៅនឹងអង្គហេតុ ដែលអង្គជំនុំជម្រះកំណត់ឲ្យធ្វើសវនាការ នៅក្នុងសំណុំរឿង០០២/០១។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** បាទ ខ្ញុំនឹងសួរសំណួរតែមួយសំណួរទេ ទៅលើវេជ្ជបណ្ឌិត ឈុនលី នូវអ្វីដែលកើតឡើងនៅមន្ទីរពេទ្យ ព-២ នេះ។

**ប្រធានអង្គជំនុំ៖**

រង់ចាំស្តាប់ការកែសម្រួលនូវសំណួរចុងក្រោយសិនទៅ លោកមេធាវីការពារក្តីលោក នួន ជា ព្រោះយើងបានសម្រេចរួចហើយ នូវលើសេចក្តីជំទាស់របស់លោកអម្បាញ់មិញ។ ទោះបីយ៉ាងណាក៏ដោយគឺយើងបានកត់សម្គាល់ឃើញថា មានផលពាក់ព័ន្ធតិចតួច។ អ៊ីចឹងហើយបានយើងប្រាប់ឲ្យទៅខាងតំណាងសហព្រះរាជអាជ្ញារៀបចំនូវសំណួរនោះឲ្យបានល្អប្រសើរ ដោយមានភាពពាក់ព័ន្ធទៅនឹង

អង្គហេតុដែលអង្គជំនុំជម្រះ កំណត់ឲ្យធ្វើសវនាការនៅក្នុងសំណុំរឿង០០២/០១។

[១៥:១៦:១២]

**លោក ហ្សាស្តើ ប៉ោ៖**

លោកប្រធាន ខ្ញុំមិនមែនមានន័យថាចង់ជំទាស់ទេ ក៏ប៉ុន្តែសំណួរដែលសហព្រះរាជអាជ្ញាបានសួរនេះគឺថាសំណួរនេះគឺមិនពាក់ព័ន្ធទេ។ ដូច្នេះ ខ្ញុំគាំទ្រទៅដល់សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ។ ហើយសូមលើកឡើងថាសំណួរសួរអម្បាញ់មិញនេះគឺមិនពាក់ព័ន្ធទេ។ សូមឲ្យសួរតែសំណួរណាដែលពាក់ព័ន្ធ ហើយខ្ញុំសូមឲ្យសហព្រះរាជអាជ្ញាបន្តចុះ។

**លោក អាប់ឌុលឡាក់ ថារីក៖**

គឺថាការជំទាស់នេះគឺថាត្រូវបានបដិសេធហើយ គួរណាស់តែជំទាស់ទៅលើបញ្ហាផ្សេង។ មេធាវីការពារក្តីហាក់ឡើងជំទាស់នេះ គឺជាការធ្វើឲ្យខាតបង់ពេលវេលារបស់យើងខ្ញុំ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

លោកតំណាងសហព្រះរាជអាជ្ញាបន្តការសួរ តាំងសំណួរចំពោះសាក្សី យើងបានសម្រេចរួចហើយលើសេចក្តីជំទាស់នេះ។

[១៥:១៧:០៧]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោកវេជ្ជបណ្ឌិត ឈុនលី ខ្ញុំសូមសួរឲ្យលោករៀបរាប់សង្ខេប ទៅលើចំណុចអម្បាញ់មិញនេះ។

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** បាទ រឿងនេះជា១រឿងមួយដែលខ្ញុំចាំមិនភ្លេចនៅក្នុងជីវិតរបស់ខ្ញុំ។ ថាព្រឹកមួយខ្ញុំឃើញនារីម្នាក់មកនៅក្នុងមន្ទីរពេទ្យ។ នាងស្លៀក -- នាងអាយុប្រហែល១៨ឆ្នាំ ស្លៀកសំពត់ខ្មៅ អាវសចាស់។ ខ្ញុំសួរនាងថា "នាងមកធ្វើអី?" នាងថា "ខ្ញុំគេហៅមកធ្វើ -- មក១រៀបចំឱសថនៅក្នុងមន្ទីរពេទ្យ ពីព្រោះខ្ញុំរៀនថ្នាក់ទី១១ ខ្ញុំចេះភាសាបារាំង" បាទ។ បន្ទាប់មកនាងនិយាយថា "ខ្ញុំដូចជាភ័យ១ មិនដឹងយ៉ាងម៉េច"។ ឮដូច្នេះ ពេទ្យខ្មែរក្រហមម្នាក់ស្រី មកជិតប្រាប់ថា "អូនឯងកុំភ័យចាំម៉ោងពីរ បងនាំអូនឯងទៅជួបប្រធានមន្ទីរពេទ្យ" បាទ។ ខ្ញុំក៏មកបន្ទប់ខ្ញុំទៅ។ ដល់ម៉ោងពីរ ខ្ញុំឃើញប្រធានមន្ទីរពេទ្យកាន់ប្រអប់វះកាត់មួយនៅនឹងដៃ ថ្នាំសណ្តំមួយដបថ្នាំសណ្តំ ហើយមានទាំង គេហៅថា *ឡាវ៉ាំងដូស្លូប* អាហ្វ៊ីង

សម្រាប់បញ្ចូលទីបទៅក្នុងបំពង់ខ្យល់ដើរយ៉ាងលឿនពីមុខខ្ញុំ។ ខ្ញុំលួចមើលតាមបង្អួចពីបន្ទប់ខ្ញុំទៅឃើញ ផុន ហ្នឹងប្រធានមន្ទីរពេទ្យចូលក្នុងបន្ទប់មួយ មួយសន្ទុះក្រោយមកស្រាប់តែឃើញខ្មែរក្រហមប្រហែលបួននាក់សែងនាងហ្នឹងអត់មានចលនាអីទាំងអស់ដេក គឺបន្ទាប់ពីត្រូវថ្នាំសណ្តំគឺថា សែងនាងហ្នឹងដេកលើប្រង់កា សែងយកមកដាក់ឡាន១រង់ចាំ១នៅមុខមន្ទីរពេទ្យ ហើយបើកឡានចេញទៅបាទ។

[១៥:១៩:១៨]

ហើយខ្ញុំក៏យល់ភ្លាមថា ពួកនេះយកនាងហ្នឹងទៅវះកាត់ គេហៅថា "វះកាត់ដកពិសោធន៍" ហើយ ខ្ញុំយល់ឃើញអ៊ីចឹងបាទ។ ខ្ញុំគិតពិចារណាស្រាប់តែប្រហែល១៥នាទីមក ឃើញពួកនោះដើរត្រឡប់មក មកពេទ្យវិញហៅខ្ញុំថា "បង ឈុនលី ជួយខ្ញុំផង១"។ ខ្ញុំថា "មានការអ្វី?" ថា "ឡានក្រឡាប់នៅមុខវត្តដំរីស"។ ហើយខ្ញុំក៏ទៅយកប្រធានមន្ទីរពេទ្យមកព្យាបាល ដែលមានរបួសប្រហែល ៤សង់ទីម៉ែត្រនៅដៃ១ឆ្វេងបាទ ដៃឆ្វេង។ ហើយបុគ្គលិកប៉ុន្មានទៀត គឺថាពួកគេព្យាបាលបាទ។ ពេលដែលខ្ញុំកំពុងតែរៀបចំដេរស្នាមរបួសប្រធាន ផុន នោះស្រាប់តែមានខ្មែរ -- ពួកខ្មែរក្រហមម្នាក់មកសួរថា "បងផុន ធ្វើម៉េច មីខ្មាំងនោះ តើយើងត្រូវធ្វើយ៉ាងម៉េច?" ហើយ ផុន បានឆ្លើយនៅចំពោះមុខខ្ញុំថា "សម្លាប់វាចោលទៅ"។ បាទ អាហ្នឹងគឺអ្វីដែលខ្ញុំបានឃើញ បានឮ។

ហើយបន្ទាប់មកទៀត ពេលល្ងាចគឺអាហ្នឹងបុគ្គលិកពេទ្យប្រាប់ខ្ញុំទេថា នាងនោះត្រូវសណ្តំនៅឡើយ នៅត្រូវថ្នាំសណ្តំនៅ ពួកហ្នឹងដាក់ប្រង់កា ហើយដឹករ៉ឺម៉កទៅវត្តប្រភិត ក្រោយ -- ជាប់លីសេមុនីវង្សហ្នឹង ហើយទៅបញ្ចូលក្នុងឡទាំងរស់តែម្តង"។ អាហ្នឹងគឺ អាត្រង់ហ្នឹងគឺថាបុគ្គលិកពេទ្យវានិយាយប្រាប់ខ្ញុំទេ បាទ។ អាមុននេះ គឺខ្ញុំឃើញ ខ្ញុំឮបាទ ប៉ុណ្ណឹងបាទ។

[១៥:២១:១៦]

**សៈ** សូមអរគុណវេជ្ជបណ្ឌិត ឈុនលី។ ខ្ញុំសូមបន្តទៅមុខទៀត ចូលទៅប្រធានបទផ្សេង។ ខ្ញុំសូមចំណាយពេលបន្តិចទេ ទៅលើប្រធានបទថ្មីនេះ។ មន្ទីរពេទ្យមួយទៀតនោះ ដែលលោកបានធ្វើការ-- ដែលលោកបានសរសេរនៅក្នុងសៀវភៅរបស់លោក គឺជាមន្ទីរពេទ្យស៊ីវិល ហៅថា "ព-១" ដែលលោកបានលើកឡើងពីខាងដើម។ ខ្ញុំសួរសំណួរមួយចំនួនពាក់ព័ន្ធទៅនឹងការអនុវត្តគោលនយោបាយនៅទីនោះ។ នៅក្នុងសៀវភៅរបស់លោកដែលថា នៅមន្ទីរពេទ្យសម្រាប់ព្យាបាលជនស៊ីវិល គឺមិនមែនកងទ័ពខ្មែរក្រហមទេ គឺថានៅទីនោះមានបុគ្គលិកមួយឈ្មោះ រ៉ន ដែលលោក គឺថាគេកំណត់ថា ជាខ្មាំងនោះ គឺថា ERN 00678842, ERN អង់គ្លេស 00369741។ តើលោកអាចជម្រាបអង្គជំនុំជម្រះទេ លោក

ស្គាល់មនុស្សនេះដែលជាអ្នកតាមដានប្រជាជនដើម្បីកំណត់ថា អ្នកណាជាខ្មាំង ហើយត្រូវយកចេញទៅនោះលោកស្គាល់ដោយរបៀបណា?

[១៥:២៣:០៣]

**ឆ៖** ខ្ញុំធ្វើការនៅមន្ទីរពេទ្យយោធា ១៦ខែ។ បន្ទាប់មក ខ្ញុំធ្វើការនៅមន្ទីរពេទ្យស៊ីវិលជាង២ខែ ហើយខ្ញុំចេញនៅថ្ងៃ៣១ បន្ទាប់ពីគណៈប្រតិភូចិនមកទស្សនកិច្ចមន្ទីរពេទ្យ ព-១ ហ្នឹងនៅថ្ងៃ៣០ មករា ១៩៧៧ បាទ។ ឈ្មោះ រ៉ន នេះ គឺថាវាគ្មានការងារអីជាប់លាប់ទេ ព្រោះវាកាន់ឡាប្ញ ប៉ុន្តែឡាប្ញ គ្មានការងារធ្វើទេ។ រ៉ន នេះមានលក្ខណៈពិសេស គឺថាមុខវាញញឹមជានិច្ច បើពេលណាវាខឹងវាកាន់តែញញឹមឡើង។ ហើយវាគួរសមណាស់ដើរទៅសួរអ្នកជំងឺអីអឺចឹង សួរអឺចឹង ដឹងថាមន្ត្រីរាជការ គឺយប់ឡើង គឺឃើញឡានឡង់រ៉ូវែ មកដឹកអ្នកជំងឺចេញហើយ។ ទោះបីស្ថានភាពអ្នកជំងឺយ៉ាងណាក៏ដោយ បាទ។ អាហ្នឹងគឺតួនាទីរបស់ រ៉ន បាទ។

[១៥:២៤:២៤]

**ស៖** តើលោកដឹងថា គេយកប្រជាជនទៅបាត់ហើយ គេកំណត់ថាជាខ្មាំងហ្នឹងលោកដឹងដោយរបៀបណា?

**ឆ៖** ខ្ញុំគ្រាន់តែដឹងថា ឡានមក -- ឡានធម្មតានៅក្នុងរបបខ្មែរក្រហមមិនសូវមានឡានចេញចូលទេ ឡាន -- ជាញឹកញាប់ខ្ញុំយាម ខ្ញុំតែងតែមើលពីកន្លែងខ្ញុំធ្វើការមក ឃើញឡានឡង់រ៉ូវែហ្នឹង ឡានហ្នឹងចូល ហើយចេញទៅវិញ។ ចេញទៅ ហើយអ្នកជំងឺគឺ រ៉ន ដែលចេញហ្នឹង គឺបាត់ហើយអ្នកជំងឺ។

**ស៖** សំណួរចុងក្រោយទៅលើចំណុចនេះ។ ទំព័រដែលខ្ញុំបានលើកឡើងពីខាងដើម គឺថាមានខ្លឹមសារ ខ្ញុំសូមដកស្រង់ "តាមរយៈសកម្មភាពតាមដានរបស់គាត់ រ៉ន គឺថាគាត់តាមដានខ្មាំងបដិវត្តន៍ ដូចជាអតីតមន្ត្រីរាជការ នាយទុន គឺគាត់ត្រូវរាយការណ៍ពីមុខសញ្ញាទាំងអស់នេះទៅជូនថ្នាក់លើ"។ តើខ្ញុំសង្ខេបប៉ុណ្ណោះ ត្រឹមត្រូវដូចអ្វីដែលលោកបានបានកត់សម្គាល់នៅពេលដែលលោកធ្វើការនៅមន្ទីរពេទ្យ ព-១ ដែរទេ ដែលថាគេតាមដានមន្ត្រីរាជការ តាមដានមន្ត្រីរដ្ឋការ បញ្ញវន្ត ក៏ដូចជានាយទុន រួចហើយរាយការណ៍ទៅថ្នាក់លើនោះ?

[១៥:២៥:១២]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយ! ក្បាលមីក្រូមិនទាន់ប្រតិបត្តិការទេ។

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** បាទ គ្រាន់តែថាគេរាយការណ៍ទៅថ្នាក់ ប៉ុន្តែយើងមិនដឹងថាថ្នាក់លើហ្នឹងនៅកន្លែងណាទេ ប៉ុន្តែឡានមកតែម្តង។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** សូមអរគុណ។ មុននឹងយើងបញ្ចប់អំពីដំណើរការមន្ទីរពេទ្យនេះ និយាយអំពីដំណើរការប្រព្រឹត្តទៅរបស់មន្ទីរពេទ្យនេះ។ ខ្ញុំសូមសួរលោកពីព្រឹត្តិការណ៍មួយដែលកើតនៅថ្ងៃទី៣០ មករា ៧៧ ដែលលោកបានលើកឡើងពីខាងដើមមកនោះ នៅពេលនោះគឺថាលោកមានការទទួលខុសត្រូវមួយ។ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះសង្ខេបទេ ថាតើៗលោកចាត់ចែងអំពីការទទួលខុសត្រូវរបស់លោកហ្នឹងដោយរបៀបណាដែរ?

[១៥:២៧:៣២]

**ឆ៖** ខ្ញុំអត់មានការទទួលខុសត្រូវអ្វីនៅក្នុងមន្ទីរពេទ្យខ្មែរក្រហមទេ។ ខ្ញុំជាបុគ្គលិកទាបបំផុត ឬមួយអាចនិយាយថា ជាអ្នកទោស អ្នកទោសម្នាក់នៅក្នុងរបបខ្មែរក្រហមក៏បានដែរ នៅក្នុងមន្ទីរពេទ្យក៏បានដែរ។ អត់មានឋានៈអីខ្ពង់ខ្ពស់ទេបាទ ប៉ុន្តែគ្រាន់តែការងារបច្ចេកទេស បើនៅពេទ្យទាហាន អ្នកទាហានឈឺខ្លាំង គេហៅខ្ញុំទៅព្យាបាល ប៉ុន្តែមកពេទ្យស៊ីវិលវិញ ត្រង់ប្រជារាស្ត្រឈឺខ្លាំងយ៉ាងណាគេអត់ត្រូវការពួកខ្ញុំទេ។ ដូច្នេះខ្ញុំគ្មានតួនាទីអ្វីទេ។ គ្រាន់តែនៅថ្ងៃ៣០នោះ នៅថ្ងៃ៣០ប្រធានមន្ទីរពេទ្យដាក់បញ្ជាឲ្យបុគ្គលិកទាំងអស់សម្អាតមន្ទីរពេទ្យទាំងខាងក្រៅ ទាំងខាងក្នុង។

នៅយប់ថ្ងៃ២៩ ម៉ោងពីរភ្លឺ គឺបុគ្គលិកទាំងអស់ចាប់សម្អាតអគារទាំងក្នុង ទាំងក្រៅ ដោយមិនខ្វល់អ្នកជំងឺដេកលក់ឡើយបាទ ហ្នឹងមួយផ្នែក។ ដល់ភ្លឺឡើង ម៉ោងប្រាំបី ស្អាតអស់ហើយ ម៉ោងប្រាំបីស្រាប់តែបញ្ជាមួយថាឲ្យបិទបង្អួចទាំងអស់ ហើយអត់ឲ្យអ្នកជំងឺ អត់ឲ្យបុគ្គលិក អ្នកជំងឺចេញចូលដើរទៅណាមកណាទេ ព្រោះធម្មតាម៉ោងប្រាំបី នៅពេទ្យស៊ីវិលម៉ោងប្រាំបីព្រឹកបាយ ម៉ោងប្រាំល្ងាចបាយ។ ហើយដល់ម៉ោងដប់ខ្ញុំលួចមើលពីអគារដែលខ្ញុំធ្វើការ ឃើញឡានមួយដឹកៗប្រតិភូចិនចូលមកមន្ទីរពេទ្យទៅអគារមួយយ៉ាងវែង។ ហើយពួកចិននេះគឺស្លៀកខោខៀវ អាវខ្លី អាវសដៃខ្លី ហើយប្រហែល១ម៉ោងក៏ឃើញឡានហ្នឹងចេញទៅវិញ។ បាទ អាហ្នឹងៗ ថ្ងៃ៣០ មករា ឆ្នាំ១៩៧៧។ ដល់ល្ងាចគេហៅពួកខ្ញុំទៅប្រាប់ ព្រោះមានប្អូននាក់ធ្វើការនៅ គេប្រាប់ថាអង្គការសុំឲ្យបងទៅសហករណ៍វិញចុះ។ ដូច្នេះថ្ងៃ៣១ ខែមករា ១៩៧៧ ខ្ញុំក៏ត្រឡប់ទៅសហករណ៍វិញ ធ្វើស្រែរហូត។

**ស៖** តើមានវេជ្ជបណ្ឌិតហ្នឹង តែរូបលោកហ្នឹងមួយទេឬ ដែលគេត្រឡប់ឲ្យទៅធ្វើការនៅសហ-ករណ៍វិញនោះ ឬក៏មានវេជ្ជបណ្ឌិតផ្សេងទៀតត្រូវគេឲ្យទៅធ្វើការនៅសហករណ៍ដែរ?

**ឆ៖** នៅបាត់ដំបង ខ្មែរក្រហមបង្កើតមន្ទីរស្រុក ដែលយកវិទ្យាល័យធ្វើជាមូលដ្ឋានសុខាភិបាល ហើយមានវេជ្ជបណ្ឌិតម្នាក់ ឬពីរមកធ្វើការនៅកន្លែងហ្នឹង និងអាំងហ្វេមីញេពីរបីនាក់។ មានបួនប្រាំកន្លែងបាទ។ អាហ្នឹងហៅថាមន្ទីរពេទ្យស្រុក។ ចំពោះខ្ញុំ ខ្ញុំដែលនៅមន្ទីរពេទ្យ ព-២ នេះជាមន្ទីរពេទ្យតំបន់ បាទមានតែម្នាក់ខ្ញុំទេ។ ដល់បន្ទាប់ ដល់ខែ -- បាន១៦ខែ ខ្ញុំមកនៅមន្ទីរពេទ្យ ព-១ ដែលមន្ទីរពេទ្យស៊ីវិល នោះមានគ្នាបួននាក់ គឺខ្ញុំម្នាក់ វេជ្ជបណ្ឌិតម្នាក់ទៀត អ្នកបច្ចេកទេសវិទ្យុផ្ទុះថត ហើយនិងជាងទឹកភ្លើងម្នាក់បាទ។

[១៥:៣១:៤៩]

**ស៖** សំណួររបស់ខ្ញុំនោះគឺថា វេជ្ជបណ្ឌិតមានត្រូវបានគេបញ្ជូនទៅសហករណ៍ដែរឬទេក្នុងអំឡុងពេលជាមួយនឹងពេលនោះ?

**ឆ៖** ដល់ពេលចេញពីមន្ទីរពេទ្យ ហ្នឹងបានទៅសហករណ៍វិញ ធ្វើស្រែធ្វើអីដូចគេដូចឯង។

**ស៖** ប្រហែលជាមានបញ្ហាបកប្រែ ក៏ប៉ុន្តែខ្ញុំសូមធ្វើបន្តទៅមុខទៀត។ នៅចុងជំពូកទី៦ នៃសៀវភៅរបស់លោក លោកបានធ្វើការសន្និដ្ឋានឆ្លងតាមបទពិសោធន៍របស់លោកបំពេញការងារនៅក្នុងពេលដែលលោកធ្វើការងារនៅទីនោះ។ ខ្ញុំសូមសួរលោកត្រង់ចំណុចនេះ ខ្មែរ ERN គឺ 006788846, អង់គ្លេសគឺ 00369744។ ខ្ញុំនឹងអានចំណុចខ្លីចំនួនពីរ ទី១គឺលោកនិយាយថា "អ្នកឈឺភាគច្រើនគឺមកពីសហករណ៍ គឺបានមកជាប់នៅមន្ទីរពេទ្យ ព-១ ហើយទ្រព្យសម្បត្តិទាំងឡាយត្រូវបានគេឆក់ប្លន់ដោយខ្មែរក្រហម។ អ្នកជំងឺខ្លះនោះត្រូវបានទទួលរងក្លាយទៅជាអ្នកដែលត្រូវបានគេយកមកធ្វើពិសោធ ហើយមន្ទីរពេទ្យព-១ នេះគឺជាកន្លែងសម្រាប់ខ្មែរក្រហមនោះរកមើលថាតើអ្នកណាគេជាខ្មាំងប្រឆាំងនឹងបដិវត្តន៍។ និយាយដោយខ្លីមក មន្ទីរពេទ្យឃោធា គឺជាកន្លែងដែលថែទាំកម្មាភិបាលទាហានខ្មែរក្រហម។ មន្ទីរពេទ្យស៊ីវិលគឺជាបន្ទប់រង់ចាំការកាប់សម្លាប់សម្រាប់ប្រជាជនកម្ពុជាតែប៉ុណ្ណោះ។ ចំណុចនេះហើយដែលលោកធ្វើការបែងចែករវាងមន្ទីរពេទ្យស៊ីវិល និងមន្ទីរពេទ្យឃោធា។ តើនេះជាការសង្ខេបត្រឹមត្រូវនូវអ្វីដែលលោកបានឃើញនៅទីនោះដែរឬទេ នៅពេលដែលលោកបម្រើការងារនៅមន្ទីរពេទ្យនោះ?

[១៥:៣៤:២៥]

**ឆ៖** នេះគឺជាការសន្និដ្ឋានរបស់ខ្ញុំបាទ។ នៅមន្ទីរពេទ្យឃោធា អ្នកជំងឺគឺថាបើមានៗសុខភាពល្អ

គឺថាគ្មានជំងឺដែលទាក់ទងនឹងអនាម័យដូចជារាកមួល គ្មានជំងឺដែលទាក់ទងនឹងកង្វះអាហាររូបបត្ថម្ភទេ ហ្នឹង នៅពេទ្យយោធា ទី១។ ទី២ អ្នកជំងឺពេទ្យយោធា ពេលហូបបាយអង្គុយនៅតុ នៅតុមូល នៅតុៗ។ ហើយម្ហូបថ្វីបើថាវាមិនសម្បូរណាស់ណា ក៏វាគ្រប់គ្រាន់ដើម្បីទ្រទ្រង់ជីវិតដែរ មានត្រី សាច់ បន្លែ អ៊ីចឹងបាទ។ ចំពោះពេទ្យស៊ីវិលវិញ គឺអ្នកជំងឺភាគច្រើន គឺមានជំងឺទាក់ទងទៅនឹងអនាម័យ ដូចជារាកមួល ទាក់ទងនឹងកង្វះអាហារូបបត្ថម្ភ ដែលហូបមិនគ្រប់គ្រាន់ មានហើម មានស្គម ជាដើម។ ហើយពេលហូប តែពីរពេលទេ ទាហានបីពេល។ ហើយពេលហូប គឺអង្គុយនៅតាមផ្លូវៗដើរ អង្គុយជាជួរអ៊ីចឹង ហើយគេដាក់ម្ហូបនៅចំកណ្តាលអ៊ីចឹង ឲ្យហូបអ៊ីចឹងទៅ។ អាហ្នឹងមួយ។

មួយទៀត អ្នកជំងឺនៅពេទ្យស៊ីវិល គឺថានៅពេលដែលស្លាប់ គឺទ្រព្យសម្បត្តិប៉ុន្មាន គឺថាត្រូវពេទ្យខ្មែរក្រហមយកទាំងអស់។ ដូចជាគ្រូពេទ្យបង្រៀនម្នាក់ស្លាប់ ខ្ញុំស្គាល់ គាត់ប្រាប់ខ្ញុំថា មានមាសប្រាំពីរជី។ គាត់សុំឲ្យខ្ញុំយក ប៉ុន្តែខ្ញុំមិនយក ដល់គាត់ស្លាប់ ថ្ងៃហ្នឹងស្លាប់ពីរនាក់ព្រឹកឡើង ស្លាប់ពីរនាក់។

ខ្មែរក្រហមទុកអ្នកជំងឺពីរនាក់ហ្នឹងដែលស្លាប់ហ្នឹង ឲ្យនៅជាមួយអ្នកជំងឺដែលរស់ហ្នឹង ទាល់តែល្ងាច តែយប់។ យប់ឡើង បានរ៉ឺម៉កដឹកអ្នកជំងឺហ្នឹង ចេញទៅក្រៅ បាទ។ ហើយទ្រព្យសម្បត្តិទាំងប៉ុន្មាន គឺខ្មែរក្រហមយកទាំងអស់។ មិនមែនគ្រាន់តែទ្រព្យសម្បត្តិទេ សូម្បីតែថ្នាំក៏ដោយ ថ្នាំចិនដែលចិនឲ្យនោះ គឺថាបានដល់អ្នកជំងឺតិចតួចណាស់ ព្រោះខ្មែរក្រហមលួចៗ ដាក់ក្នុងហោប៉ៅវា។ ហើយពួកខ្មែរក្រហមស្អប់ពួកអ្នកជំងឺណាដែលមានស្បែក គេហៅស្បែកៗស មិនចូលចិត្ត បាទ។

[១៥:៣៧:១៥]

ហើយមួយទៀត ការដែលយកជំងឺទៅវះកាត់ ក៏ដូចនៅមន្ទីរពេទ្យ ព-២ ដែរ ខ្ញុំឃើញៗម្តង ប៉ុន្តែខ្ញុំឃើញអ្វី និយាយអ្វីដែលខ្ញុំឃើញទេ គឺមានស្ត្រីម្នាក់គាត់ឆ្កួត។ គាត់ឆ្កួត គាត់រាំៗ ច្រៀង ដើរចេញពីមន្ទីរពេទ្យ ហើយបុគ្គលិកពេទ្យកាន់រំពាត់ ដើរវ៉ៃចូលក្នុងមន្ទីរពេទ្យ។ ដល់ក្រោយមក ខ្ញុំឃើញប្រធានមន្ទីរពេទ្យប្រាប់ខ្ញុំថា “ហ្នឹងជូនអ្នកជំងឺទៅភូមិវិញ”។ តាមពិត គឺថាអត់ទេ គឺថាខ្ញុំឃើញអ្នកជំងឺហ្នឹងគេដាក់លើប្រង់កា ចាក់ថ្នាំសណ្តំ ដោយអត់មានកម្រើកអ្វីសោះ រួចទៅបើកចេញទៅក្រៅ។ អាហ្នឹង គឺខ្ញុំអាចគ្រាន់តែសន្និដ្ឋានចេញក្រៅណាស់ គឺទៅដើម្បីវះកាត់។ នេះ ខ្ញុំនិយាយអ្វីដែលខ្ញុំបានឃើញ ត្រង់វះកាត់ ខ្ញុំមិនបានឃើញទេ គ្រាន់តែនិយាយអ្វីដែលខ្ញុំបានឃើញ គឺឃើញដឹកអ្នកជំងឺដាក់ថ្នាំសណ្តំ ហើយចេញទៅក្រៅ។ ហើយមួយទៀត ពេទ្យស៊ីវិលក៏ជាកន្លែងគ្រោះថ្នាក់មួយដែរ គឺថាស៊ើប ជាកន្លែងដែលគេស៊ើបសួររក គេហៅថា “ខ្មាំង” ដែលមានមន្ត្រីរាជការជាដើម។ ហើយៗថាជាខ្មាំងហើយ គេនាំចេញ

ទៅបាត់ហើយ។ សូមអស់ប៉ុណ្ណឹង។

[១៥:៣៨:៥៥]

**ស៖** សូមអរគុណ។ យើងចូលទៅប្រធានបទផ្សេងពីនេះបន្តិចមួយទៀត។ នៅក្នុងសៀវភៅរបស់លោក លោកបានរៀបរាប់ "ក្នុងអំឡុងខែសីហា ឆ្នាំ១៩៧៥ នៅពេលនោះ គឺលោកមានឱកាសទៅលេងគ្រួសាររបស់លោកនៅភូមិដំរីស្លាប់ ហើយលោកបានរៀបរាប់អំពីអ្នកថ្មីដែលបានមករស់នៅ នៅក្នុងភូមិនោះ"។ គឺត្រង់ទំព័រលេខខ្មែរ 00678804, ហើយនិងបន្ទាប់ទំព័រមួយទៀត បន្ទាប់នេះ អង់គ្លេស គឺ 003697156។ លោកបានរៀបរាប់នៅទីនេះថា "ឃើញមានអ្នកថ្មីមករស់នៅក្នុងក្រុងបាត់ដំបង"។ ហើយខ្ញុំនឹងអានចំណុចមួយខ្លី "ខ្ញុំបានជួបពេទ្យមួយរូប ដែលមានឈ្មោះស្រដៀងខ្ញុំដែរគឺ ឆិន លី ហើយនិងមួយទៀតឈ្មោះ ឡុង ណារ៉េត ពួកគេនិយាយថា គេយក -- ខ្មែរក្រហមយកពួកគេមកពីភ្នំពេញ ហើយដាក់នៅតាមស្ថានីយរថភ្លើងនីមួយៗ ឧទាហរណ៍នៅខេត្តពោធិ៍សាត់ និងមោងឫស្សី និងក្រុងបាត់ដំបង និងស្ថានីយរថភ្លើងមួយទៀត ដែលធ្វើដំណើរមកស៊ីសុផុន"។ ដូច្នេះ ខ្ញុំសូមឲ្យលោកបញ្ជាក់ទៅមើល៍ ថាតើលោកពិតជាបានឃើញអ្នកជាអ្នកប្រជាជនថ្មីនោះ ត្រូវបានគេដឹកយកមកនៅភូមិដែលលោកនៅ -- រស់នៅនេះដែរឬទេ លោក ឈុនលី?

[១៥:៤១:០៩]

**ឆ៖** បាទ ពេលនោះឯងជាពេលដែលខ្មែរក្រហមជម្លៀសប្រជារាស្ត្រពីៗភ្នំពេញ មកបាត់ដំបងតាមរទេះភ្លើង។ បាទ ហើយមួយចំនួនគឺថា មកនៅក្នុងភូមិរបស់ខ្ញុំ។

**ស៖** សូមអរគុណ។ ខ្ញុំនឹងសួរសំណួរលោកមួយសំណួរទៀត។ តើលោកអាចជម្រាបជូនតុលាការបានដែរឬទេ -- បាទ ប៉ុន្តែខ្ញុំសូមសួរលោកដូច្នេះជាមុនសិន។ តើមានស្ថានភាពអ្វីចំពោះអ្នកដែលត្រូវបានគេជម្លៀសមកដល់ខេត្ត -- ក្រុងបាត់ដំបងនោះ តើគេមានរៀបចំកន្លែងស្នាក់នៅ ឬក៏ម្ហូបអាហារឲ្យពួកគេដែរឬទេ?

**ឆ៖** អ្នកដែលជម្លៀសមកនោះគឺថា គ្រាន់តែ -- ម្ហូបអាហារដោះស្រាយខ្លួនឯងទាំងអស់។ គ្រាន់តែប្រជារាស្ត្រដែលអ្នកភូមិហ្នឹង គឺថាមាន ដីទំនេរៗត្រង់ណា សង់ខ្ទមនៅត្រង់ហ្នឹងទៅបាទ ឬមួយផ្ទះណាដែលធំ ចែករំលែកឲ្យអ្នកដែលមកពីឆ្ងាយនៅជាមួយ ប៉ុន្តែភាគច្រើនគាត់សង់នៅផ្ទះ គាត់សង់នៅដីទំនេរ សង់ជាខ្ទមតូចៗ។

**ស៖** សូមអរគុណលោកច្រើន។ នៅក្នុងសៀវភៅលោក លោកសរសេរបន្ថែមទៀត រៀបរាប់

អំពីស្ថានភាពកើតឡើងចំពោះដែលត្រូវបានគេភៀសខ្លួន ត្រង់ខ្មែរលេខ ERN 00678836, អង់គ្លេសគឺ 00369736។ ខ្ញុំរៀបរាប់អ្វីដែលលោកសរសេរឡើងវិញ នៅក្នុងចំណុចនោះលោករៀបរាប់ថា "មានការអត់ឃ្លានកើតឡើង" ហើយលោកក៏បានលើកឡើងថា "ក្នុងចំណោមគ្រួសារជនជាតិអ៊ីស្លាមប្រហែលជា១០០នាក់ មានតែពាក់កណ្តាលទេដែលនៅរស់"។ តើលោកអាចជម្រាបតុលាការដោយសង្ខេបបានដែរឬទេថា តើលោកបានឃើញអ្វីខ្លះ ហើយតើលោកបានដឹងអ្វីខ្លះចំពោះការដែលអត់ឃ្លានកើតឡើងចំពោះប្រជាជន ដូចដែលខ្ញុំបានបញ្ជាក់អម្បាញ់មិញនេះ?

[១៥:៤៤:៣៤]

**ឆ៖** ការអត់ឃ្លាននេះ មិនមែនកើតឡើងនៅឆ្នាំ៧៥ទេ គឺថា បើខ្ញុំមិនច្រឡំទេ គឺនៅចុងឆ្នាំ៧៦ៗ បាទ មិនមែន៧៥ទេ ព្រោះ ៧៥ យើងនៅសល់ម្ហូប។ ហើយពេលដែលប្រជារាស្ត្រពីភ្នំពេញមករស់នៅក្នុងភូមិៗខ្ញុំនោះ ខ្ញុំខ្លួនខ្ញុំ ទាំងម្តាយខ្ញុំបានដើរទៅមើល ក្រែងលោជួបកូនចៅ ក្រែងលោជួបបងប្អូនបាទ។ អាហ្នឹងបាន -- ប៉ុន្តែអត់បានជួបទេ ជួបតែមិត្តភក្តិបាទ។ ហើយពេលនោះឯងគឺថាម្ហូបអាហារគឺមិនទាន់ៗដាច់នៅឡើយទេ គឺថានៅចុង៧៦នេះបានស្លាប់ច្រើន ឆ្នាំ៧៦។ ស្លាប់ គឺថាគ្រួសារចាម គឺអស់ពាក់កណ្តាលគ្រួសារចាម ប្រហែលពាក់កណ្តាលគ្រួសារចាម ហើយចាមណាដែលគ្នាឈឺមិនទៅធ្វើការ គេបង្អត់អាហារទៀត ហើយគេបង្ខំចាមឲ្យស៊ីសាច់ជ្រូកទៀតបាទ។

**ស៖** ខ្ញុំសូមអនុញ្ញាតសួរលោកបន្ថែមបន្តិច។ ពាក់ព័ន្ធទៅនឹងការបង្អត់អាហារ ហើយនិងស្ថានភាពកើតឡើងជុំវិញការបង្អត់អាហារនេះ នៅត្រង់ខ្មែរ ERN លេខ 00678882, ERN ជាភាសាអង់គ្លេសគឺ 00369727។ លោកបានរៀបរាប់ព្រឹត្តិការណ៍ក្រោយខ្មែរ -- ក្រោយចូលឆ្នាំខ្មែរឆ្នាំ១៩៧៦ មានន័យថា គឺការកើតឡើងនូវពេលដែលការបង្អត់អាហារនោះ។ លោកនិយាយថា "ខ្មែរក្រហមធ្វើដូចជាស្បៀងអាហារ ស្រូវត្រូវបានអស់ហើយ ក៏ប៉ុន្តែគេឃើញមានឡានទៅដឹកស្រូវអង្ករចេញពីឃ្លាំង"។ ខ្ញុំសូមសួរលោក តើលោកដឹងចំណុចនេះតាមរបៀបណាដែរ ដែលលោកថាគេឃើញដឹកស្រូវអង្ករនោះជាទៀងទាត់ចេញពីឃ្លាំងទៅ?

[១៥:៤៦:៣០]

**ឆ៖** ខ្មែរក្រហមបានកែនប្រជារាស្ត្រឲ្យទៅរុះរើផ្ទះឈើនៅក្រុងបាត់ដំបង ដើម្បីសង់ឃ្លាំងមួយគេហៅថា "ឃ្លាំងធំ" សម្រាប់ដាក់អង្ករ។ ហើយជាទៀងទាត់គឺថាទាំងខ្ញុំ ទាំងអ្នកស្រុកឃើញឡានមកដឹកស្រូវពីឃ្លាំងនោះចេញទៅក្រៅ មិនដឹងទៅណា ប៉ុន្តែចេញទៅក្រៅបាទ។ ហើយនៅពេលដែលប្រជា

រាស្ត្រៗ អង្កាល់ហ្នឹងគេហៅថា “សហករណ៍” គឺបើកអង្ករពីឃ្លាំងមកដែរ ប៉ុន្តែគ្រាន់តែមួយគ្រប់ៗ។ រួចដល់ក្រោយគេថា “អង្ករជិតអស់ៗ” អ៊ីចឹង។ នេះគឺអ្វីដែលខ្ញុំឃើញ ព្រោះឡានៗមកដឹកៗអង្ករពីឃ្លាំងធំគេហៅថា “ឃ្លាំងឃុំ” បាទ។

[១៥:៤៨:៣៥]

**សៈ** សូមអរគុណ។ ប្រសិនបើយើងចូលទៅលើប្រធានបទមួយខ្លីវិញម្តង គឺនៅក្នុងនោះលោកនិយាយអំពីប្រជាជនដែលរស់នៅក្នុងឃុំវត្តគរ។ ចំណុចនេះចាប់ផ្តើមខ្មែរ ERN លេខ 00678828, អង់គ្លេសគឺ 00369731។ លោកបានសរសេររៀបរាប់នៅក្នុងនោះថា “លោកស្គាល់គ្រួសារ នួន ជា ហើយគាត់ហ្នឹងរស់នៅ -- គ្រួសារហ្នឹងរស់នៅក្នុងផ្ទះមួយក្នុងវត្ត -- ឃុំវត្តគរ”។ ខាងក្រោមនោះបន្តិចលោកបានសរសេរថា សូមដកស្រង់សម្តីលោកសរសេរ “ក្រោមរបបខ្មែរក្រហមឃុំវត្តគរ ទទួលបាននូវការប្រព្រឹត្តមួយពិសេសខុសពីឃុំវត្តគរ គឺប្រជាជនមានស្ថានភាពយ៉ាប់យ៉ឺន។ ហើយខាងអ្នកវត្តគរនេះឃុំវត្តគរនេះបានទទួលរបបអាហារគ្រប់គ្រាន់”។ ក្រោមនេះបន្តិច “នៅពេលដែលប្រជាជននៅឃុំ ដទៃនោះកំពុងតែអត់អាហារ របបអាហារនៅឃុំវត្តគរមិនផ្លាស់ប្តូរនោះទេ។ ម្តាយរបស់ នួន ជា ទទួលបាននូវការប្រព្រឹត្តល្អគ្រប់គ្រាន់ ហើយគាត់ទទួលបាននូវទអង្ករ ស្ករ និងគ្រឿងឧបត្ថម្ភផ្សេងទៀតគ្រប់គ្រាន់”។ តើចំណុចនេះលោកបានដឹងដោយសារតែបទពិសោធន៍របស់លោកធ្លាប់ឆ្លងកាត់ឃើញផ្ទាល់ក្នុងរបបខ្មែរក្រហមនោះ ឬក៏យ៉ាងម៉េច?

**ឆៈ** ខ្ញុំស្គាល់ភូមិវត្តគរ ពីព្រោះខ្ញុំធ្វើការទៅបាត់ដំបងតាំងពីឆ្នាំ១៩៦៧ បាទ។ ខ្ញុំស្គាល់ភូមិវត្តគរគឺថា អ្នកភូមិគឺសុទ្ធតែអ្នកធូរធារ ហើយបញ្ញវន្តមួយចំនួនចេញពីឃុំវត្តគរហ្នឹងឯង។ អ្នកបញ្ញវន្តក៏ដោយនិន្នាការផ្សេងៗគ្នាក្តី គឺថាចេញពីវត្តគរហ្នឹងឯង បាទ។ ហើយគ្រួសារ នួន ជា ក៏ខ្ញុំស្គាល់។ ហើយបងប្អូន -- និយាយមែនទែនជាគ្រួសារល្អ គ្រួសារហ្នឹងជាគ្រួសារល្អទេបាទ។ គ្រួសារល្អដូចគេដូចឯងអ៊ីចឹង។

ហើយខ្ញុំស្គាល់គាត់រហូតដល់ខ្ញុំធ្លាប់មានព្យាបាលគាត់ផង ព្យាបាលសមាជិកគ្រួសារអ្នកវត្តគរហ្នឹងបាទ ស្គាល់ច្រើន ហើយមានបុគ្គលិកពេទ្យមួយចំនួនក៏ជាអ្នកវត្តគរដែរ បាទ ខ្ញុំស្គាល់។

[១៥:៥១:៥៨]

ហើយក្នុងរបបខ្មែរក្រហមប្អូន នួន ជា ម្នាក់ដែលធ្វើគយ អត់មានគេយកទៅណាទេ គឺគាត់នៅបើកឡានក្នុងរបបខ្មែរក្រហម ខុសពីមន្ត្រីដទៃទៀតបាទ ទី១។ ទី២ ក្នុងជំនាន់របបខ្មែរក្រហម ភូមិវត្តគរនេះ គឺក្មេងក្តីចាស់ក្តីទទួលរបបមួយកំប៉ុងកន្លះ ១ថ្ងៃដូចគ្នា។ ហើយនៅកន្លែងណាដែលភូមិណាដែល

អត់ឃ្លាន គឺរបបភូមិវត្តគរអត់មានប្រែប្រួលទេ បាទ។ ហើយខ្ញុំស្គាល់អ្នកដែលផ្គត់ផ្គង់ម្ហូបអាហារដល់ម្ដាយលោក នួន ជា បាទ ពីព្រោះគាត់ក៏ជាអ្នកផ្គត់ផ្គង់ម្ហូបដល់មន្ទីរពេទ្យដែលខ្ញុំធ្វើការដែរ គឺមន្ទីរពេទ្យព-២ និងមន្ទីរពេទ្យព-១ ហើយគាត់ក៏ផ្គត់ផ្គង់ម្ហូបអាហារដល់លោក ម្ដាយលោក នួន ជា ដែរ បាទ។

**ស៖** សូមអរគុណ។ ប្រសិនបើខ្ញុំអាចសួរលោកអំពីការប្រែប្រួល ឬក៏ការផ្លាស់ប្ដូររចនាសម្ព័ន្ធរដ្ឋបាលនៅភូមិភាគពាយ័ព្យ នៅក្នុងសៀវភៅរបស់លោកត្រង់ជំពូក៨ និង ៩ លោកនិយាយអំពីការបាត់ខ្លួនកម្មាភិបាលពាយ័ព្យ ហើយនិងការមកដល់នៃកម្មាភិបាលបស្ចិម។ ហើយលោកបានឃើញការចាប់ខ្លួនមនុស្សម្នាក់ដែលមកតាមទូក។ ដូច្នេះអ្វីដែលខ្ញុំដកស្រង់នេះ គឺចេញមកពីម៉ុំៗ ដោយដាច់ដោយឡែកពីគ្នាតែប៉ុណ្ណោះ មិនបានជាអត្ថបទមួយទាំងមូលនោះទេ។ និយាយអំពីចំណុចមួយដែលលោកបានសរសេរអំពីការប្រជុំមួយដែលលោកបានទៅចូលរួមនៅក្នុងចុងឆ្នាំ៧៧ ដើមឆ្នាំ៧៨ ត្រង់ជំពូក៨។ ខ្មែរ ERN គឺ 00678865, អង់គ្លេស ERN គឺ 00369758។ លោកបានសរសេររៀបរាប់ថា មានកិច្ចប្រជុំមួយនោះលោកបានទៅចូលរួមប្រជុំនៅពេលយប់។ ហើយលោកបានដឹងអំពីការមកដល់កម្មាភិបាលថ្មីរបស់ខ្មែរក្រហម។ យោងតាមចំណុចនោះគឺថា លោកបានរៀបរាប់អំពីស្ថានភាពខ្មាំងនៅក្នុងប្រទេស និងស្ថានភាពខ្មាំងនៅក្រៅប្រទេស។ ហើយប្រសិនបើខ្ញុំដកស្រង់សម្ដីនៅទីនេះចំពោះសភាពការណ៍ខ្មាំងក្នុងប្រទេស ខ្មែរក្រហមបានលើកឡើងអំពីខ្មាំងស៊ីរូងផ្ទៃក្នុង ពួកសេ.អ៊ី.អា ពួកកា.ហ្សេ.បេ ពួកប្រតិកិរិយា ពួកសេរីនិយមក្នុងជួរកម្មាភិបាលគ្រប់ជាន់ថ្នាក់ និងបញ្ហាបដិវត្តន៍ដាច់ខាត និងទាំងស្រុងត្រូវកម្ទេចពួកទាំងនេះ។ ខ្ញុំសូមសួរ តើចំណុចដែលខ្ញុំរៀបរាប់នេះ គឺលោកបានស្ដាប់ឮដោយផ្ទាល់ត្រចៀកក្នុងពេលដែលលោកចូលរួមប្រជុំនោះ ឬក៏យ៉ាងម៉េច?

[១៥:៥៦:០៧]

**ឆ៖** ឮដោយផ្ទាល់ត្រចៀក ពីព្រោះថាពេលយប់បន្ទាប់ពីធ្វើការយ៉ាងហត់នឿយ គេកោះពលករទាំងអស់ឲ្យចូលរួមប្រជុំ។ ខ្ញុំមិនចូលចិត្តការប្រជុំទេ ខ្ញុំមិនដែលស្ដាប់ ប៉ុន្តែដល់យូរៗទៅ ខ្ញុំឮតែវាលើកឡើងដដែលៗ គឺខ្មាំងស៊ី -- ខ្មាំងផ្ទៃក្នុង ខ្មាំងក្នុងប្រទេស និងខ្មាំងក្រៅប្រទេស ហើយខ្ញុំក៏ចាប់អារម្មណ៍នោះបាទ។ នេះខ្ញុំស្ដាប់ផ្ទាល់។

**ស៖** ខ្ញុំសួរតាមរបៀបនេះវិញ។ ចំពោះការប្រជុំដែលបានរៀបចំឡើងក្នុងអំឡុងពេលនុ៎ងនោះ ដែលថាលោកបានឃើញការបាត់ខ្លួនកម្មាភិបាលភាគពាយ័ព្យ ហើយបន្ទាប់មកគឺគេយកកម្មាភិបាលពីបស្ចិមនោះមកជំនួស នៅក្នុង -- នៅកន្លែងនោះ។ តើការបាត់ខ្លួន និងការជំនួសក្នុងពេលដែលរៀបរាប់

នេះតែមួយ ឬក៏យ៉ាងម៉េច?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

កុំអាល់ទាន់ឆ្លើយៗ!

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** ខ្ញុំមិនបានឃើញការបាត់ខ្លួនកម្មាភិបាលពាយ័ព្យទេ ប៉ុន្តែខ្ញុំឃើញកម្មាភិបាលបស្ចិមដែលមកថ្មី បស្ចិមមកជំនួស។ ហើយខ្ញុំឃើញតែម្តងគត់ ដែលគេចាប់ចងដាក់ទូក ដែលលោកបានមានប្រសាសន៍ ឃើញម្តងគត់ ឃើញគេចាប់ទៅនោះបាទ។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** សូមអរគុណ។ លោកវេជ្ជបណ្ឌិត ឈុនលី យើងបានជជែកគ្នាខាងដើម បុគ្គលម្នាក់ឈ្មោះថា--

**អ្នកបកប្រែ៖**

សូមអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាគាត់បញ្ជាក់ឈ្មោះឡើងវិញ អ្នកបកប្រែស្តាប់ឈ្មោះមិនច្បាស់។

**ប្រធានអង្គជំនុំ៖**

លោកតំណាងសហព្រះរាជអាជ្ញារៀបចំសំណួរសាជាថ្មីឡើងវិញ ហើយជាពិសេសឈ្មោះ។ អម្បាញ់មិញនេះគឺអ្នកបកប្រែស្តាប់អត់បានទេ អត់មានការបកប្រែទេ។

[១៥:៥៨:៤១]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** បុគ្គលដែលយើងបានជជែកគ្នាខាងដើម គឺឈ្មោះ ខេកប៉ែន ហៅ ស៊ូ-- ខែក ប៉ែន ហៅ ស៊ូ ដែលស្ថិតនៅក្នុងតំបន់មួយនៅភូមិភាគពាយ័ព្យ ដែលលោកបានរៀបរាប់មុនគឺ ខែក ប៉ែន ហៅ ស៊ូ។ តើលោកមានបានដឹងទេ មានអ្វីកើតឡើងចំពោះគាត់? តើគាត់ជួបជោគវាសនាអ្វីដែរក្នុងរបបខ្មែរក្រហម?

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** ខ្ញុំមិនដឹងទេ ពីព្រោះថាពេលនោះមានការ ហៅថា ការចម្រាញ់ជាបន្តបន្ទាប់។ ដូច្នេះខ្ញុំមិន

ដឹងថា នរណានៅស្លាប់ នរណារស់ ខ្ញុំមិនដឹងទេបាទ។ គ្រាន់តែដឹងថាមានការចម្រាញ់ជាបន្តបន្ទាប់។

**លោក អាប់ឌុលឡាក់ ថារីក៖**

យើងខ្ញុំសូមអនុញ្ញាតបង្ហាញឯកសារមួយទៅដល់សាក្សី ថាតើគាត់ស្គាល់ទេឈ្មោះអម្បាញ់មិញនេះ។ គឺឯកសារ D108/26.1.04 គឺបញ្ជីអ្នកទោសនៅ ស-២១ ហើយចង់សួរថាគាត់ស្គាល់ទេ? ហើយវាដូចគ្នាទៅនឹងបុគ្គលដែលគាត់រៀបរាប់អម្បាញ់មិញនេះដែរឬទេ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអនុញ្ញាតពីលោកប្រធាន ហើយយើងខ្ញុំមានឯកសារនេះជាក្រដាសផងដែរ។ ដូច្នេះហើយគឺខ្ញុំសូមអនុញ្ញាតផ្តល់ជូនទៅដល់សាក្សី ដើម្បីងាយស្រួលសម្រាប់គាត់មើល។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកជូនសាក្សីពិនិត្យ!

[១៦:០០:៤២]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ ខ្មែរ ERN គឺ 00086931។ ខ្ញុំសូមឲ្យខាងមន្ត្រីរបស់ខ្ញុំនេះបញ្ចាំងលើអេក្រង់ត្រង់ទំព័រនេះ គឺ 00086931, ឯកសារដែលនៅក្នុងដៃរបស់លោកនេះ បារាំងគឺលេខ 00864730 ទៅដល់ 731, អង់គ្លេស គឺ 00837610។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក ឈុនលី នៅត្រង់ចំណុចទី៦ នៃឯកសារនេះ ខ្ញុំអានចេញពីឯកសារជាភាសាអង់គ្លេស។ ហើយខ្ញុំសង្ឃឹមថាលោកអាចតាមទាន់មើលឯកសារខ្មែរនៅក្នុងចំណុចទី៦ និយាយថា "តំបន់៤ បុគ្គលក្នុងជួរលេខ ១០ - ២៦ ហៅ ខែក ប៊ុន ហៅ ស៊ូ លេខាតំបន់"។ គឺត្រង់ចំណុចលេខ២៩។ ដូច្នេះសូមឲ្យលោកពិនិត្យមើលនោះ ថាតើឈ្មោះហ្នឹងគឺបុគ្គលតែមួយដែលលោកបានរៀបរាប់ ហើយហៅ -- ហើយរៀបរាប់អំពីគាត់ហ្នឹង ពីខាងដើមហ្នឹង តើជាបុគ្គលតែមួយឬយ៉ាងម៉េច?

[១៦:០២:០៩]

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** ខ្ញុំៗមិនប៉ានថាយ៉ាងម៉េចទេ ព្រោះឈ្មោះគាត់គេហៅ ខែក ប៉ែន ៗ ឬ មិត្តស៊ូ។ នេះ ខែក ប៊ុន ហៅ ស៊ូ។ ដូច្នេះ ខ្ញុំមិនប៉ានថា ត្រូវ ឬខុសទេបាទ។

**ស៖** សូមអរគុណ។ គឺយើងអាចដកចេញឯកសារនេះពីសាក្សីវិញបាន។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន តើយើងគួរសម្រាកនៅពេលនេះ ឬក៏អនុញ្ញាតឲ្យខ្ញុំបន្តទៅមុខទៀត?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ មន្ត្រីរដ្ឋបាលតុលាការដកឯកសារជាក្រដាសពីសាក្សីវិញ។

បាទ ឥឡូវនេះដល់ពេលត្រូវសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃសុក្រ ទី០៧ ខែធ្នូ ឆ្នាំ២០១២ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយសវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មសាក្សី ហ៊ុន ឈុនលី។ សូមភាគី និងសាធារណជនជ្រាប។

[១៦:០៣:០៧]

លោក ហ៊ុន ឈុនលី ការស្តាប់សក្ខីកម្មរបស់លោក នៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះនឹងបន្តធ្វើការស្តាប់សក្ខីកម្មសាក្សីរបស់លោក នៅថ្ងៃស្អែកទៀត។ ដូច្នេះ អង្គជំនុំជម្រះកោះអញ្ជើញលោកមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀត។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនសាក្សីរូបនេះ វិលត្រឡប់ទៅលំនៅដ្ឋានគាត់វិញចុះ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញ នៅព្រឹកថ្ងៃស្អែកនៅវេលាម៉ោងប្រាំបួន។

បង្គាប់ឲ្យមន្ត្រីអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងបីរូបទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ ហើយនិងឲ្យនាំខ្លួនពួកគាត់ត្រឡប់មកកាន់បន្ទប់សវនាការនេះវិញ នៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។ ដោយឡែក លោក អៀង សារី ឲ្យនាំគាត់មកនៅត្រឹមបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដែលមានរៀបចំនូវឧបករណ៍សោតទស្សន៍ សម្រាប់គាត់អាចចូលរួម និងតាមដានការសវនាការពីចម្ងាយ។ សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០៤ នាទី)*